ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុរបស់សម្តេចព្រះមហាក្សត្រីព្រះវររាជ មាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គលគម្រប់ ៨៨ ព្រះវស្សា

◆ លិខិតថ្លែងអំណរគុណ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៩៤ ខែមិថុនា ឆ្នាំ២០២៤

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា



ព្រះឆាយាលក្ខណ៍សម្តេចព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

### សំបុត្រ


- ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុរបស់សម្តេចព្រះមហាក្សត្រីព្រះវររាជ មាតាជាតិខ្មែរ........ ១
- លិខិតថ្លែងអំណរគុណ ........................... ២


### ផ្នែកឯកសារ


- ឈួន ស៊ាង ៖ និស្សិតពេទ្យ ........................ ៣


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- ជីវិតស្ត្រីក្នុងកងចល័តនារីខ្មែរក្រហម............ ៦
- កងចល័តវ័យកណ្តាលក្នុងរបបខ្មែរក្រហម ..... ៩
- វេទិកាអន្តរជំនាន់ស្តីពី «ជំនឿ និងប្រវត្តិសាស្ត្រ» នៅវត្តពោធិមានបុណ្យ ឃុំដង្កៀមក្តាម ...... ១២
- មជ្ឈមណ្ឌលឯកសារកម្ពុជាចុះពិនិត្យសុខភាពបឋម និងចែករទេះរុញ .......................... ១៥
- មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងសហការជាមួយរដ្ឋបាលស្រុកអន្លង់វែង ចែករទេះរុញ ........ ១៩
- មជ្ឈមណ្ឌលឯកសារកម្ពុជា និងមន្ទីរពេទ្យ INTER CARE ប្រគល់សម្ភារបរិក្ខារពេទ្យ....... ២១
- មជ្ឈមណ្ឌលឯកសារកោះថ្ម ចែករទេះរុញ និងការសជំនួយត្រចៀកជូនអ្នកដែលមាន ........ ២៣
- មជ្ឈមណ្ឌលឯកសារកោះថ្ម គោរពវិញ្ញាណក្ខន្ធ និងដាក់កម្រងផ្កាជាការចងចាំ និងដឹងគុណ...... ២៦
- មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើង ............ ២៩
- មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បណ្តុះបណ្តាលសិស្សវិទ្យាល័យ ហ៊ុន សែន ស្គន់ អំពីការប្រើប្រាស់ម៉ាស៊ីនថតរូប និងបច្ចេកទេសថតរូប.......... ៣៤
- អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ បានធ្វើទស្សនកិច្ចសិក្សា និងជួប ..... ៣៦
- អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ទស្សនកិច្ចសហគមន៍ភូមិបាក់នឹម..... ៣៩
- ទាវ ឆុន រំឭកអំពីសាវតាររបស់ខ្លួនជា ......... ៤១
- ជាយ ហ៊ុយ អតីតខ្មែរសដែលជាចលនា...... ៤៥


### ផ្នែកវេទិកាពិភាក្សាសាធារណៈ


- អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកបុរីអូរស្វាយ សែនជ័យ ទទួលបាន............ ៤៨
- មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជា.............. ៥១
- មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាថ្នាក់រៀនស្តីពី «ការជម្លៀសដោយបង្ខំ» ................ ៥៤


### ផ្នែកស្រាវជ្រាវរកគ្រួសារ


- ជីវិតកូនប្រុសពុកក្នុងគុកខ្មែរក្រហម (គ) ... ៥៨



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ ៖** ឆាំង យុ, ដា៉រដ្ឋ មេត្តា, ស៊្តឹង វ៉ាន់ដាន, ឈាង ស៊ីវឈីង, ស្រិន លាងវឈី, អេង សុខម៉េង, លី សុខឃាង, រស់ សំពៅ, ឈុំ វ៉ា, រី ស៊ីថា, ឡុង ដានី, សាំង ចាន់ធូ, ស៊ាង ចិន្តា, ស្រេង លីដា, និង ហង្ស ឆាំឆាន

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដា៉រដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនី ឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វេ៉ង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org



# ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុរបស់
# សម្តេចព្រះមហាក្សត្រីព្រះវររាជ មាតាជាតិខ្មែរ
## ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
## គម្រប់ ៨៨ ព្រះវស្សា

ទូលព្រះបង្គំខ្ញុំបាទ **ឆាំង យុ** នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា
និងជាស្ថាបនិកព្រះរាជបណ្ណាល័យ ហ្វូងម៉ែ សូមព្រះបរមរាជានុញ្ញាត
ក្រាបបង្គំទូលថ្វាយសេចក្តីគោរព និងព្រះពរក្នុងព្រះវរោកាស
ដ៏មហាប្រសើរ ថ្ងៃថ្លា នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុរបស់
**សម្តេចព្រះមហាក្សត្រី ព្រះវររាជ មាតាជាតិខ្មែរ**
ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ
និងសុភមង្គល។

# លិខិតថ្លែងអំណរគុណ

មជ្ឈមណ្ឌលឯកសារកម្ពុជា
សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ
**ឯកឧត្តមបណ្ឌិត ជា ចាន់តូ**
អគ្គទេសាភិបាលកិត្តិយស ធនាគារជាតិកម្ពុជា
ដែលផ្តល់សៀវភៅមានចំណងជើងថា
**«របប ប៉ុល ពត ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍» ចំនួន ៥៣ក្បាល**
**សម្រាប់តម្កល់ទុកនៅបណ្ណាល័យមជ្ឈមណ្ឌលឯកសារកម្ពុជា។**
សៀវភៅ «របប ប៉ុល ពត ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍»
នេះ គឺពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ប្រវត្តិសាស្ត្រប្រទេស
កម្ពុជា ជាពិសេស របបប្រល័យពូជសាសន៍ ប៉ុល ពត និងសម្រាប់ក្មេងៗ
ជំនាន់ក្រោយសិក្សាឈ្វេងយល់។

មជ្ឈមណ្ឌលឯកសារកម្ពុជា សូមគោរពជូនពរ
ឯកឧត្តម ទទួលបានសុខភាពល្អ និងជ័យជម្នះគ្រប់ភារកិច្ច។




សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចពីខ្ញុំបាទ។
ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៤
**ឆាំង យុ**
នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជា
ស្ថាបនិកព្រះរាជបណ្ណាល័យ ហ្វូនម៉ែ

# ឈួន ស្វាង ៖ និស្សិតពេទ្យ ជម្លៀសទៅតំបន់៣ ភូមិភាគពាយ័ព្យ

ដារ៉ារដ្ឋ មេត្តា



ក្រុមគ្រូពេទ្យចុះពិនិត្យសុខភាពជូនប្រជាជនក្រោយរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឈួន ស្វាង ជនជាតិខ្មែរ អាយុ៣៨ឆ្នាំ (ក្នុងឆ្នាំ១៩៧៧)។ ខ្ញុំមានឪពុកឈ្មោះ ធុច គឺជាគ្រូបង្រៀននៅវិទ្យាល័យតាកែវ និងមានបងប្រុសឈ្មោះ ម៉ុង គល់ គឺជាទាហានស័ក្តិ៤។ ខ្ញុំរៀបការរួចហើយ។ ខ្ញុំគឺជានិស្សិតពេទ្យនៅមហាវិទ្យាល័យពេទ្យ។ ខ្ញុំបានទទួលសញ្ញាបត្របណ្ឌិតពេញលក្ខណៈនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៧៥។ នៅឆ្នាំ១៩៧៧ ខ្ញុំគឺជាប្រជាជនថ្មី នៅភូមិប៉ោយសំរោង តំបន់៣ ភូមិភាគពាយ័ព្យ។ ខ្ញុំមានស្រុកកំណើតនៅភូមិទូកមាស ឃុំទូកមាស ស្រុកបន្ទាយមាស ខេត្តកំពត។

នៅឆ្នាំ១៩៥៣ ខ្ញុំចូលរៀនថ្នាក់ទី១២ នៅសាលាបឋមសិក្សាចំបក់ ស្រុកបាទី ខេត្តតាកែវ រហូតដល់ឆ្នាំ១៩៥៨ ខ្ញុំប្រឡងចូលថ្នាក់ទី៦នៅអនុវិទ្យាល័យព្រះខ្ទ័យ ក្រុងតាកែវ ខេត្តតាកែវ។ ប៉ុន្តែខ្ញុំបានប្រឡងធ្លាក់ ហើយក៏បានមករៀននៅសាលាឈ្នួលនៅអនុវិទ្យាល័យឯកជនគង់ពិសី ស្រុកត្រាំខ្នារ ខេត្តតាកែវវិញ។ នៅក្នុងឆ្នាំ១៩៥៩ ខ្ញុំប្រឡងជាប់ចូលរៀននៅអនុវិទ្យាល័យព្រះខ្ទ័យវិញហើយបានធ្វើការសិក្សារហូតដល់ឆ្នាំ១៩៦៣ ដែលជាឆ្នាំខ្ញុំចូលសេ-អ៊ុ-អា ក្រោមការណែនាំផ្ទាល់ពីបងរបស់ខ្ញុំឈ្មោះ ម៉ុង គល់។

នៅឆ្នាំ១៩៦៤ ខ្ញុំផ្លាស់មករៀននៅវិទ្យាល័យយុគន្ធរ ក្រុងភ្នំពេញ ហើយខ្ញុំបានជាប់ទាក់ទងខ្មែរសេរី-អ៊ី-អា ជាមួយឈ្មោះ ហូ, ពន្នី, ស៊ីឌី, វ៉ាន់ថា គឺជាសិស្សវិទ្យាល័យយុគន្ធរ តាមរយៈបងប្រុសរបស់ខ្ញុំឲ្យទាក់ទង។ ខ្ញុំរួមកម្លាំងជាមួយអ្នកទាំង៤នាក់នោះធ្វើសកម្មភាពស៊ើបការណ៍ពីខ្មែរក្រហមជាបន្តបន្ទាប់។ នៅឆ្នាំ១៩៦៧ ខ្ញុំជាប់សញ្ញាបត្រភាគទី២ ទៅរៀននៅមហាវិទ្យាល័យពេទ្យភ្នំពេញ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការរំដោះទីក្រុងភ្នំពេញបាន។ ពេលនោះអង្គការជម្លៀសប្រជាជនចេញពីទីក្រុង ធ្វើឲ្យខ្ញុំត្រូវដាច់ខ្សែទាក់ទងមួយរយៈ។ គ្រួសារខ្ញុំត្រូវខ្មែរក្រហមជម្លៀសទៅស្រុកភ្នំស្រុក តំបន់៥ ភូមិភាគពាយ័ព្យ។ រយៈពេល ២ខែក្រោយមក អង្គការអំពាវនាវឲ្យរដ្ឋការគ្រប់ផ្នែកមករៀនសូត្រនៅភ្នំស្រុក ហើយក៏បញ្ជូនឈ្មោះខ្ញុំមកបាត់ដំបង។ ពេលនោះ ខ្ញុំបានទាក់ទងជាមួយខ្សែចាស់ឈ្មោះ ការ (នៅឆ្នាំ១៩៧៧ អង្គការឲ្យមកភ្នំពេញ), ឈ្មោះ សំអាត នៅសហករណ៍ព្រះនេត្រព្រះ តំបន់៥ ភូមិភាគពាយ័ព្យ ដើម្បីដាក់ផែនការបំផ្លាញបដិវត្តន៍គ្រប់ផ្នែកដែលមាននៅកន្លែងនីមួយៗ។ ក្រោយមកអង្គការបញ្ជូនពួកគាត់ទៅកន្លែងផ្សេង ហើយខ្ញុំក៏ដាច់ការទាក់ទងជាមួយពួកគាត់ដែរ។

នៅខែឧសភា ឆ្នាំ១៩៧៦ ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យទៅភ្ជួររាស់ស្រែ ហើយខ្ញុំបានរួមធ្វើសកម្មភាពជាមួយ សំណាង និង វុធ បំផ្លាញបដិវត្តន៍ដោយភ្ជួរយឺត និងធ្វើឲ្យបាក់នង្គ័ល។ នៅពេលយប់ អង្គការឆ្លៀតឲ្យប្រជាជនទៅដកសំណាប ខ្ញុំក៏ចាប់ផ្តើមធ្វើសកម្មភាពបំផ្លាញបដិវត្តន៍ជាមួយនឹងខ្សែរបស់ខ្ញុំទាំងអស់ ដោយនៅពេលដកសំណាបចាប់ឲ្យធំដើម្បីឲ្យដាច់ ដកឲ្យសល់ខ្លះនៅក្នុងទីចង់សំណាបមិនត្រឹមត្រូវធ្វើឲ្យពិបាកនៅពេលស្ទូង។ បន្តមកទៀត ខ្ញុំបានធ្វើសកម្មភាពបំផ្លាញបដិវត្តន៍ជាមួយឈ្មោះ ឈឿម ក្នុងការឃ្វាលក្របីដោយមិនបានរកកន្លែងស្មៅឲ្យក្របីស៊ី ធ្វើឲ្យក្របីបាក់កម្លាំងប្រើប្រាស់លែងកើត ធ្វើឲ្យការកសាងកសិកម្មអន់ថយ ហើយធ្វើឲ្យរាំងស្ទះនូវដំណើរកសាងសេដ្ឋកិច្ចរបស់អង្គការបដិវត្តន៍។

នៅក្នុងឆ្នាំ១៩៧៧ ខ្ញុំបានទទួលកម្លាំងថ្មីទៀតដែលខ្ញុំចាប់ផ្តើមកសាងតាំងពីខែធ្នូ ក្នុងឆ្នាំ១៩៧៦មកម្ល៉េះ។ កម្លាំងថ្មីនេះមានឈ្មោះ ឆិល គឺជាបុគ្គលិកនៅធនាគារជាតិកម្ពុជា, ភឿប អតីតអ្នករកស៊ីឈ្នួលបើកបរត្រាក់ទ័រ។ បន្តមកទៀត ខ្ញុំបានរួមសកម្មភាពបំផ្លាញបដិវត្តន៍ជាមួយឈ្មោះ ទៀង និង ឈឿម ដោយឲ្យគោដើរជាន់កណ្តាប់ស្រេចតែចិត្ត ប្រមូលកណ្តាប់ស្រូវមិនឲ្យអស់ពីស្រែ ព្រមទាំងបររទេះគោកិនកណ្តាប់ស្រូវ ធ្វើឲ្យគ្រាប់ស្រូវជ្រុះពាសវាលពាសកាល។ ក្នុងរដូវបោកបែនអង្គការបានចាត់ឲ្យប្រជាជនក្នុងសហករណ៍ទៅធ្វើការបោកបែន និងបញ្ជូនស្រូវនៅវេលាយប់។ ពេលនោះខ្ញុំរួមសកម្មភាពបំផ្លាញបដិវត្តន៍ជាមួយឈ្មោះ វណ្ណា, ដាវី, ទៀង, មោ, ចក់, ហឺ, វុធ, ភឿប, ម៉ៃ, ឆិល, ភឿប និង ឈ្មោះ ស៊ីវ ដោយធ្វើការបោកបែនមិនឲ្យជ្រុះ បញ្ជូនមិនឲ្យសព្វ។ ឯការជជុះចំបើងក្រោយពេលបញ្ជូនក៏មិនឲ្យស្អាតដែរ។ ចំណែកការ ដេររមាត់បាវមិនឲ្យជិតល្អដើម្បីទុកឲ្យធ្លាយស្រូវនៅពេលដឹកជញ្ជូន។

បន្ទាប់មកអង្គការចាត់តាំងខ្ញុំទៅផ្នែកចម្ការ។ ពេលនោះខ្ញុំបានរួមសកម្មភាពបំផ្លាញបដិវត្តន៍ជាមួយឈ្មោះ ឆិល, ម៉ៃ, ហឺ និង ចក់ ដោយធ្វើដីដាំបន្លែមិនឲ្យស្អាតល្អ។ ចំណែកគ្រាប់ដំណាំសុទ្ធតែជាពូជថ្មីនាំឲ្យផ្លែមិនសូវច្រើន ឃើញមានស្លឹកល្អ ប៉ុន្តែមិនសូវផ្លែ ហើយការស្រោចទឹកក៏មិនបានដិតដល់, មិនការពារសត្វល្អិតនាំឲ្យខូចបន្លែជាច្រើនរង ចំណែកសម្ភារដូចជា ចប បង្គី ធុង ស្រោចទឹក ទុកបោលឲ្យបាក់ និងប្រើការលែងកើត។

នៅពាក់កណ្តាលឆ្នាំ១៩៧៧ ការឃោសនាបំផុសបំផុលក៏ឡើងមួយកម្រិតថែមទៀតស្របគ្នានឹងការព្យុះសូរការកាំភ្លើងធំឯព្រំដែនទាំងថ្ងៃទាំងយប់ដែលជាកត្តាមួយងាយស្រួលក្នុងការបញ្ចូលចិត្តគំនិតអ្នកដែលមានសតិអារម្មណ៍វិវដ្តទៅរកសង្គមចាស់។ ឆ្លៀតក្នុងឱកាសនោះ ខ្ញុំចាប់ផ្តើមធ្វើសកម្មភាពឃោសនាឲ្យប្រជាជនក្នុងសហករណ៍កាន់តែមានកំហឹងនឹងបដិវត្តន៍ ដោយសកម្មភាពនេះខ្ញុំធ្វើ ឡើង

*ដោយមានការចូលរួមជាមួយឈ្មោះ វឌ្ឍនា, ដាវី, វុធ និង មោ ជាជំនួយ។ ក្រោយមកអង្គការតម្រូវឲ្យខ្ញុំមករាស់ដី ហើយរួមសកម្មភាពជាមួយឈ្មោះ ឈឿម, ភឿប, ស៊ីវ និង វុធ ដោយរាស់មិនឲ្យសល់ដីព្រមទាំងវាយធ្វើបាបគោ ក្របី ឲ្យដើរជាន់និងស៊ីសន្ទូង។ ឯការថែរក្សាសត្វមិនដិតដល់ និងបានអនុវត្តប្រឆាំងប្រៀបផែនការថ្មី ស្រាប់តែថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៧៧ អង្គការក៏ចាប់ខ្ញុំបញ្ជូនមកកន្លែងឃុំឃាំងបន្ទាយនាងតំបន់៥ អស់រយៈពេល១៨ថ្ងៃ ហើយថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៧ ក៏បញ្ជូនខ្ញុំមកភ្នំពេញតែម្តង។*

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារJ00៤៩៧។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ឈួន ស៊ាង ពិតប្រាកដយ៉ាងណានោះទេ?***



*គ្រូពេទ្យដេររបួសឲ្យអ្នកជំងឺក្រោយរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# ជីវិតស្ត្រីក្នុងកងចល័តនារីខ្មែរក្រហម

ស្ដើង ឌ៉ាន់ដាន



សិស្សវិទ្យាល័យ ឈីនលាន ហាន់ជ័យ ចុះស្រាវជ្រាវលើប្រធានបទស្តីពី «ជីវិតស្ត្រីក្នុងកងចល័តនារីខ្មែរក្រហម»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីថ្ងៃទី១១ ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំដំណើរទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» សម្រាប់អ្នកស្រាវជ្រាវវ័យក្មេងដែលកំពុងតែសិក្សានៅវិទ្យាល័យ ឈីនលាន ហាន់ជ័យ និងជាអ្នកស្ម័គ្រចិត្តកម្ពុជាប្រចាំខេត្តកំពង់ចាម។ គោលបំណងនៃដំណើរទស្សនកិច្ចគឺ ទី១) ដើម្បីសិក្សាឈ្វេងយល់ពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលធ្លាប់ទទួលរងការជម្លៀសដោយបង្ខំតាមរថភ្លើងដំណាក់កាលទី៣, ទី២) បង្កើនការយល់ដឹងអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមិនទាន់បានចងក្រង និងចុះផ្សាយអំពីប្រវត្តិ-សាស្ត្ររបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទី៣) ទទួលបានឱកាសឈ្វេងយល់ពីផ្លូវរថភ្លើង និងទទួលបានបទពិសោធន៍ផ្ទាល់ខ្លួនក្នុងការធ្វើដំណើរតាមរថភ្លើងដើម្បីលើកកម្ពស់អំពីការចូលរួមដោយប្រជាធិបតេយ្យ។ អ្នកស្រាវជ្រាវវ័យក្មេង ទទួលបានចំណេះដឹង និងបទពិសោធន៍ថ្មីៗជាច្រើនចេញពីការសិក្សាទាំងទ្រឹស្តី និងការចុះអនុវត្តផ្ទាល់។ អ្នកស្ម័គ្រចិត្តកម្ពុជាបានចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ក្រោមប្រធានបទការជម្លៀសប្រជាជនដោយបង្ខំ ដំណាក់កាលទី៣ក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) និងការធ្វើបទបង្ហាញអំពីប្រភេទឯកសារដើម និងវិធីសាស្ត្រស្រាវជ្រាវ។

ជាការអនុវត្តជាក់ស្តែង អ្នកស្រាវជ្រាវវ័យក្មេងត្រូវចុះជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅខេត្តពោធិ៍សាត់។

ប្រធានបទសម្រាប់ក្រុមទី១ ដែលជាអ្នកស្រាវជ្រាវវ័យក្មេងរួមមាន ស្តើង វ៉ាន់ដាន, ឆេង ឡៃហ័ង, លឹម ស៊ូខេង, វ៉េត អ៊ីនហ៊ួន, ប្រុស មករា, ចក់ អេងលី, ថៃ ស្រីញ៉ា និង ម៉ៅ លាងហ៊ួក ចុះទៅស្រាវជ្រាវគឺផ្តោតលើ «ជីវិតស្ត្រីក្នុងកងចល័តនារីខ្មែរក្រហម»។ អ្នកស្រាវជ្រាវវ័យក្មេងបានជួប និងសម្ភាសន៍ស្ត្រីដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមសរុបចំនួន៣នាក់ ដែលចែករំលែកអំពីបទពិសោធន៍ក្នុងរបបខ្មែរក្រហម និងសុខភាពបច្ចុប្បន្នរបស់ខ្លួន។ ស្ត្រីជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំង៣នាក់សុទ្ធតែធ្លាប់ធ្វើការងារនៅតាមកងចល័តផ្សេងៗគ្នាក្នុងរបបខ្មែរក្រហម។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទី១) ឈ្មោះ អួន មៀន អាយុ៧៨ឆ្នាំ គឺជាកងចល័តនារីវ័យកណ្តាលក្នុងរបបខ្មែរក្រហម។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទី២) ឈ្មោះ សួន គី អាយុ៦៥ឆ្នាំ គឺជាកងចល័តនារីក្នុងរបបខ្មែរក្រហម និងទី៣) អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ឈ្មោះ ជួន ណាត អាយុ៥៥ឆ្នាំ គឺជាកងចល័តកុមារក្នុងរបបខ្មែរក្រហម។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាស្ត្រី បាននិយាយរៀបរាប់អំពីបទពិសោធន៍មួយថ្ងៃក្នុងរបបខ្មែរក្រហមប្រាប់ដល់អ្នកស្រាវជ្រាវវ័យក្មេងក្រុមទី១ ដូចខាងក្រោម៖

## អួន មៀន ៖ អតីតកងចល័តនារីវ័យកណ្តាលក្នុងរបបខ្មែរក្រហម

«ខ្ញុំឈ្មោះ អួន មៀន អាយុ៧៨ឆ្នាំ បច្ចុប្បន្នរស់នៅភូមិបឹងខ្នារ ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់។ ខ្ញុំមានកូនចំនួន៨នាក់។ ខ្ញុំគឺជាកូនស្រីច្បង និងមានបងប្អូនប្រុសស្រីសរុបចំនួន៤នាក់។ ខ្ញុំរៀបការប្តីនៅអាយុ១៩ឆ្នាំ និងបង្កើតកូនប្រុសបានចំនួន៣នាក់។ នៅពេលដែលប្រទេសមានសង្គ្រាម ប្តីខ្ញុំចូលធ្វើជាទាហានលន់ នល់។ មិនយូរប៉ុន្មានបន្ទាប់ពីកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ ទីរួមខេត្តពោធិ៍សាត់ក៏ត្រូវបានរំដោះ។ ប្តីនិងកូន រួមទាំងឪពុកម្តាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់ចោល ពីព្រោះប្តីរបស់ខ្ញុំគឺជានាយទាហានលន់ នល់។ ខ្ញុំអាចរួចផុតពីការសម្លាប់នៅគ្រានោះ ទាំងដែលខ្ញុំត្រូវលំបាកគ្រប់បែបយ៉ាង។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យធ្វើការនៅកងចល័តនារីដែលត្រូវទៅធ្វើការនៅកន្លែងផ្សេងៗ។ ខ្ញុំត្រូវបង្ខំធ្វើការងារចម្រុះ ដូចជា ភ្ជួរស្រែ រែកដី ធ្វើស្រែចម្ការ និងលីសែងរបស់របរផ្សេងៗទៀត។ ការហូបចុកគឺខ្វះខាតណាស់ ដូចជា អង្ករ៤កំប៉ុង ត្រូវដាំឲ្យទៅជាបបរមួយខ្ទះធ្លោតៗ។ ខ្ញុំត្រូវធ្វើការងារគ្មានពេលសម្រាក និងពេលខ្លះធ្លាក់ខ្លួនឈឺ។ ខ្មែរក្រហមតែងតែថាខ្ញុំឈឺសតិអារម្មណ៍ ឬធ្វើពុត។ អ្វីដែលខ្ញុំចងចាំមិនភ្លេចពីរបបខ្មែរក្រហមនោះគឺ ខ្មែរក្រហមបានសម្លាប់ក្រុមគ្រួសាររបស់ខ្ញុំទាំងអស់ ពីព្រោះតែជាប់ប្រវត្តិជាអតីតទាហាន លន់ នល់ ហើយខ្លួនខ្ញុំផ្ទាល់ត្រូវរស់នៅឯកោ និងភាពអត់ឃ្លាន។ ខ្ញុំនៅតែនឹករលឹកដល់គ្រួសាររបស់ខ្ញុំជានិច្ច»។

## សួន គី៖ អតីតកងចល័តយុវនារីក្នុងរបបខ្មែរក្រហម

«ខ្ញុំឈ្មោះ សួន គី អាយុ៦៥ឆ្នាំ បច្ចុប្បន្ន គឺជាកសិករស់នៅខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ សួន និងម្តាយឈ្មោះ ហួត។ ខ្ញុំមានបងប្អូនសរុបចំនួន៨នាក់ ហើយខ្ញុំគឺជាកូនទី៤ក្នុងគ្រួសារ។ ខ្ញុំរៀបការប្តី និងមានកូនប្រុសស្រីចំនួន១២នាក់ ក្នុងនោះស្លាប់អស់៦នាក់ នៅរស់៦នាក់មកដល់សព្វថ្ងៃ។ នៅឆ្នាំ១៩៧៨ ខ្ញុំមានអាយុ១៦ឆ្នាំ។ ខ្ញុំមិនបានចូលរៀនទេ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវបានខ្មែរក្រហមចាត់ចូលជាកងចល័តនារី ដែលត្រូវធ្វើការងារ រែកដី, លើកទំនប់, ធ្វើស្រែ និងធ្វើការងារធ្ងន់ៗផ្សេងទៀត។ ខ្ញុំត្រូវបានខ្មែរក្រហមប្រើឲ្យធ្វើការនៅពេលយប់បន្ថែមទៀត ដោយគ្មានពេលសម្រាកឡើយ។ បើទោះបីជាទៅមិនរួច គឺត្រូវតែទៅដែរ។

ប្រសិនបើមិនទៅ គឺស្លាប់។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់ចូលជាប្រជាជនថ្មី ពីព្រោះខ្ញុំនៅទីរួមខេត្តពោធិ៍សាត់ ដែលកាន់កាប់ដោយទាហាន លន់ នល់ ហើយក្រោយមកត្រូវបានរំដោះនៅឆ្នាំ១៩៧៥។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវបង្ខំឲ្យធ្វើការងារនៅតាមកងចល័តនារី ដែលត្រូវដើរទៅធ្វើការធ្ងន់ និងស្ថិតនៅឆ្ងាយពីភូមិ។ ការងារដែលខ្ញុំត្រូវធ្វើរួមមានលើកទំនប់, ធ្វើស្រែ និងភ្ជួររាស់។ ខ្ញុំមិនមានពេលសម្រាកគ្រប់គ្រាន់ និងគ្មានអាហារហូបឆ្អែតឡើយ។ ជីវិតពេលនោះគឺពិតជាលំបាកខ្លាំងណាស់។ អ្វីដែលខ្ញុំសោកស្តាយបំផុតនោះគឺ ខ្ញុំបាត់បង់បងប្អូនចំនួន៥នាក់ និងឪពុកម្តាយរបស់ខ្ញុំដែលបានស្លាប់ក្នុងរបបខ្មែរក្រហម។ នេះគឺជាការចងចាំដែលខ្ញុំមិនអាចបំភ្លេចបាន»។

## ជួន ណាត ៖ អតីតកងកុមារក្នុងរបបខ្មែរក្រហម

«ខ្ញុំឈ្មោះ ជួន ណាត អាយុ៥៥ឆ្នាំ គឺជាកសិកររស់នៅស្រុកបាកាន ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ ជុំ ភួន និងម្តាយឈ្មោះ ឃឹម សយ។ ខ្ញុំគឺជាកូនស្រីច្បងក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៦នាក់ ក្នុងនោះមានប្រុស៤នាក់ និងស្រី២នាក់។ ខ្ញុំបានរៀបការប្តីនិងមានកូនចំនួន៤នាក់ គឺប្រុស១នាក់ និងស្រី៣នាក់។ ភូមិរបស់ខ្ញុំត្រូវកងទ័ពខ្មែរក្រហមរំដោះចន្លោះពីឆ្នាំ១៩៧៣និងឆ្នាំ១៩៧៤។ នៅពេលនោះខ្ញុំទើបមានអាយុ១០ឆ្នាំប៉ុណ្ណោះ។ ខ្ញុំមិនបានរៀនសូត្រអ្វីទេ។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវអង្គការខ្មែរក្រហមចាត់ឲ្យចូលធ្វើការក្នុងកងចល័តកុមារ។ ខ្មែរក្រហមបានឲ្យខ្ញុំធ្វើការងារជាមួយកុមារដទៃទៀតជាច្រើន។ ខ្ញុំត្រូវធ្វើការងារដូចជា កើបអាចម៍គោ, កាប់ដើមទន្ទ្រានខែត្រ, លើកដីធ្វើភ្លឺស្រែ និងរើសដំឡូង។ ខ្មែរក្រហមបានប្រើឲ្យខ្ញុំធ្វើការងារតាំងពីព្រលឹមរហូតដល់ម៉ោង២រសៀល ទើបបានហូបបាយថ្ងៃ និងពេលខ្លះហួសម៉ោង២ទៅទៀត។ ខ្ញុំធ្វើការទាំងអត់អាហារក៏មានដែរ។ ខ្ញុំធ្លាប់លួចរត់ទៅជួបម្តាយ ប៉ុន្តែត្រូវបានឈ្លបខ្មែរក្រហមចាប់បាន រួចក៏បញ្ជូនខ្ញុំមកកាន់កងកុមារវិញ និងធ្វើទារុណកម្មដោយការចាប់វាយ និងឃុំឃាំងខ្ញុំ។ ខ្ញុំត្រូវអង្គការចាត់ចូលជាប្រជាជនថ្មី។ ក្នុងអំឡុងពេលនោះ អង្គការសង្ស័យថាខ្ញុំជាកូនទាហាន លន់ នល់ ពីព្រោះអង្គការឮខ្ញុំនិយាយពាក្យថា «ប៉ាម៉ាក់»។ ខ្ញុំស្ទើរតែត្រូវបានអង្គការចាប់យកទៅសម្លាប់ ប៉ុន្តែខ្ញុំបានរត់គេច និងមានអ្នកភូមិជួយលាក់អត្តសញ្ញាណរបស់ខ្ញុំ។ នៅក្នុងកំឡុងពេលដែលរត់គេចខ្លួនពីការចាប់សម្លាប់ ខ្ញុំរត់ទៅជួបកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិ ទើបខ្ញុំអាចនៅមានជីវិតរស់នៅមកដល់សព្វថ្ងៃនេះ»។

រឿងរ៉ាវរបស់ស្ត្រីជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំង៣នាក់ខាងលើ បានបង្ហាញអំពីការធ្វើការងារជាទម្ងន់របស់ស្ត្រី ក្នុងរបបខ្មែរក្រហមដែលឆ្លុះបញ្ចាំងអំពីប្រវត្តិសាស្ត្រយ៉ាងច្បាស់អំពីភាពអំណត់ និងស៊ូទ្រាំរបស់ស្ត្រីក្នុងរបបខ្មែរក្រហម។





សិស្សវិទ្យាល័យ ឈីនលាន ហាន់ជ័យ ចុះស្រាវជ្រាវលើប្រធានបទស្តីពី «ជីវិតស្ត្រីក្នុងកងចល័តនារីខ្មែរក្រហម»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# កងចល័តវ័យកណ្ដាលក្នុងរបបខ្មែរក្រហម

ឈាង ស៊ីវឈីង



សិស្សវិទ្យាល័យ ឈីនលាន ហាន់ជ័យ ចុះស្រាវជ្រាវលើប្រធានបទស្ដីពី «កងចល័តវ័យកណ្ដាលក្នុងរបបខ្មែរក្រហម»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីថ្ងៃទី១១ ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំដំណើរទស្សនកិច្ចសិក្សាអំពី«ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» សម្រាប់អ្នកស្រាវជ្រាវវ័យក្មេងដែលកំពុងតែសិក្សានៅវិទ្យាល័យ ឈីនលាន ហាន់ជ័យ និងជាអ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ប្រចាំខេត្តកំពង់ចាម។ គោលបំណងនៃដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើង គឺដើម្បីឈ្វេងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ក្នុងនោះក្រុមការងារនៃមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ក៏បានបែងចែកយុវជនទៅជាក្រុមអ្នកស្រាវជ្រាវវ័យក្មេងចំនួន៥ក្រុម។ ក្រុមនីមួយៗត្រូវទទួលបានចំណេះដឹង និងបទពិសោធន៍ថ្មីៗជាច្រើនចេញពីការសិក្សាទាំងទ្រឹស្ដី និងការចុះអនុវត្តផ្ទាល់។ មេរៀនទ្រឹស្ដី គឺក្រុមអ្នកស្រាវជ្រាវវ័យក្មេង ត្រូវចូលរួមវេទិកាថ្នាក់រៀនស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ក្រោមប្រធានបទការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី៣ ក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) និងការធ្វើបទបង្ហាញអំពីប្រភេទឯកសារដើម និងវិធីសាស្ត្រស្រាវជ្រាវ បង្រៀនដោយលោក ស៊ាង ចិន្ដា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។

ក្រោយពីបានចូលរៀនក្នុងវេទិកាថ្នាក់រៀនរួច ក្រុមអ្នកស្រាវជ្រាវវ័យក្មេង ត្រូវទទួលយកប្រធានបទមួយរួមទាំងសំណុំឯកសារទាក់ទងការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម សម្រាប់ចុះទៅសិក្សា

ស្រាវជ្រាវសម្ភាសន៍ផ្ទាល់តាមរយៈផ្លូវរថភ្លើងកាលពីរបបខ្មែរក្រហម ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅខេត្តពោធិ៍សាត់។ គោលបំណងនៃដំណើរការស្រាវជ្រាវគឺ ទី១) ដើម្បីចងក្រងឯកសារប្រវត្តិសាស្ត្រ និងចង់ដឹងអំពីការពិតនៃប្រវត្តិសាស្ត្រដែលប្រជាជនប្រមាណ២លាននាក់បានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។ ក្រុមស្រាវជ្រាវបានរៀនសូត្រ និងយល់ដឹងអំពីទិដ្ឋភាពជូរចត់ ដែលប្រជាជនជំនាន់មុនបានរស់នៅនិងឆ្លងកាត់។ ទី២) ចង់ឲ្យកូនខ្មែរជំនាន់ក្រោយចេះចងក្រងឯកសារ សិក្សាឈ្វេងយល់ពីផលលំបាក និងសោកនាដកម្មបន្សល់ទុកដោយរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ទី៣) គឺការបណ្តុះស្មារតីផ្សះផ្សា ចេះសាមគ្គីគ្នា និងចេះអធ្យាស្រ័យគ្នា ដើម្បីបង្រួបបង្រួមជាតិ ការពារកុំឲ្យរបបប្រល័យពូជសាសន៍កើតមាននាពេលអនាគត។

ខាងក្រោមនេះគឺជាបទសម្ភាសន៍ដោយសង្ខេបរបស់ក្រុមអ្នកស្រាវជ្រាវវ័យក្មេង ជាមួយ មាស រ៉េន ធ្លាប់ធ្វើការងារក្នុងកងចល័តវ័យកណ្តាលក្នុងរបបខ្មែរក្រហម ៖

«ខ្ញុំឈ្មោះ **មាស រ៉េន** អាយុ៧១ឆ្នាំ រស់នៅភូមិដង្កៀបក្តាម ឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ យន់ និង ម្តាយឈ្មោះ យេន។ ខ្ញុំមានបងប្អូនចំនួន៩នាក់ ហើយខ្ញុំជាកូនទី៣ក្នុងគ្រួសារ។ ខ្ញុំធ្លាប់បានចូលរៀនជាមួយព្រះសង្ឃនៅវត្ត។ នៅឆ្នាំ១៩៧២ ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំឈ្មោះ ណែម។ ក្រោយពេលខ្ញុំរៀបការរួច ខ្ញុំមានកូនចំនួន៦នាក់។ ខ្ញុំគឺជាកូនកសិកររស់នៅជនបទ ហេតុនេះខ្ញុំស្ទាត់ជំនាញក្នុងការធ្វើស្រែចម្ការ។ ពេលកងទ័ពខ្មែរក្រហមបានចូលមកគ្រប់គ្រងប្រទេសបានទាំងស្រុង ខ្ញុំរស់នៅភូមិដង្កៀមក្តាម ដដែល។ មិនបានប៉ុន្មានផងស្រាប់តែខ្មែរក្រហមជម្លៀសខ្ញុំចេញពីក្រុមគ្រួសារភ្លាមៗ។ នៅក្នុងរបបខ្មែរក្រហមវាពិតជាមានភាពលំបាកខ្លាំងណាស់ ព្រោះខ្ញុំមិនដែលបានជួបស្ថានភាពបែបនេះពីមុនមក។ ខ្ញុំត្រូវបានជម្លៀសឲ្យទៅនៅភូមិកូកាង ដែលខណៈនោះខ្ញុំមានអាយុ៣០ឆ្នាំហើយ។ ការងាររបស់ខ្ញុំនៅពេលនោះគឺតម្រូវឲ្យជីកដីលើកទំនប់ ចំណែកអាហារបរិភោគ គឺមិនគ្រប់គ្រាន់ឡើយ។ ខ្ញុំហូបតែបបរដែលមានគ្រាប់អង្ករពីរបីគ្រាប់ប៉ុណ្ណោះក្នុងមួយចាន។ ដូច្នេះខ្ញុំពិតជាស្រេកឃ្លានខ្លាំងណាស់ ហើយខ្ញុំក៏មិនអាចចេញរកអាហារហូបបន្ថែមបានដែរ ព្រោះខ្លាចអង្គការចាប់យកទៅរៀនសូត្រ។ អង្គការកំណត់ឲ្យខ្ញុំហូបប៉ុណ្ណា គឺខ្ញុំត្រូវហូបប៉ុណ្ណោះ គឺមិនអាចតវ៉ាប្តុយកលើសបានឡើយ។

នៅពេលអង្គការប្រញឹកប្រមូលផល គឺតម្រូវឲ្យកងចល័តធ្វើការទាំងយប់ទាំងថ្ងៃមិនឲ្យសម្រាកឡើយ ហើយក៏មិនបានបន្ថែមរបបអាហារឲ្យខ្ញុំដែរ គឺខ្ញុំនៅតែឲ្យហូបតែបបរបន្តិចបន្តួចប៉ុណ្ណោះ។ បន្ទាប់មកដោយសារតែបរិភោគមិនគ្រប់គ្រាន់ និងធ្វើការងារហួសកម្លាំងបានធ្វើឲ្យខ្ញុំធ្លាក់ខ្លួនឈឺ ប៉ុន្តែអង្គការបែរជាសង្ស័យខ្ញុំថាធ្វើពុតជាឈឺទៅវិញ។ អង្គការមិនឲ្យខ្ញុំឈប់សម្រាកព្យាបាលឡើយ ដូច្នេះខ្ញុំត្រូវតែបន្តទៅធ្វើការដូចសព្វមួយដង។ ខ្ញុំឈឺទើបធ្វើការឲ្យអង្គការយឺត ក៏ត្រូវបានប្រធានកងវាយពីក្រោយបណ្តាលឲ្យខ្ញុំដួល។

រឿងដែលខ្ញុំសោកស្តាយបំផុតក្នុងរបបខ្មែរក្រហម គឺកូនតូចៗរបស់ខ្ញុំចំនួន៣នាក់ក្នុងនោះមានកូនប្រុស២នាក់ស្រី១នាក់ បានស្លាប់ដោយសារគ្មានអាហារបរិភោគគ្រប់គ្រាន់។ វាជារឿងឈឺចាប់ណាស់សម្រាប់ខ្ញុំដែលជាម្តាយ ដែលត្រូវបាត់បង់កូនជាទីស្រឡាញ់ម្តងដល់ទៅ៣នាក់បែបនេះ។ វាពិតជាតក់ស្លុត និងពិបាកទទួលយកនូវការឈឺចាប់នេះណាស់។ ប៉ុន្តែទោះបីជាខ្ញុំបាត់បង់កូនយ៉ាងណាក្តី ក៏ខ្ញុំត្រូវតែបង្ខំចិត្តទៅធ្វើការដូចរាល់ថ្ងៃទាំងភាពឈឺចាប់ ព្រោះតែភ័យខ្លាចអង្គការយកទៅធ្វើទារុណកម្ម ដោយចោទថាគេចវេសពីការងារ។

រហូតមកដល់សព្វថ្ងៃ សុខភាពរបស់ខ្ញុំមិនសូវរឹងមាំទេ ខ្ញុំប្រែមកស្គមស្គាំងព្រោះពិបាកចិត្តរឿងកូនស្លាប់ និងគ្មានអាហារបរិភោគគ្រប់គ្រាន់តាំងពីពេលនោះមក។ ពេលនោះខ្ញុំរស់នៅដូចជាស្លាប់អញ្ចឹង ព្រោះវាវេទនាគ្មានពាក្យថ្លែង។ ក្រោយពេលប្រទេសទទួលបានសន្តិភាពពេញលេញ ខ្ញុំក៏ត្រឡប់មកភូមិកំណើតវិញ ហើយចាប់ផ្តើមធ្វើស្រែដើម្បីចិញ្ចឹមគ្រួសារ។ ចំណែកប្តីរបស់ខ្ញុំបានស្លាប់ដោយសាររោគមនុស្សចាស់អស់រយៈពេល១០ឆ្នាំមកហើយ ហើយខ្ញុំត្រូវរស់នៅចិញ្ចឹមកូនរហូតរៀបការអស់ ។



សិស្សវិទ្យាល័យ ឈីនលាន ហាន់ជ័យ ចុះស្រាវជ្រាវលើប្រធានបទស្តីពី «កងចល័តវ័យកណ្តាលក្នុងរបបខ្មែរក្រហម»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





# វេទិកាអន្តរជំនាន់ស្ដីពី «ជំនឿនិងប្រវត្តិសាស្ត្រ» នៅវត្តពោធិ៍មានបុណ្យ ឃុំដង្កៀបក្ដាម ស្រុកបាកាន ខេត្តពោធិ៍សាត់

**ស្រិន លាងឈី**



សិស្សវិទ្យាល័យ ឈីនលាន ហាន់ជ័យ ចុះស្រាវជ្រាវលើប្រធានបទស្ដីពី «ជំនឿ និងប្រវត្តិសាស្ត្រ» នៅវត្តពោធិ៍មានបុណ្យ ឃុំដង្កៀបក្ដាម ស្រុកបាកាន ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អ្នកស្រាវជ្រាវវ័យក្មេង ដែលជាអ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាម បានចូលរួមវេទិកាអន្តរជំនាន់ស្ដីពី «ជំនឿ និងប្រវត្តិសាស្ត្រ» នៅវត្តពោធិ៍មានបុណ្យ ឃុំដង្កៀបក្ដាម ស្រុកបាកាន ខេត្តពោធិ៍សាត់ ដោយមានការអញ្ជើញចូលរួមចែករំលែកបទពិសោធន៍រឿងរ៉ាវក្នុងរបបខ្មែរក្រហមពីព្រះចៅអធិការវត្តពោធិ៍មានបុណ្យ ព្រះនាម សីលក្ខុ មុន្នី សំរិទ្ធិន ព្រះជន្មាយុ៩២ព្រះវស្សា។

វេទិកាអន្តរជំនាន់នេះ គឺផ្នែកមួយក្នុងកម្មវិធីសិក្សាស្រាវជ្រាវនៃទស្សនកិច្ចសិក្សាអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យសម្រាប់យុវជន ផ្ដោតលើការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី៣ ក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) និងធ្វើឡើងក្នុងគោលបំណងដើម្បីអនុញ្ញាតឲ្យអ្នកស្រាវជ្រាវវ័យក្មេងបានស្ដាប់បទ

ពិសោធន៍ និងសាច់រឿងផ្ទាល់របស់ព្រះចៅអធិការដែលធ្លាប់ឆ្លងកាត់ក្នុងរបបខ្មែរក្រហម, ជំនឿក្នុងមូលដ្ឋានទាក់ទងប្រវត្តិសាស្ត្របុរាណក្នុងសហគមន៍ និងប្រវត្តិនៃការកកើតវត្តពោធិ៍មានបុណ្យ។

វត្តពោធិ៍មានបុណ្យ ជាវត្តដែលផ្សាភ្ជាប់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាច្រើន និងបានបង្កើតឡើងនៅឆ្នាំ១៥១២។ ដូចជាព្រឹត្តិការណ៍ទី១ គឺព្រះបាទអង្គចន្ទរាជា ព្រះអង្គយាងទៅបន់ស្រន់អធិដ្ឋាននៅទីទួលដើមពោធិ៍មានបុណ្យ បន្ទាប់ពីទទួលបានការអញ្ជើញចូលរួមការប្រកួតជល់ដំរីពីសំណាក់ស្តេចសៀម។ ក្រោយពីបន់ស្រន់រួចព្រះបាទអង្គចន្ទរាជា ក៏ទទួលបានជ័យជម្នះ។ តាមជំនឿ និងដំណាលតៗគ្នាថា ដើមពោធិ៍នៅទីទួលនេះបានងាប់អស់រយៈពេលជាច្រើនឆ្នាំមកហើយ តែក្រោយមកក៏លូតលាស់ឡើងវិញ។ ការងាប់ និងលាស់ឡើងវិញនៃដើមពោធិ៍ បានបង្កើតជាជំនឿថា រាល់ការបន់ស្រន់នៅដើមពោធិ៍ ពិតជាទទួលបាននូវអ្វីដែលយើងចង់បាន។ ព្រឹត្តិការណ៍ទី២នោះគឺការអធិដ្ឋានរបស់ឧកញ៉ា ឃ្លាំង មឿង មុនពេលលោតចូលទៅក្នុងរណ្តៅ ក្នុងគោលបំណងប្រាថ្នាការកេណ្ឌទ័ពខ្មោចមកជួយព្រះបាទចន្ទរាជា។ ដូច្នេះតាមរយៈរឿងរ៉ាវទាំងពីរនេះ ទើបប្រជាជនហៅវត្តនេះថា វត្តពោធិ៍មានបុណ្យមកដល់សព្វថ្ងៃ។

ជំនឿ និងប្រវត្តិសាស្ត្រ ៖ តើជំនឿត្រូវការការពិតប្រវត្តិសាស្ត្រដែរឬទេ? ជំនឿ និងការពិតប្រវត្តិសាស្ត្រ គឺទិដ្ឋភាពប្រទាក់ក្រឡាគ្នាដែលប្រជាជនជារឿយៗតែងតែលើកឡើង។ បូជនីយ-ស្ថានប្រវត្តិសាស្ត្រ «ឧកញ៉ា ឃ្លាំង មឿង និង លោកជំទាវ ខាន់ ខៀវ» បង្ហាញយ៉ាងច្បាស់អំពីសារសំខាន់នៃការផ្សារភ្ជាប់អំពីជំនឿ និងព្រឹត្តិការណ៍ប្រវត្តិ-សាស្ត្រនាគ្រាដែលឧកញ៉ា ឃ្លាំង មឿង រៀបចំពិធីពលីជីវិត ដើម្បីកេណ្ឌទ័ពខ្មោចឲ្យមកជួយច្បាំង។ ព្រះចៅអធិការវត្តពោធិ៍មានបុណ្យ មានសង្ឃដីកាថា «មុនពេលពលីជីវិតដោយលោតចូលរណ្តៅដើម្បីហៅទ័ពខ្មោចមកជួយច្បាំងឧកញ៉ា ឃ្លាំង មឿង បាន



ព្រះចៅអធិការវត្តពោធិ៍មានបុណ្យ មានសង្ឃដីកាទៅកាន់សិស្សវិទ្យាល័យ ឈីនលាន ហាន់ជ័យ ដែលចុះមកស្រាវជ្រាវនៅវត្តរបស់ព្រះអង្គ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មកអុជធូបបន់ស្រន់នៅទីតាំងដើមពោធិ៍ ដើម្បីសម្រេចបានភាពជោគជ័យ»។

បន្ទាប់ពីការបូជាជីវិតដើម្បីកេណ្ឌទ័ពខ្មោចឲ្យមកជួយច្បាំង និងបន្តទទួលបានជ័យជម្នះទៅលើទ័ពសៀម វីរភាព និងការលះបង់របស់ឧកញ៉ា ឃ្លាំង មឿង និងគ្រួសារ ត្រូវបានប្រជាជនរស់នៅខេត្តពោធិ៍សាត់ បន្តនិយាយជាទីមោទកភាព និងមានការផ្សារភ្ជាប់ទៅនឹងជំនឿអំពីព្រលឹងរបស់ឧកញ៉ា ឃ្លាំង មឿង បន្តថែរក្សា និងមើលសុខទុក្ខដល់កូនចៅជំនាន់ក្រោយនៅក្នុងភូមិសាស្ត្រខេត្តពោធិ៍សាត់។ ប្រជាជនជាទូទៅតែងតែទៅបន់ស្រន់សុំសេចក្តីសុខ និងឈ្វេងយល់អំពីរឿងរ៉ាវប្រវត្តិសាស្ត្រនៅក្នុងមូលដ្ឋានដែលបានកើតឡើងនៅទីនោះ។

ខាងក្រោមនេះជាការសង្ខេបសង្ឃដីកាបែករំលែកប្រវត្តិនៃការឆ្លងកាត់របបខ្មែរក្រហម និងបទពិសោធន៍របស់ព្រះចៅអធិការវត្តពោធិ៍មានបុណ្យ ព្រះនាម សីលក្ខមុន្នី សំរិទ្ធិន ផ្ទាល់ ៖

«បច្ចុប្បន្នអាត្មាភាពគង់ជាចៅអធិការវត្តពោធិ៍មានបុណ្យ ស្ថិតនៅភូមិត្នោតព្រះ ឃុំដង្កៀបក្តាម ស្រុកបាកាន ខេត្តពោធិ៍សាត់។ ស្រុកកំណើតរបស់អាត្មាភាព គឺនៅភូមិគោកណាំង ឃុំតាំងក្រសាំង

ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ អាត្មាភាពមានឪពុកឈ្មោះ ស្ដើង និងម្ដាយឈ្មោះ ឃឹម។ អាត្មាភាពមានបងប្អូនសរុបទាំងអស់ចំនួន៥នាក់ គឺមានប្រុស២នាក់ និងមានស្រី៣នាក់។ អាត្មាភាពចូលរៀននៅវត្តគង្គា ឃុំតាំងក្រសាំង រហូតដល់ថ្នាក់ទី៣ ទើបឈប់រៀន។ បន្ទាប់មក អាត្មាភាពធ្វើជាកម្មករនៅរោងម៉ាស៊ីនកិនស្រូវ។ នៅឆ្នាំ១៩៧០ អាត្មាភាពចូលបម្រើជាកងទ័ពរំដោះខ្មែរក្រហម និងត្រូវបានបញ្ជូនទៅវាយនៅសមរភូមិ៩យប់១០ថ្ងៃ។ អាត្មាភាពបន្តធ្វើជាកងទ័ពរហូតឆ្នាំ១៩៧៥។

បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ ប្រជាជនពីទីក្រុងភ្នំពេញ ត្រូវបានជម្លៀសមកកាន់តំបន់មូលដ្ឋាន និងក្រោយមកទៀត មានប្រជាជនមកពីខេត្តស្វាយរៀងត្រូវបានបន្តបញ្ជូនមកទីនេះ ចន្លោះពីឆ្នាំ១៩៧៧ ដល់ ឆ្នាំ១៩៧៨។ ប្រជាជនដែលត្រូវបានជម្លៀសមកពីខេត្តស្វាយរៀង គឺអង្គការមិនបានទុកឲ្យរស់នៅយូរនោះទេ គឺត្រូវយកទៅសម្លាប់ចោលភ្លាមៗ ទាំងឡានៗ។ អាត្មាភាពអាចនៅរស់ដល់សព្វថ្ងៃនេះ ពីព្រោះអាត្មាភាពនិយាយកុហកអង្គការថាមិនចេះអក្សរ។ នៅទីនេះអ្នកមានចំណេះដឹងត្រូវបានខ្មែរក្រហមចាប់ខ្លួនយកទៅសម្លាប់ទាំងអស់។ ចំណែកឯព្រះសង្ឃនៅវត្តអារាមផ្សេងៗ ត្រូវចាប់ផ្សឹក និងឲ្យធ្វើការដូចប្រជាជនធម្មតា។ ចំពោះការហូបចុក អាត្មាភាពហូបតែបបររាវៗក្នុងអង្ករ១កំប៉ុងហូប១២នាក់ និងត្រូវធ្វើការងារពីព្រលឹមទល់ព្រលប់។ អាត្មាភាព ត្រូវអង្គការឲ្យធ្វើជាប្រធានកងការដ្ឋានចិញ្ចឹមគោ ក្របី ជ្រូក និងមាន់ទា ដោយយកទីតាំងវត្តល្អួងជាការដ្ឋានចិញ្ចឹមសត្វ។ ក្រោយពីខ្មែរក្រហមដួលរលំ អាត្មាភាព ធ្វើស្រែចម្ការ នៅឃុំរលកស ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។ បន្ទាប់មកអាត្មាបួសជាព្រះសង្ឃនៅវត្តពោធិ៍មានបុណ្យនេះតែម្តង។ អាត្មាភាពចងចាំមិនភ្លេចថា ខ្មែរក្រហមបានដឹកមនុស្សយកមកសម្លាប់នៅក្រោយភូមិ។ អាត្មាភាពភ័យតក់ស្លុតយ៉ាងខ្លាំង។ ការសម្លាប់មនុស្សក្នុងរបបខ្មែរក្រហមគឺចាប់ផ្តើមសម្លាប់ពីម៉ោង៣ទៀបភ្លឺឡើងទៅ»។



សិស្សវិទ្យាល័យ ឈីនលាន ហាន់ជ័យ ដែលចុះស្រាវជ្រាវលើប្រធានបទស្ដីពី «ជំនឿ និងប្រវត្តិសាស្ត្រ» ស្ដាប់សង្ឃដីការបស់ព្រះចៅអធិការវត្តពោធិ៍មានបុណ្យ ស្ថិតនៅក្នុងឃុំដង្កៀបក្ដាម ស្រុកបាកាន ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកម្ពុជាចុះពិនិត្យសុខភាពបឋម និងចែករទេះរុញ

## រួមទាំងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាពនៅស្រុកកោះញែក ខេត្តមណ្ឌលគិរី

*អេង សុខម៉េង*



ក្រុមការងារសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅស្រុកកោះញែក ខេត្តរតនគិរី ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាប់ពីថ្ងៃទី១១ដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមវេជ្ជបណ្ឌិតមកពីមន្ទីរពេទ្យ ខេវីត្បូងឃ្មុំ បានរៀបចំវេទិកាពិនិត្យសុខភាព និងអប់រំអំពីការថែទាំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រមាណជាចំនួន១៩១នាក់ ក្នុងឃុំអបួនលើ ឃុំសុខសាន្ត ឃុំស្រែសង្គម ឃុំស្រែហ៊ុយ ឃុំណងឃីលិក និងឃុំរយ៉ៈ ស្ថិតនៅក្នុងស្រុកកោះញែក ខេត្តមណ្ឌលគិរី។ ទន្ទឹមនេះ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នកដែលមានពិការភាពដែរ។

ជាកិច្ចចាប់ផ្តើមមេឃុំអបួនលើ លោក ហាន សុខន បានមានប្រសាសន៍បើកវេទិកា និងស្វាគមន៍យ៉ាងកក់ក្តៅដល់ប្រជាជនដែលបានមកចូលរួមក្នុង «វេទិកាពិនិត្យសុខភាពបឋម និងអប់រំអំពីការ



ថែទាំសុខភាព» ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ លោក ហាន សុខន បន្តថា ការពិនិត្យសុខភាពមានសារសំខាន់ណាស់ ព្រោះអាចឲ្យយើងដឹងពីវិធីការពារជំងឺកាចសាហាវផ្សេងៗ។ ឆ្លៀតក្នុងឱកាសនេះដែរ លោកមេឃុំ បានផ្ដាំផ្ញើដល់អ្នកដែលបានចូលរួមវេទិកានេះ សូមជួយផ្សព្វផ្សាយបន្តដល់សាច់ញាតិ និងអ្នកជិតខាង ក៏ដូចជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដទៃទៀត ដើម្បីឲ្យគាត់ដឹងពីវិធីថែទាំសុខភាពឲ្យកាន់តែច្រើនឡើង។ ជាទីបញ្ចប់ លោកមេឃុំ បានផ្ដាំផ្ញើដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ត្រូវចេះថែរក្សាសុខភាព ហូបអាហារដែលមានជីវជាតិ និងសម្រាកឲ្យបានគ្រប់គ្រាន់ ព្រមទាំងចេះធ្វើលំហាត់ប្រាណឲ្យបានទៀងទាត់។

បន្ទាប់មកលោក ព្រុំ ដល្លា និពន្ធនាយក ឌីញូវ (D-News) ដែលផ្សព្វផ្សាយរឿងរ៉ាវរបស់អ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្ដល់នូវការចាប់អារម្មណ៍ចំពោះការថែទាំសុខភាពដោយលោកសង្កត់ធ្ងន់ថា ការពិនិត្យសុខភាពមានសារសំខាន់ណាស់ ជាពិសេសមនុស្សចាស់។ លោកបន្តថា អ្នក



ក្រុមគ្រូពេទ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចុះពិនិត្យសុខភាពបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅស្រុកកោះញែក ខេត្តរតនគិរី។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រស់រានមានជីវិតពីរបបខ្មែរក្រហមដែលមកពិនិត្យសុខភាពនៅថ្ងៃនេះ គឺធ្លាប់បានចូលរួមផ្ដល់បទសម្ភាសន៍អំឡុងឆ្នាំ២០២១ កន្លងទៅ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់ព័ត៌មានដល់អ្នកស្ម័គ្រចិត្តកម្ពុជា នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីអាចឲ្យអ្នកស្ម័គ្រចិត្តកត់ត្រាប្រវត្តិរឿងរ៉ាវពីរបបខ្មែរក្រហមទុកជាឯកសារ សម្រាប់ក្មេងៗជំនាន់ក្រោយបានសិក្សាស្រាវជ្រាវបន្តទៀត។





ក្រុមគ្រូពេទ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចុះពិនិត្យសុខភាពបឋមជូនព្រះសង្ឃ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកោះញែក ខេត្តរតនគិរី។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តមកវេជ្ជបណ្ឌិត ឡាវ ហាវ៉ាន ប្រធានផ្នែកសង្គ្រោះបន្ទាន់ នៃមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ខេត្តត្បូងឃ្មុំ មានប្រសាសន៍ក្នុងវេទិកាអប់រំពីសុខភាពបន្ទាប់ពីពិនិត្យជំងឺបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមថា ការពិនិត្យសុខភាពមានសារសំខាន់បំផុតសម្រាប់អ្នកជំងឺ។ ការពិនិត្យរកឃើញជំងឺទាន់ពេលវេលា គឺជាជំនួយដើម្បីអាចឲ្យគ្រូពេទ្យមានលទ្ធភាពព្យាបាលអ្នកជំងឺឲ្យបានជោគជ័យ ត្រឹមត្រូវ និងមិនយឺតពេល។ វេជ្ជបណ្ឌិត ឡាវ ហាវ៉ាន បន្ថែមថា អ្នកជំងឺដែលមានសម្ពាធឈាមលើសត្រូវតាមដានសម្ពាធឈាមឲ្យបានញឹកញាប់ដើម្បីដឹងពីសម្ពាធឈាមខ្លួនឯង ងាយស្រួលគ្រប់គ្រង និងត្រូវលេបថ្នាំជាប្រចាំទោះបីសម្ពាធឈាមបានចុះក៏ដោយ។ វេជ្ជបណ្ឌិត ឡាវ ហាវ៉ាន ក៏បានផ្ដាំផ្ញើ យាយ តា អ៊ំ ពូ មីង ទាំងអស់ត្រូវពិសាអាហារដែលមានរសជាតិសាប ឬអាហារដែលមានរសជាតិប្រៃល្មមចៀសវាងអាហារដែលមានរសជាតិប្រៃ និងផ្អែមខ្លាំងៗ រសជាតិផ្អែម និងប្រៃខ្លាំង អាចនាំឲ្យ យាយ តា អ៊ំ ពូ មីង ប្រឈមមុខនឹងជំងឺលើសសម្ពាធឈាម ទឹកនោមផ្អែម ទឹកនោមប្រៃ និងជំងឺផ្សេងៗទៀត។

នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ គឺជាកម្មវិធីពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៧០នាក់ បន្ថែមទៀតពីវេជ្ជបណ្ឌិតចំនួនបីរូប គឺ វេជ្ជបណ្ឌិត ឡាវ ហាវ៉ាន វេជ្ជបណ្ឌិត ឡុង ដាវ៉ា វេជ្ជបណ្ឌិត កែវ គឹមស្រួ ព្រមទាំងគិលានុបដ្ឋាយិកាចំនួនបីរូបគឺ អ្នកគ្រូពេទ្យ អ៊ូ បញ្ញា អ្នកគ្រូពេទ្យ ថន ម៉ារី និងអ្នកគ្រូពេទ្យ នឿន សុខរ៉ែន នៃមន្ទីរពេទ្យខេវីត្បូងឃ្មុំ។ បន្ទាប់ពីវេទិកាពិនិត្យសុខភាព គឺមានវេទិកាអប់រំពីសារសំខាន់នៃការថែទាំសុខភាព។

នៅក្នុងឱកាសនោះ វេជ្ជបណ្ឌិត ឡុង ដាវ៉ា បានមានប្រសាសន៍នៅក្នុងវេទិកាអប់រំអំពីសុខភាពថា ប្រភេទជំងឺនៅថ្ងៃនេះរួមមានជំងឺលើសឈាម និងជំងឺទឹកនោមផ្អែមមានចំនួនច្រើនជាងប្រភេទជំងឺដទៃដូចទៅនឹងថ្ងៃទី១ដែរ។ បន្ទាប់មក គឺជំងឺឈឺសន្លាក់ដៃជើង និងជំងឺបន្ទាប់បន្សំផ្សេងៗទៀត។ វេជ្ជបណ្ឌិត ឡុង ដាវ៉ា បន្តថា ជំងឺលើសសម្ពាធឈាមគឺបណ្ដាលមកពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមកពិនិត្យសុខភាព គឺភាគច្រើននិយមចូលចិត្តហូបប្រៃដោយមិនដឹងខ្លួន ដូចជា ការហូបផ្អកប្រហុក និងត្រីងៀត ជាដើម ហើយនៅស្ទើរតែគ្រប់ផ្ទះមានពាងសម្រាប់ផ្អកអាហារផ្អាប់ទាំងអស់នេះ។ វេជ្ជបណ្ឌិត ឡុង ដាវ៉ា បន្តថា យោងតាមរបាយការណ៍ពីអង្គការសុខភាពពិភពលោក បង្ហាញថា មនុស្សម្នាក់ត្រូវការអំបិលប្រហែល១ស្លាបព្រាកាហ្វេ និងស្ករប្រហែល៥ស្លាបព្រាកាហ្វេប៉ុណ្ណោះក្នុងមួយថ្ងៃសម្រាប់ជាអាហាររូបត្ថម្ភដែលត្រឹមត្រូវសម្រាប់សុខភាពរូបរាងកាយ។ វេជ្ជបណ្ឌិត ឡុង ដាវ៉ា

បន្ថែមថា សម្ពាធឈាមដែលត្រឹមត្រូវសម្រាប់មនុស្សទូទៅគឺ១៤ និងកម្រិតស្ករ គឺចន្លោះពី ៩០-១២០ (សម្រាប់ការពិនិត្យដែលមិនទាន់ទទួលទានអាហារ) កម្រិតលើសពីនេះ គឺជារោគសញ្ញា ឬជំងឺលើសសម្ពាធឈាម និងជំងឺទឹកនោមផ្អែម។ ពេលពិនិត្យឃើញកម្រិតដូចខាងលើ គ្រូពេទ្យ នឹងណាត់អ្នកជំងឺជួបដើម្បីពិនិត្យម្តងទៀត ប្រសិនបើកម្រិតស្ករ និងសម្ពាធឈាមដូចឬលើសពីលើកទី១ គ្រូពេទ្យនឹងណែនាំអ្នកជំងឺឲ្យលេបថ្នាំ។ សូមបញ្ជាក់ថា ជំងឺលើសឈាម និងជំងឺទឹកនោមផ្អែមមិនអាចព្យាបាលឲ្យជាសះស្បើយបានទេ គឺអ្នកជំងឺត្រូវលេបថ្នាំដើម្បីរក្សាកម្រិតស្ករ និងកម្រិតឈាមកុំឲ្យប្រែប្រួលខ្លាំងប៉ុណ្ណោះ ហើយត្រូវលេបថ្នាំពេញមួយជីវិត។

នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤ ដែលថ្ងៃចុងក្រោយនៃវេទិកាពិនិត្យសុខភាព និងអប់រំអំពីសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា បានចែករទេះរុញចំនួន១០គ្រឿង និងកាសជំនួយត្រចៀកចំនួន ៨ ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាពរស់នៅក្នុងស្រុកកោះញែក ខេត្តមណ្ឌលគិរី។ ការចែករទេះរុញ និងកាសជំនួយត្រចៀក គឺដើម្បីជួយសម្រាលការលំបាកក្នុងការធ្វើដំណើរប្រចាំថ្ងៃ និងទំនាក់ទំនងជាមួយកូនចៅនៅក្នុងគ្រួសារ។



ក្រុមការងារសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅស្រុកកោះញែក ខេត្តរតនគិរី ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងសហការជាមួយរដ្ឋបាលស្រុកអន្លង់វែង ចែករទេះរុញ

## ចំនួន១៦គ្រឿង ជូនដល់ប្រជាជនដែលមានពិការភាពនៅភូមិជើងភ្នំ

លី សុខឃាង



ក្រុមការងារសុខភាពរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង សហការជាមួយរដ្ឋបាលស្រុកអន្លង់វែង មានកិត្តិយសផ្តល់រទេះរុញចំនួន១៦គ្រឿង ជូនដល់ប្រជាជនចំនួន១៦នាក់ដែលមានពិការភាពដោយសារសង្គ្រាម ឬពីកំណើតនៅភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤។ កម្មវិធីនៃការចែកជូនរទេះរុញនេះត្រូវបានធ្វើឡើងដើម្បីសម្រាលបន្ទុក និងជួយរំលែកការលំបាកនៃការបម្លាស់ទីសម្រាប់ការងារនិងការរៀនសូត្រ លើកកម្ពស់ការចូលរួមរបស់ជនមានពិការភាពនៅក្នុងកិច្ចការសង្គមផ្សេងៗប្រកបដោយភាពស្មើភាពគ្នា និងគាំទ្រដល់បរិយាសសង្គមដែលគ្មានការរើសអើងចំពោះជនមានពិការភាព។

ការផ្តល់ជូនរទេះរុញដល់ជនមានពិការភាពនៅភូមិជើងភ្នំ នៃស្រុកអន្លង់វែង គឺជាកាយវិការមនុស្សធម៌ ដោយសារតែផលវិបាកនៃសង្គ្រាមនិង

យុទ្ធភណ្ឌមិនទាន់ផុះ។ ស្រុកអន្លង់វែងត្រូវបានស្គាល់ជាទូទៅថាជាតំបន់តស៊ូចុងក្រោយបង្អស់នៃចលនាខ្មែរក្រហម ដែលបានធ្វើសមាហរណកម្មចូលក្នុងរាជរដ្ឋាភិបាលកម្ពុជានៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨។ ប្រជាជនជាច្រើននៅក្នុងសហគមន៍បានប្រឈមមុខនឹងស្លាកស្នាមរបួស ទាំងផ្នែករាងកាយ និងស្មារតី។

កម្មវិធីចែកជូនរទេះរុញដល់ជនមានពិការភាពត្រូវបានធ្វើឡើងជាលើកដំបូងនៅភូមិជើងភ្នំ ដោយសារតែភូមិនេះត្រូវបានកំណត់ថា ជាភូមិជនពិការក្នុងរយៈកាលនៃការតស៊ូប្រដាប់អាវុធខ្មែរក្រហមចន្លោះឆ្នាំ១៩៧៩ ដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨។ នៅពេលនោះ អ៊ុង ជឿន ឬត្រូវស្គាល់ជាទូទៅថាជា តាម៉ុក ដែលបានដឹកនាំចលនាខ្មែរក្រហមនៅអន្លង់វែង បានកំណត់ឲ្យជនមានពិការភាពទាំងអស់រស់នៅភូមិជើងភ្នំ ដែលមានទីតាំងជាប់ជើងភ្នំដងរែកនៃស្រុកអន្លង់វែង។ តាម៉ុក បានយល់ឃើញថា នៅពេលមានការវាយប្រហារប្រដាប់អាវុធពីសំណាក់កងកម្លាំងរបស់រាជរដ្ឋាភិបាលកម្ពុជា ជនមានពិការភាពទាំងអស់អាចចល័ត និងគេចខ្លួនឡើងទៅលើភ្នំដងរែក។ សព្វថ្ងៃនេះ ជនមានពិការភាពជាច្រើនបន្តរស់នៅក្នុងភូមិជើងភ្នំនេះ ហើយប្រកបរបរចិញ្ចឹមជីវិតដោយធ្វើស្រែចម្ការផ្សេងៗ។







ក្រុមការងារសុខភាពរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ចែករទេះរុញ និងកាសជំនួយត្រចៀកជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកម្ពុជា និងមន្ទីរពេទ្យ INTER CARE ប្រគល់សម្ភារបរិក្ខារពេទ្យ ជូនដល់មន្ទីរពេទ្យយោធានៃកងពលតូចថ្មើរជើងលេខ ៣១

*រស់ សំពៅ*



ឯកឧត្តម ឧត្តមសេនីយ៍ឯក យឿង សុខុន មេបញ្ជាការយោធភូមិភាគ៣ ប្រគល់បណ្ណសរសើរជូនមជ្ឈមណ្ឌលឯកសារកម្ពុជា និងមន្ទីរពេទ្យ INTER CARE ដែលបានផ្តល់សម្ភារបរិក្ខាពេទ្យ ជូនមន្ទីរពេទ្យយោធានៃកងពលតូចថ្មើរជើងលេខ៣១។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារកម្ពុជា និង មន្ទីរពេទ្យ INTER CARE បានប្រគល់សម្ភារបរិក្ខារពេទ្យ ជូនដល់មន្ទីរពេទ្យយោធានៃកងពលតូចថ្មើរជើងលេខ៣១ ស្ថិតនៅក្នុងឃុំប្រេស ស្រុកជុំគិរី ខេត្តកំពត ក្រោមអធិបតីភាពឯកឧត្តម ឧត្តមសេនីយ៍ឯក យឿង សុខុន មេបញ្ជាការយោធភូមិភាគទី៣ និង ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាម ហ៊ិ មេបញ្ជាការរងកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ។

នៅក្នុងកម្មវិធីប្រគល់សម្ភារបរិក្ខារពេទ្យនេះ ក៏មានការចូលរួមពីសំណាក់លោកគ្រូអ្នកគ្រូ ក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យយោធា និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រមាណជាង៩០នាក់។ គោលបំណងក្នុងការប្រគល់សម្ភារបរិក្ខារពេទ្យទៅដល់មន្ទីរពេទ្យយោធានៃកងពលតូចថ្មើរជើងលេខ ៣១ គឺដើម្បីចូលរួមចំណែកថែទាំសុខភាពរបស់កងទ័ពដែលកំពុងប្រចាំការនៅតាមអង្គភាព ប្រជាជនក្នុងសហគមន៍ និងជាពិសេសអ្នករស់រានមានជីវិត

ពីរបបខ្មែរក្រហមដែលមានវ័យចាស់ជរា ហើយកំពុងប្រឈមនឹងបញ្ហាសុខភាពធ្ងន់ធ្ងរៗ នៅក្នុងឱកាសនោះដែរ លោក រស់ សំពៅ តំណាងមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានចែកអាវយឺត និងថង់យាម ជូនតា យាយ អ៊ំ ពូ មីង ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម លោកគ្រូអ្នកគ្រូ និងក្រុមគ្រូពេទ្យមន្ទីរពេទ្យយោធានៃកងពលតូចថ្មើរជើងលេខ៣១ ដែលបានអញ្ជើញចូលរួមក្នុងពិធីនេះ។

នៅចុងបញ្ចប់នៃកម្មវិធីឯកឧត្តមឧត្តមសេនីយ៍ឯក យឿង សុខុន មេបញ្ជាការយោធភូមិភាគទី៣ នៃកងយោធពលខេមរភូមិន្ទ ឡើងសម្តែងការអរគុណ និងប្រគល់លិខិតថ្លែងអំណរគុណជូនដល់មន្ទីរពេទ្យ INTER CARE និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានជួយឧបត្ថម្ភនូវសម្ភារបរិក្ខារពេទ្យសម្រាប់មន្ទីរពេទ្យនៃកងពលតូចថ្មើរជើងលេខ៣១។

បន្ទាប់ពីចប់កម្មវិធី ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាម ហ៊ា មេបញ្ជាការរងកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ បានអញ្ជើញទៅទស្សនាអគារសហគមន៍ភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត ដែលសាងសង់ឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់ប្រជាជននៅក្នុងសហគមន៍ពិសេសអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មកជួបជុំគ្នាដើម្បីប្រជុំពិភាក្សា ទាក់ទងនឹងបញ្ហាសុខភាព និងនិយាយរៀបរាប់អំពីរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម។





មជ្ឈមណ្ឌលឯកសារកម្ពុជា និងមន្ទីរពេទ្យ INTER CARE ផ្តល់សម្ភារបរិក្ខាពេទ្យ ជូនមន្ទីរពេទ្យយោធានៃកងពលតូចថ្មើរជើងលេខ៣១ យោធភូមិភាគ៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលឯកសារកោះថ្ម ចែករទេះរុញ និងកាសជំនួយត្រចៀកជូនអ្នកដែលមានពិការភាព

## នៅភូមិសាទុំ ភូមិម្កោរថ្មី និងភូមិក្តុលលើ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ

*ឈុំ វ៉ា និង ទី ស៊ីថា*




ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីថ្ងៃទី១២ ដល់ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤ លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម និងក្រុមការងារ សហការជាមួយអាជ្ញាធរភូមិ បានរៀបចំកម្មវិធីចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពចំនួន៤នាក់ ក្នុងនោះមានស្ត្រីដែលមានពិការភាពម្នាក់ រស់នៅក្នុងភូមិសាទុំ ភូមិម្កោរថ្មី និងភូមិក្តុលលើ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

បន្ទាប់ពីទទួលបានរទេះរុញ និងកាសជំនួយការស្តាប់ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពបានបង្ហាញចំណាប់អារម្មណ៍ផ្ទាល់ខ្លួនដូចខាងក្រោម ៖

### យិន សាន

ខ្ញុំឈ្មោះ យិន សាន ភេទប្រុស អាយុ៨៧ឆ្នាំ បច្ចុប្បន្នរស់នៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ យិន និងម្តាយឈ្មោះ ញ៉ែន។ ឪពុកម្តាយខ្ញុំបានស្លាប់អស់ហើយ។ ខ្ញុំមានបងប្អូនចំនួនពីរនាក់ ហើយខ្ញុំគឺជាកូនទីមួយ ចំណែកប្អូនស្រីជាកូនទីពីរមានឈ្មោះ យិន សារិន។ ខ្ញុំរៀបការប្រពន្ធ និងមានកូនពីរនាក់ គឺស្រីម្នាក់ និង

ប្រុសម្នាក់ៗ សព្វថ្ងៃខ្ញុំរស់នៅជាមួយកូនស្រីពៅ។ រទេះរុញនេះពិតជាមានសារសំខាន់បំផុតសម្រាប់ខ្ញុំ និងក្រុមគ្រួសារ។ ខ្ញុំពិការជើងតាំងពីសម័យសង្គ្រាម ហើយធ្វើឲ្យប៉ះពាល់ដល់ជីវភាពគ្រួសារ ព្រោះខ្ញុំមិនអាចចេញទៅធ្វើការងារដូចជាមនុស្សទូទៅបាន ណាមួយគ្មានអ្នកណាជួលធ្វើការងារឡើយ។ តាំងពីរូបខ្ញុំនៅមានកម្លាំង ក៏ពុំសូវមានអ្នកជួល ណាមួយមនុស្សពិការដូចខ្ញុំមិនអាចធ្វើការងារធ្ងន់ៗ ហើយគ្មានចំណេះដឹងទៀត។ នេះជាបន្ទុកធ្ងន់ដល់គ្រួសារខ្ញុំ ម្យ៉ាងទៀត គ្រួសារបានចំណាយពេលជាមួយរូបខ្ញុំធ្វើឲ្យខាតពេលវេលា។ ខ្ញុំពិការជើងខាងឆ្វេង និងងងឹតភ្នែកទាំងសងខាងរយៈពេល៥ឆ្នាំមកហើយ។ ពេលខ្ញុំទទួលបានរទេះរុញ ខ្ញុំអាចធ្វើដំណើរទៅលេងញាតិមិត្តបងប្អូននៅក្នុងភូមិ ពីព្រោះមួយរយៈពេលកន្លងមក ខ្ញុំមិនដែលបានទៅណាមកណាទេ។ ចំពោះសុខភាពខ្ញុំរាល់ថ្ងៃមិនប្រសើរទេ ខ្ញុំមានជំងឺជាប្រចាំ ព្រោះរាងកាយទ្រុឌទ្រោម និងអាយុច្រើន។ ដោយសារតែសង្គ្រាម និងសម័យខ្មែរក្រហមធ្វើឲ្យខ្ញុំពិបាក ហើយរាល់ថ្ងៃខ្ញុំគិតច្រើនណាស់។ ខ្ញុំពិតជាត្រេកអរ និងសប្បាយចិត្តដែលមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់រទេះរុញដល់ខ្ញុំជាជនពិការ និងងងឹតភ្នែកទាំងសងខាង។ ខ្ញុំគ្មានអ្វីក្រៅពីអរគុណទៅដល់ក្រុមការងារ និងមជ្ឈមណ្ឌលឯកសារកោះថ្មនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលយករទេះរុញមកជូនខ្ញុំដោយផ្ទាល់ទេ។ ខ្ញុំសូមជូនពរក្រុមការងារមានសេចក្តីសុខចម្រើន ទទួលបានពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## ឯម ប៉ាន់

ខ្ញុំឈ្មោះ ឯម ប៉ាន់ ភេទប្រុស អាយុ៨៤ឆ្នាំ មានស្រុកកំណើតនៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំរស់នៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ឯម ឡិប និងម្តាយឈ្មោះ ឡុក ឈុន។ ខ្ញុំមានបងប្អូនបង្កើតចំនួន៦នាក់ គឺស្រីចំនួន២នាក់ និងប្រុសចំនួន៤នាក់។ ប្រពន្ធរបស់ខ្ញុំឈ្មោះ ខ្វាន់ សៀង។ ខ្ញុំមានកូនទាំងអស់ចំនួន៩នាក់ គឺស្រីចំនួន៣នាក់ និងប្រុសចំនួន៦នាក់។ ខ្ញុំពិតជាសប្បាយចិត្តជាខ្លាំង និងពេញចិត្តចំពោះកាសជំនួយត្រចៀក ព្រោះខ្ញុំចាប់ផ្តើមស្តាប់មិនឮអស់រយៈពេល៦ឆ្នាំមកហើយ ប៉ុន្តែរយៈពេល២ឆ្នាំដំបូងអាចស្តាប់បានទាល់និយាយខ្លាំងៗ។ កាលពីដើមខ្ញុំគឺជាអាចារ្យនៅវត្តភូមិសាទុំ ឃុំជាំក្រវៀន។ រយៈពេល៤ឆ្នាំចុងក្រោយនេះ ខ្ញុំមិនដែលបានទៅវត្តស្តាប់ព្រះធម៌ទេ ពីព្រោះស្តាប់មិនឮ ប្រៀនដូចជាមនុស្សមិនដឹងអីទាំងអស់។ បន្ទាប់ពីបានកាសជំនួយត្រចៀក ខ្ញុំនឹងទៅវត្តបន្តទៀតដើម្បីសូត្រធម៌ និងស្តាប់ព្រះសង្ឃទេសនា។ សម្រាប់កាសជំនួយត្រចៀកនេះវាពិតជាមានសារសំខាន់សម្រាប់ខ្ញុំខ្លាំងណាស់ មិនពិបាកចិត្តក្នុងការសន្ទនាជាមួយកូនចៅញាតិមិត្ត។ ពីមុនទាល់និយាយខ្លាំងៗទើបខ្ញុំស្តាប់ឮ ម្យ៉ាងទៀតខ្ញុំខ្លាចរំខានដល់អ្នកជុំវិញខ្លួន ហើយពេលខ្លះកូនចៅក៏ធុញចំពោះខ្ញុំខ្លះដែរ។ កូនចៅ ទៅធ្វើការងារមកពីហត់ ហើយត្រូវមកពិបាកក្នុងការសន្ទនាជាមួយមនុស្សថ្លង់ដូចជាខ្ញុំទៀត។ ខ្ញុំសូមថ្លែងអំណរគុណចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមការងារទាំងអស់បានផ្តល់កាសជំនួយត្រចៀកដល់រូបខ្ញុំ។ អរគុណសម្រាប់ការយកចិត្តទុកដាក់ដល់ជនពិការ និងមនុស្សចាស់ជរា។ ខ្ញុំសូមជូនពរក្រុមការងារទាំងអស់ជួបសំណាងល្អ ជោគជ័យគ្រប់ភារៈកិច្ច និងមានសុខភាពល្អគ្រប់ៗគ្នា។

## ប៉ូញ ទុំ

ខ្ញុំឈ្មោះ ប៉ូញ ទុំ ភេទស្រី អាយុ៧១ឆ្នាំ មានស្រុកកំណើតនៅភូមិចង្កុកណ្តាល ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំនៅភូមិម្កោរថ្មី ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានម្តាយឈ្មោះ ភិន (ស្លាប់នៅក្នុងរបប ប៉ុល ពត) ចំណែកឪពុកឈ្មោះ ប៉ូញ (ស្លាប់នៅក្នុងរបប ប៉ុល ពត)។ ខ្ញុំមានប្តីឈ្មោះ សែម កែម និងមានកូនចំនួន៧នាក់ គឺប្រុសចំនួន៤នាក់ និងស្រីចំនួន៣នាក់។ កូនរបស់ខ្ញុំម្នាក់បានស្លាប់ដោយសារក្អួតៗរហូតដល់ស្លាប់។ ខ្ញុំសូមអរគុណដល់ក្រុមការងារទាំងអស់គ្នាដែលផ្តល់

ការសង្គ្រោះជួយត្រចៀកដល់ខ្ញុំជាមនុស្សថ្លង់ និងងងឹតភ្នែក។ ខ្ញុំពិតជាសប្បាយចិត្តខ្លាំងណាស់ ព្រោះខ្ញុំអាចស្តាប់ឮដូចកាលពីមុន។ អារម្មណ៍មនុស្សថ្លង់តែងតែប្រែប្រួលជានិច្ច ដោយសារការស្តាប់មិនឮ ហើយចេះតែតូចចិត្តដែលគ្រួសារមិនសូវយកចិត្តទុកដាក់ចំពោះខ្លួន។ ខ្ញុំថ្លង់ត្រចៀករយៈពេលយូរឆ្នាំហើយ ប៉ុន្តែឥឡូវមានការសង្គ្រោះជួយត្រចៀកធ្វើឲ្យខ្ញុំអាចស្តាប់ឮឡើងវិញ ប្រៀបដូចជារស់ម្តងទៀត។ ខ្ញុំស្តាប់មិនឮ ខ្ញុំមិនមានអារម្មណ៍ល្អទេ ហើយពេលខ្លះកូនចៅនិយាយល្អ តែខ្ញុំយល់ខុស។ កាលពីប៉ុន្មានថ្ងៃមុននេះ ខ្ញុំឈឺរហូតដាំបាយមិនកើត ទើបហៅប្អូននៅខាងកើតផ្ទះមកជួយដាំបាយឲ្យ។ ចុងក្រោយខ្ញុំចង់បានរបស់ហូបចុក ពីព្រោះខ្ញុំមិនអាចដើរទៅណាមកណាបាន ព្រោះងងឹតភ្នែក និងថ្លង់។

**ម៉ៅ ជិន**

ខ្ញុំឈ្មោះ ម៉ៅ ជិន ភេទប្រុស អាយុ៩០ឆ្នាំ មានទីកន្លែងកំណើតនៅភូមិយក្រីម ឃុំយក្រីម ស្រុកស្នួល ខេត្តក្រចេះ។ ខ្ញុំមានឪពុកឈ្មោះ ជិន និងម្តាយឈ្មោះ ផាន់ (ស្លាប់ដោយសារជំងឺ)។ ខ្ញុំមានបងប្អូនប្រុស ២នាក់ ប៉ុន្តែប្អូនខ្ញុំស្លាប់តាំងពីឆ្នាំ១៩៩៤។ ខ្ញុំចាប់ផ្តើមថ្លង់ និងញ័រសរសៃនៅឆ្នាំ២០២០ បើគិតទៅមានរយៈពេល៥ឆ្នាំហើយ។ ខ្ញុំពិតជាពិបាករស់នៅណាស់ ព្រោះពេលកូនចៅនិយាយ ខ្ញុំស្តាប់មិនឮ ពិបាកក្នុងចិត្តដេកចាំតែថ្ងៃស្លាប់។ ថ្ងៃនេះ ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយជាខ្លាំង ដែលក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ការសង្គ្រោះជួយត្រចៀកដល់រូបខ្ញុំ។ ខ្ញុំពិតជាត្រេកអរខ្លាំងណាស់ ដែលអាចស្តាប់ឮដូចកាលពីមុនវិញ ព្រោះខ្ញុំស្តាប់មិនឮរយៈពេល៤ឆ្នាំមកហើយ។ ប៉ុន្តែពេលនេះ ខ្ញុំអាចឮ និងអាចនិយាយជាមួយកូនចៅក្នុងគ្រួសារ និងបងប្អូនញាតិមិត្តរស់នៅក្នុងភូមិបាន។ ការសង្គ្រោះជួយត្រចៀកនេះអាចឲ្យខ្ញុំមានទំនាក់ទំនងប្រចាំថ្ងៃជាមួយអ្នកនៅជុំវិញខ្លួនបានល្អប្រសើរ។ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានផ្តល់ការសង្គ្រោះជួយត្រចៀកមកដល់រូបខ្ញុំ។







ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចែករទេះរុញ និងការសង្គ្រោះជួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកោះថ្ម គោរពវិញ្ញាណក្ខន្ធ និងដាក់កម្រងផ្កាជាការចងចាំ និងដឹងគុណ

## ចំពោះយុទ្ធជនដែលបានពលីជីវិត ដើម្បីបុព្វហេតុជាតិ និងសង្គ្រោះអាយុជីវិតប្រជាជនប្រមាណ ៥លាននាក់ ឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅមហាចេតិយ តំបន់ប្រវត្តិសាស្ត្រយោធាតេជោ កោះថ្ម អ៊ិច-១៦

*ឈុំ រ៉ា*



ពិធីគោរពវិញ្ញាណក្ខន្ធ និងដាក់កម្រងផ្កាជាការចងចាំ និងដឹងគុណចំពោះយុទ្ធជនដែលបានពលីជីវិត ដើម្បីបុព្វហេតុជាតិ និងសង្គ្រោះអាយុជីវិតប្រជាជនប្រមាណ៥លាននាក់ឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ប៉ុល ពត នៅមហាចេតិយតំបន់ប្រវត្តិសាស្ត្រយោធាតេជោ កោះថ្ម អ៊ិច-១៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង៨កន្លះព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤ លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្មបានដឹកនាំក្រុមការងារចូលរួមគោរពវិញ្ញាណក្ខន្ធ និងដាក់កម្រងផ្កាជាការចងចាំ និងដឹងគុណចំពោះយុទ្ធជនដែលបានពលីជីវិតដើម្បីបុព្វហេតុជាតិ និងមាតុភូមិ សង្គ្រោះអាយុជីវិតប្រជាជនប្រមាណ៥លាននាក់ឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ប៉ុល ពត នៅមហាចេតិយតំបន់ប្រវត្តិសាស្ត្រយោធាតេជោ កោះថ្ម អ៊ិច-១៦។

ក្នុងការរំដោះប្រទេសជាតិចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ធ្វើឲ្យកងកម្លាំងប្រដាប់អាវុធសង្គ្រោះជាតិកម្ពុជាចំនួន៤៩រូប បានពលីនៅអំឡុងពេលវាយប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហមមានជំងឺ និងបាត់បង់អាយុជីវិតនៅពេលកំពុងហ្វឹកហាត់យុទ្ធសាស្ត្រកងទ័ពនៅតំបន់ឡុងយ៉ាវ ប្រទេសវៀតណាម ចន្លោះពីថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ សពរបស់យុទ្ធជនពលីកម្ពុជាត្រូវបានបញ្ចុះនៅចន្លោះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ស្ថិតនៅភូមិសួសរ៉ាំ ឃុំឡុងយ៉ាវ ស្រុកកាំមី ខេត្តដុងណាយ ប្រទេសវៀតណាម។

នៅព្រឹកថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២ ផ្នូរសពយុទ្ធជនកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា ទាំង៤៩រូប ត្រូវបានប្រារព្ធពិធីបើកតាមប្រពៃណីសាសនា ដើម្បីលាងសម្អាតអដ្ឋិធាតុ និងលើកដាក់ក្នុងមឈូសមាស។ នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២ ទើបមានពិធីប្រគល់អដ្ឋិធាតុយុទ្ធជនកងកម្លាំងប្រដាប់អាវុធរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ទាំង៤៩រូប ធ្វើមាតុភូមិនិវត្តន៍ពីសាធារណរដ្ឋសង្គមនិយមវៀតណាម មកកាន់ប្រទេសកម្ពុជាវិញ។ កងយោធពលខេមរភូមិន្ទ មន្ត្រីរាជការ និងប្រជាជនកម្ពុជាបាននៅរង់ចាំទទួលអដ្ឋិធាតុរបស់យុទ្ធជនទាំង៤៩រូប នៅច្រកព្រំដែនកោះថ្ម អ៊ិច-១៦ ស្ថិតនៅក្នុងភូមិកោះថ្ម ឃុំទន្លុង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ អដ្ឋិធាតុរបស់យុទ្ធជនទាំង៤៩រូប ត្រូវប្រារព្ធពិធីបូជា រួចរើសធាតុដាក់តម្កល់ក្នុងកោដ្ឋ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២២ ដោយមានតំណាងរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងការពារជាតិ ចូលរួមដង្ហែទៅតម្កល់ក្នុងមហាចេតិយតំបន់ប្រវត្តិសាស្ត្រយោធាតេជោ កោះថ្ម អ៊ិច-១៦ ដែលទើបសាងសង់រួចរាល់។

នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ ខាងមុខនេះ គឺជាខួបលើកទី៤៧ នៃទិវាចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដល់ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤។







មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ចូលគោរពវិញ្ញាណក្ខន្ធ និងដាក់កម្រងផ្កាជាការចងចាំ និងដឹងគុណចំពោះយុទ្ធជនដែលបានពលីជីវិត ដើម្បីបុព្វហេតុជាតិ និងសង្គ្រោះអាយុជីវិតប្រជាជនប្រមាណ ៥លាននាក់ឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅមហាចេតិយតំបន់ប្រវត្តិសាស្ត្រយោធាតេជោ កោះថ្ម អ៊ិច-១៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅចុងទសវត្សរ៍ឆ្នាំ១៩៧០ ប្រជាជនកម្ពុជាទូទាំងប្រទេសកំពុងរង់ចាំនូវចលនាដឹកនាំខ្លាំងក្លាមួយដ៏ជាក់លាក់ ដើម្បីវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ។ បើគ្មានមេដឹកនាំ និងគ្មានកម្លាំងប្រដាប់អាវុធពិតប្រាកដទេ ចលនាតស៊ូនានានឹងត្រូវបនប្រល័យពូជសាសន៍កម្ទេចទាំងអស់ដោយគ្មានត្រាប្រណីឡើយ។

នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ទីតាំងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៃបញ្ជាការដ្ឋានវរសេនាធំ តំបន់ ២១ សមមិត្ត ហ៊ុន សែន និងកម្មាភិបាលដ៏ទុកចិត្តបួននាក់ គឺ វ៉ា ប៉ោអ៊ាន, នុច ថន, ញឹក ហួន និង ស៊ូ គឹម ស្រ៊ាង (ហៅសាញ់) ចាប់ផ្ដើមធ្វើដំណើរភៀសខ្លួនទៅវៀតណាម ដើម្បីស្វែងរកការជួយឧបត្ថម្ភគាំទ្រក្នុងការរំដោះជាតិ ចេញពីរបបប្រល័យពូជសាសន៍ប៉ុល ពត។ ទីតាំងដែលសមមិត្ត ហ៊ុន សែន និងសមមិត្ត៤នាក់ទៀតឆ្លងកាត់ពីខាងកម្ពុជា គឺនៅត្រង់ពាំងខ្ទ័រ និងអាងដាច់ដែលមានដើមទ្រយឹងធំស្កឹមស្កៃនៅក្បែរនោះ ដែលនៅទល់ខាងមុខគឺជាស្រុក ឡុកនិញ ខេត្តសុងបែ ប្រទេសវៀតណាម។

សមមិត្ត ហ៊ុន សែន បានដើរចូលចម្ងាយប្រមាណ២០០ម៉ែត្រ ទៅក្នុងទឹកដីវៀតណាម។ សំណួរមួយចំនួនដែលសមមិត្ត ហ៊ុន សែន បានចោទសួរខ្លួនឯងថា តើអាចត្រូវស្លាប់នៅពេលឆ្លងព្រំដែនកម្ពុជា-វៀតណាម ដោយការជាន់មីន ឬដោយកងការពារព្រំដែនរបស់វៀតណាមឬទេ? តើអាចត្រូវជាប់គុកដោយសារការឆ្លងដែនខុសច្បាប់ឬទេ? តើវៀតណាមជឿហើយសុខចិត្តជួយក្នុងការផ្ដួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ឬទេ? ក្នុងពេលដែលវៀតណាមកំពុងមានទំនាក់ទំនងការទូតជាមួយកម្ពុជាប្រជាធិបតេយ្យ? សំណួរចុងក្រោយ តើវៀតណាមអាចចាប់បញ្ជូនខ្លួនមកឲ្យ ប៉ុល ពត វិញដែរឬទេ?

សមមិត្ត ហ៊ុន សែន បានដើរទៅដល់ផ្លូវលំក្រាលគ្រួសក្រហម ក៏បានសម្រេចលាក់អាវុធរួចរៀបចំដាំបបរដោយអង្ករដែលនៅសល់ក្នុងថៃបន្តិចបន្តួច រួចបន្តដំណើរតាមផ្លូវថ្នល់ទៅរកជួបកងកម្លាំងវៀតណាម និងប្រជាជនវៀតណាម។ បើសមមិត្ត ហ៊ុន សែន និងកម្មាភិបាលដ៏ទុកចិត្តបួននាក់មិនសម្រេចលាក់អាវុធ ពេលបានជួបជាមួយកងកម្លាំងវៀតណាមច្បាស់ជាផ្ទុះអាវុធជាមិនខាន។ ពេលធ្វើដំណើរបានប្រមាណ១៤គីឡូម៉ែត្រពីព្រំដែន សមមិត្ត ហ៊ុន សែន និងកម្មាភិបាលដ៏ទុកចិត្តបួននាក់បានជួបជាមួយកម្មករចម្ការកៅស៊ូ។ ដំបូងវៀតណាមសង្ស័យថា សមមិត្ត ហ៊ុន សែន និងសមមិត្ត៤នាក់ទៀត គឺជាក្រុមវាយឆ្មក់ ឬក្រុមចារកិច្ចរបស់ ប៉ុល ពត និងបានធ្វើការសាកសួរ។ ក្រោយមក ភាគីវៀតណាមចាប់ផ្ដើមជឿជាក់ខ្លះៗលើការអះអាងរបស់សមមិត្ត ហ៊ុន សែន ថាមិនមែនជាក្រុមវាយឆ្មក់របស់ ប៉ុល ពត ទេ។ ភាគីវៀតណាមក៏បានដាំបាយឆ្នាំងលេខ១០ និងធ្វើម្ហូបសម្រាប់មនុស្ស៥នាក់ដែលមិនបានហូបបាយ គឺហូបតែបបរអស់រយៈពេលជាង១ឆ្នាំកន្លងមកហើយ។ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៧ សមមិត្តទាំងប្រាំត្រូវបានវៀតណាមដឹកតាមរថយន្តធុនធ្ងន់ ម៉ាក GMC ពីភូមិ ឡាំងជីនទៅដល់ស្រុក ឡុកនិញ។

នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ អង្គភាព ១២៥ ដែលមានឈ្មោះផ្លូវការថា កងកម្លាំងប្រដាប់អាវុធសង្គ្រោះជាតិកម្ពុជា ត្រូវបានបង្កើតឡើងនៅធូឌឹក ប្រទេសវៀតណាម។

កោះថ្មនារាត្រីថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ បានក្លាយជាទិវាមួយដ៏សំខាន់នៃរបត់ប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងជាពេលវេលាដែលសមមិត្ត ហ៊ុន សែន បានចាប់ផ្ដើមដំណើរឆ្ពោះទៅការផ្ដួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត។



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចូលគោរពវិញ្ញាណក្ខន្ធ និងដាក់កម្រងផ្កាជាការចងចាំ និងដឹងគុណចំពោះយុទ្ធជនដែលបានពលីជីវិត ដើម្បីបុព្វហេតុជាតិ និងសង្គ្រោះអាយុជីវិតប្រជាជនប្រមាណ ៥ លាននាក់ឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅមហាចេតិយតំបន់ប្រវត្តិសាស្ត្រយោធាតេជោ កោះថ្ម អ៊ិច-១៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើង

## ស្តីពី «ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងដំណាក់កាលទី៣» សម្រាប់អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន ៤៤នាក់ មកពីខេត្តត្បូងឃ្មុំ

ធុង ជានី



អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ ចូលរួមដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើង ស្តីពី «ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងដំណាក់កាលទី៣»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង៨ព្រឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៤ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម ដឹកនាំក្រុមអ្នកស្ម័គ្រចិត្តកម្ពុជា មកពីខេត្តត្បូងឃ្មុំចំនួន៤៤នាក់ ធ្វើដំណើរចេញពីស្ថានីយរថភ្លើងក្រុងភ្នំពេញទៅកាន់ស្ថានីយរថភ្លើងខេត្តកំពត។ គោលបំណងនៃការរៀបចំដំណើរទស្សនកិច្ចសិក្សាតាមទូរថភ្លើងនេះ គឺមជ្ឈមណ្ឌលឯកសារកោះថ្ម ចង់ឲ្យយុវជនបានឈ្វេងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម(១៩៧៥-១៩៧៩) ជាពិសេសអំឡុងពេលដែលកងទ័ពខ្មែរក្រហមជម្លៀសប្រជាជនពីភូមិភាគបូព៌ានៅដំណាក់កាលទី៣ ចាប់ពីចុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨។ ប្រជាជននៅភូមិភាគបូព៌ាទាំងអស់ត្រូវខ្មែរក្រហមជម្លៀសទៅភូមិភាគពាយ័ព្យ តាមវិធីសាស្ត្រផ្សេងៗគ្នា មានដូចជា ការលួងលោមកត់ឈ្មោះ និងការគំរាមកំហែងជាដើម។ ប្រជាជនដែលត្រូវបានខ្មែរក្រហមជម្លៀសដោយបង្ខំ ត្រូវដឹកតាមរទេះគោ ខ្លះក៏ធ្វើដំណើរដោយថ្មើរជើង ហើយ

ខ្លះទៀតក៏បានរត់គេចខ្លួន ប៉ុន្តែត្រូវខ្មែរក្រហមចាប់បាន ហើយយកមកដាក់ឃុំឃាំង។ ប្រជាជនដែលត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិភាគបូព៌ា ទៅភូមិភាគពាយ័ព្យគឺភាគច្រើនអង្គការចាត់តាំងឲ្យធ្វើស្រែ។

រថភ្លើងបានធ្វើដំណើរមកដល់ស្ថានីយខេត្តកំពត នៅវេលាម៉ោង១២ថ្ងៃត្រង់។ នៅវេលាម៉ោង២កន្លះ ក្រុមការងារ និងអ្នកស្ម័គ្រចិត្តកម្ពុជាដែលត្រូវបែងចែកជាក្រុមបានចុះជួបសម្ភាសន៍ និងស្តាប់រឿងរ៉ាវរបស់អតីតអ្នកធ្វើការក្នុងការដ្ឋានស្រែអំបិល និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៥នាក់ សព្វថ្ងៃរស់នៅស្រុកឈូក និងស្រុកជុំគិរី និងទស្សនកិច្ចវាលស្រែអំបិលស្ថិតនៅភូមិបឹងតាព្រាម សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត។ មុនចុះសម្ភាសន៍លោក ឡុង ដានី បានធ្វើការណែនាំទៅកាន់អ្នកស្ម័គ្រចិត្តកម្ពុជា ដើម្បីឲ្យការសម្ភាសន៍ទទួលបានប្រសិទ្ធភាពខ្ពស់។

ខាងក្រោមនេះគឺជាការសង្ខេបរឿងរ៉ាវចេញពីបទសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម៖

## ក្រុមទី១) ផាន់ មាន ៖ អតីតប្រធានកងនារីស្រែអំបិល

នាងខ្ញុំឈ្មោះ ផាន់ មាន ភេទស្រី អាយុ៧៦ឆ្នាំ មានទីកន្លែងកំណើតនៅឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត។ សព្វថ្ងៃ ខ្ញុំរស់នៅភូមិឃុំដដែល។ ខ្ញុំមានកូនចំនួន៥នាក់ ក្នុងនោះមានកូនស្រី១នាក់។ ក្រោយពីរបបខ្មែរក្រហមឡើងកាន់កាប់ប្រទេសបានទាំងស្រុងនៅក្នុងឆ្នាំ១៩៧៥ ខ្ញុំត្រូវបានអង្គការជម្លៀសឲ្យមកធ្វើការក្នុងការដ្ឋានស្រែអំបិល ដែលមានទីតាំងនៅភូមិបឹងតាព្រាម សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត ក្នុងរបបខ្មែរក្រហមគឺតំបន់៣៥ ភូមិភាគនិរតី។ ខ្ញុំមានតួនាទីជាប្រធានកងនារី ក្តាប់កងនារីចំនួន១០០នាក់។ ចំពោះការប្រមូលផលអំបិល ក្នុងមួយអាទិត្យត្រូវប្រមូលផលឲ្យបាន២ដង ឬស្មើ២តោន។ បន្ទាប់ពីនោះខ្ញុំត្រូវលើកអំបិលដាក់លើរថភ្លើងដើម្បីដឹកមកភ្នំពេញ។ ចំពោះម៉ោងធ្វើការ គឺចាប់ផ្តើមពីម៉ោង៦ព្រឹក រហូតដល់ម៉ោង១១ថ្ងៃត្រង់ ចំណែករសៀលគឺចាប់ពីម៉ោង១២ រហូតដល់ម៉ោង១០យប់ក៏មាន ប្រសិនបើប្រមូលផលអំបិលមិនទាន់ហើយរួចរាល់។ បន្ទាប់ពីធ្វើការ ខ្ញុំត្រូវចូលរួមការប្រជុំទិតៀនស្វ័យទិតៀនគ្នាទៅវិញទៅមក ដើម្បីកែប្រែកំហុស។ ខ្ញុំត្រូវអង្គការទិតៀនច្រើនដង ហើយខ្ញុំត្រូវឡើងប្តេជ្ញាស្មោះត្រង់ជាមួយអង្គការ និងខិតខំធ្វើការ។ នៅក្នុងកងនារីរបស់ខ្ញុំ ពុំមានអ្នកណាត្រូវទទួលទារុណកម្មធ្ងន់ធ្ងរ ឬត្រូវអង្គការយកទៅសម្លាប់ ឬបាត់ខ្លួនឡើយ។ ខ្ញុំធ្លាប់ឮអង្គការយកមនុស្សទៅសម្លាប់ ប៉ុន្តែខ្ញុំមិនដឹងថា អង្គការសម្លាប់ឬក៏អត់ទេ ព្រោះចេះតែមានមនុស្សបាត់ខ្លួនរហូតមក។ រីឯការហូបចុកវិញ ខ្ញុំមិនបានហូបគ្រប់គ្រាន់ទេ តែខ្ញុំត្រូវតែធ្វើការជូនអង្គការឲ្យបានដាច់ខាត។ នៅក្នុងរបបខ្មែរក្រហម មានមន្ទីរពេទ្យសម្រាប់ព្យាបាលជំងឺ ប៉ុន្តែការព្យាបាលមិនបានជិតដល់ឡើយ។ ក្នុងរបបខ្មែរក្រហម អង្គការបានរៀបចំរៀបការឲ្យខ្ញុំ ដោយគ្រាន់តែចាប់ដៃគ្នា និងឡើងប្តេជ្ញាជូនអង្គការប៉ុណ្ណោះ។ សម័យនោះ សម្លៀកបំពាក់រៀបការរបស់ខ្ញុំរហែក ព្រោះអង្គការមិនបានបើកខោអាវថ្មីឲ្យខ្ញុំឡើយ។ ក្រោយពេលរៀបការរួច អង្គការបានបញ្ជូនខ្ញុំឲ្យទៅរស់នៅភ្នំពេញជាមួយប្តី។ មកដល់ភ្នំពេញប្រហែលជា១០ថ្ងៃ កងទ័ពវៀតណាមវាយចូលមករំដោះបានទីក្រុងភ្នំពេញនៅដើមឆ្នាំ១៩៧៩។ ខ្ញុំត្រូវរត់ទៅតាមកងទ័ពខ្មែរក្រហមដល់ខេត្តពោធិ៍-សាត់។ បន្ទាប់ពីស្រុកទេសមានសន្តិភាព ខ្ញុំបានទៅរស់នៅស្រុកស្ទោង ខេត្តកំពង់ធំ ជាស្រុកកំណើតខាងប្តីរបស់ខ្ញុំរយ:ពេល២០ឆ្នាំ។ ក្រោយមកខ្ញុំក៏វិលត្រឡប់មករស់នៅស្រុកកំណើតរបស់ខ្ញុំវិញរហូតមកដល់សព្វថ្ងៃនេះ។

## ក្រុមទី២) សយ យ៉ា ៖ អតីតកងនារីស្រែអំបិលនៅខេត្តកំពត

នាងខ្ញុំឈ្មោះ សយ យ៉ា អាយុ៦៦ឆ្នាំ កើតនៅឃុំក្រាំងស្បូវ ស្រុកឈូក ខេត្តកំពត។ សព្វថ្ងៃខ្ញុំរស់នៅក្នុងភូមិចំការមន ឃុំតាកែន ស្រុកឈូក ខេត្ត

កំពត។ ខ្ញុំមានប្តីឈ្មោះ ម៉ុម ជា និងមានកូនចំនួន ៨នាក់។ ដំណាក់កាលដំបូង អង្គការចាត់តាំងខ្ញុំឲ្យធ្វើការសែងគ្រាប់ សែងអ្នករបួស និងសែងសសរឈើទុកធ្វើឃ្លាំងដាក់អំបិល។ ក្រុមសែងសសរមានគ្នា ១២នាក់ សុទ្ធតែជានារី។ មានពេលមួយនោះ ដៃគូម្នាក់របស់ខ្ញុំបានរបូតស្បែកជើងហើយក៏ផ្អៀងខ្លួន ចំណែកអ្នកក្រោយឃើញបែបនេះស្មានថាទម្លាក់ចុះ ខ្ញុំក៏ទម្លាក់ឈើតាមដែរ ស្រាប់តែភ្លាត់ត្រូវចំក្បាលសមាជិកម្នាក់ទៀតស្លាប់ភ្លាមៗ។ ដោយហេតុការណ៍មួយនេះ ខ្ញុំក៏សម្រេចចិត្តស្នើសុំឈប់ពីការងារសែងសសរ។ ក្រោយមក អង្គការបញ្ជូនខ្ញុំមកការដ្ឋានស្រែអំបិលក្នុងអំឡុងឆ្នាំ១៩៧៨ ដោយមួយថ្ងៃកំណត់ឲ្យកើបអំបិលឲ្យបាន២ស្រែ នៅពេលអំបិលកកក្រាស់។ ប្រសិនបើអំបិលកកស្តើង ត្រូវកើបឲ្យហើយ៣ស្រែ។ កាលនោះ ប្រធានក្រុមធំមានឈ្មោះ ស៊ីនឿន។ ដំបូងខ្ញុំហូបបាយបានឆ្អែត។ ក្រោយមកពេលអំបិលទទួលបានផលច្រើន និងការងារច្រើន បែរជាអង្គការកាត់បន្ថយរបបបាយ ហើយដូរមកជាបបរវិញដោយអង្គការយកលេសថាស្បៀយអង្ករ។ ខ្ញុំចាំបានថាការដ្ឋានស្រែអំបិលមាន៣កន្លែងគឺ បឹងទូក ត្រើយកោះ និង ជុំគ្រៀល។ ការងាររបស់ខ្ញុំក្រៅពីរែកអំបិល គឺកាប់ស្លឹកចាកយកមកបាំងឃ្លាំងអំបិល កោសស្លែដាក់ភ្លឺស្រែ ហាលស្រែឲ្យស្ងួត បុកឲ្យហាប់ ហើយកម្មករស្រែអំបិលក៏អាចច្រៀងរាំបានដែរ។ យើងច្រៀងរាំដើម្បីបន្ទប់ទុក្ខ និង ភាពស្រេកឃ្លាន ព្រោះមិនមានអាហារហូបគ្រប់គ្រាន់។ នៅពេលយប់ខ្ញុំស្រេកឃ្លានយ៉ាងខ្លាំង ដូច្នេះខ្ញុំបន់ព្រះឲ្យឆាប់ភ្លឺដល់ម៉ោង១២ថ្ងៃត្រង់ ដើម្បីបានអាហារហូប ប៉ុន្តែពេលព្រឹកអង្គការប្រើឲ្យខ្ញុំរែកអំបិលទាំងអត់អាហារ។ សព្វថ្ងៃ ខ្ញុំមានជំងឺដាច់សរសៃឈាមបេះដូង ដែលបណ្តាលមកពីធ្វើការងារធ្ងន់តាំងពីរបបខ្មែរក្រហម។



អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ ចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តកំពត អំឡុងពេលចូលរួមដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើង ស្តីពី «ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងដំណាក់កាលទី៣»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



## ក្រុមទី៣) មុំ ផា អតីតកងចល័តនារីកងចល័តអំបិលនៅការដ្ឋានស្រែអំបិលបឹងទូក

ខ្ញុំឈ្មោះ មុំ ផា កើតនៅភូមិត្រពាំងគុល ឃុំត្រពាំងសាលាខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិចំការមន ឃុំតាកែន ស្រុកឈូក ខេត្តកំពត។ ខ្ញុំមានបងប្អូនចំនួន៩ នាក់ ក្នុងនោះមានស្រី៤នាក់។ ខ្ញុំមានប្រពន្ធឈ្មោះ សយ យ៉ា និងមានកូនចំនួន៧ នាក់។ ក្នុងរបបខ្មែរក្រហម អង្គការចាត់តាំងខ្ញុំឲ្យធ្វើការងារ ដូចជា៖ ធ្វើស្រែ ដាំបន្លែ លើករងដំឡូង ដាំឪឡឹក កើបអាចម៍គោលាមកមនុស្ស ជួយបង្ហាប់ដីស្រែសម្រាប់ធ្វើស្រែអំបិល និងប្រមូលផលអំបិលដាក់ក្នុងឃ្លាំង។ ខ្ញុំធ្វើការគ្មានពេលឈប់សម្រាកឡើយ ប៉ុន្តែរបបអាហារមិនបានហូបគ្រប់គ្រាន់ឡើយ គឺហូបតែបបររាវៗ ពេលខ្លះបបរលាយដំឡូងឬទំពាំង ធ្វើឲ្យខ្ញុំគ្មានកម្លាំងធ្វើការឡើយ។ នៅចន្លោះពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ អង្គការបានផ្លាស់ប្តូរខ្ញុំទៅភ្នំពេញ ដើម្បីឃ្វាលគោរាប់ពាន់ក្បាល ស្ថិតនៅតំបន់បឹងប្រយ៉ាបខាងត្បូងព្រែកព្នៅ។ បន្ទាប់មក នៅចុងឆ្នាំ១៩៧៨ អង្គការបានឲ្យខ្ញុំហាត់ក្បួនទាហាន ក្រាបលូន និងរត់ចម្ងាយ១០គីឡូម៉ែត្រ។ ពេលខ្លះអង្គការឲ្យខ្ញុំហាត់ទាំងពាក់កណ្ដាលយប់នៅចំណុចវត្តឃ្មុញក្បែរទីក្រុងភ្នំពេញ។ មិនយូរប៉ុន្មានកងទ័ពវៀតណាមក៏វាយចូលមករំដោះប្រជាជនកម្ពុជា នៅដើមឆ្នាំ១៩៧៩។ ខ្ញុំក៏រត់បែកខ្ញែកពីអ្នកដែលធ្លាប់រស់ជាមួយគ្នា ទៅរស់នៅជាមួយកងទ័ពខ្មែរក្រហមប្រមាណ ២០០នាក់ ដែលកំពុងដាច់ស្បៀងអាហារ។ ខ្ញុំរស់នៅជាមួយកងទ័ពខ្មែរក្រហមរហូតមកដល់ឆ្នាំ១៩៨១។ នៅក្នុងឆ្នាំ១៩៨១ ដដែល ខ្ញុំក៏បានចូលមកសារភាពជាមួយរដ្ឋអំណាចនៅស្រុកមោងឫស្សី ខេត្តបាត់ដំបង។ បន្ទាប់ពីបានចូលសារភាពរួចអាជ្ញាធរស្រុក ក៏បានឲ្យខ្ញុំវិលមកជួបជុំក្រុមគ្រួសារបងប្អូនខ្ញុំវិញ។ ប៉ុន្តែបងប្រុសខ្ញុំម្នាក់ឈ្មោះ មុំ កើតមានតួនាទីជាកងទ័ពខ្មែរក្រហម បានស្លាប់នៅភ្នំដិន តាំងពីឆ្នាំ១៩៧៩។ នៅក្នុងឆ្នាំ១៩៨២ ខ្ញុំបានរៀបការជាមួយប្រពន្ធឈ្មោះ សយ យ៉ា តាមប្រពៃណីនៅភូមិក្រាំងស្បូវ ឃុំក្រាំងស្បូវ ស្រុកឈូក ខេត្តកំពត។ ដោយសារជីវភាពខ្វះខាត កូនខ្ញុំទាំង៧ នាក់មិនបានរៀនសូត្រខ្ពង់ខ្ពស់នឹងគេទេ។




អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ ចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តកំពត អំឡុងពេលចូលរួមដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើង ស្តីពី «ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងដំណាក់កាលទី៣»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ក្រុមទី៤) អ៊ាម ភ័ន្ត ៖ អតីតចុងភៅនៅអង្គភាពទ័ពខ្មែរក្រហម

ខ្ញុំឈ្មោះ អ៊ាម ភ័ន្ត ភេទប្រុស អាយុ៦៥ឆ្នាំ មានទីកន្លែងកំណើត និងរស់នៅបច្ចុប្បន្នក្នុងភូមិបឹងតាព្រាម សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត។ ខ្ញុំគឺជាអតីតនាយកសាលាបឋមសិក្សាបឹងតាព្រាម។ កាលពីកុមារភាពខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ ចាស់ តែដោយសារសង្គ្រាម មានការទម្លាក់គ្រាប់បែក គ្រួសារខ្ញុំនិងអ្នកភូមិឯទៀតក៏ផ្លាស់ចេញទៅរកតំបន់មានសុវត្ថិភាព។ ឪពុកម្ដាយខ្ញុំទៅរស់នៅតំបន់ថ្មី ហើយខ្ញុំក៏បានបន្តការរៀនសូត្រនៅសាលាចិនមួយដែលមានឈ្មោះថា ហេង ម៉េង។ ពេលនោះ ខ្ញុំរៀនភាសាបរទេសគឺភាសាអង់គ្លេស និងភាសាបារាំងបន្ថែមទៀត។ ខ្ញុំរៀនមិនបានប៉ុន្មានផង ខ្មែរក្រហមបានចូលមកគ្រប់គ្រងប្រទេសបានទាំងស្រុង ហើយខ្ញុំត្រូវបានអង្គការជម្លៀសទៅខេត្តកោះកុងដើម្បីលើកទំនប់ និងធ្វើស្រែ។ ទិដ្ឋភាពនៅតាមផ្លូវជម្លៀសគឺពិតជាអណោចអធ័មណាស់ ព្រោះខ្ញុំឃើញមានសាកសពនៅពាសវាលពាសកាល។ ខ្ញុំអាចនៅរស់រានមានជីវិតពីរបបខ្មែរក្រហមបានដោយសារខ្ញុំអាចធ្វើការងារបានគ្រប់យ៉ាង និងមានស្នាដៃចម្អិនអាហារឆ្ងាញ់។ កងទ័ពខ្មែរក្រហមចាត់តាំងខ្ញុំឲ្យធ្វើជាចុងភៅ។ ក្នុងរបបខ្មែរក្រហម ខ្ញុំមិនដែលឈឺ ឬបង្កឲ្យមានផលលំបាកដល់កងទ័ពខ្មែរក្រហមទេ។ តួនាទីជាចុងភៅក្នុងរបបខ្មែរក្រហម និងជារឿងដែលរន្ធត់បំផុតចំពោះខ្ញុំផ្ទាល់គឺ មិត្តភក្តិរបស់ខ្ញុំចំនួន៣នាក់ត្រូវកងទ័ពខ្មែរក្រហមសម្លាប់ និងវះយកថ្លើមមកឲ្យខ្ញុំចម្អិនជាម្ហូបជូនអង្គការបរិភោគ ដោយចោទថាមិត្តភក្តិរបស់ខ្ញុំទាំងបីនាក់នោះតដៃជាមួយអង្គការ។



អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ ចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទស្សនាស្រែអំបិលនៅខេត្តកំពត អំឡុងពេលចូលរួមដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើង ស្ដីពី «ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងដំណាក់កាលទី៣»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បណ្តុះបណ្តាលសិស្សវិទ្យាល័យ ហ៊ុន សែន ស្គន់

## អំពីការប្រើប្រាស់ម៉ាស៊ីនថតរូប និងបច្ចេកទេសថតរូបជាឯកសារ

***សាំង ចាន់ធូ***




*លោក លី ដេវីត និងក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមបណ្តុះបណ្តាលសិស្សវិទ្យាល័យ ហ៊ុន សែន ស្គន់ អំពីការប្រើប្រាស់ម៉ាស៊ីនថតរូប និងបច្ចេកទេសថតរូបជាឯកសារ។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំការបណ្តុះបណ្តាលសិស្សវិទ្យាល័យ ហ៊ុន សែន ស្គន់ ចំនួន២០នាក់ អំពីការប្រើប្រាស់ម៉ាស៊ីនថតរូប និងបច្ចេកទេសថតរូបជាឯកសារ។ ការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ម៉ាស៊ីនថតរូប និងបច្ចេកទេសថតរូប ធ្វើឡើងតបតាមការស្នើសុំរបស់គណៈគ្រប់គ្រងវិទ្យាល័យ ហ៊ុន សែន ស្គន់ ដើម្បីផ្តល់ចំណេះដឹង ក៏ដូចជាការអនុវត្តផ្ទាល់អំពីការប្រើប្រាស់ម៉ាស៊ីនថតរូប និងការថតរូបដល់សិស្សដែលជាសមាជិកនៃក្រុមប្រឹក្សាយុវជន-យុវនារីរបស់វិទ្យាល័យ ក្នុងការផ្តិតយករូបថត ដើម្បីចងក្រងជាឯកសាររាល់សកម្មភាព និងព្រឹត្តិការណ៍កើតឡើងនៅក្នុងវិទ្យាល័យ។

លោក លី ដេវីត បុគ្គលិកផ្នែកផ្សព្វផ្សាយនៃ







*លោក លី ដេវីត និងក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បណ្តុះបណ្តាលសិស្សវិទ្យាល័យ ហ៊ុនសែន ស្គន់ អំពីការប្រើប្រាស់ម៉ាស៊ីនថតរូប និងបច្ចេកទេសថតរូបជាឯកសារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ផ្តល់បទបង្ហាញអំពីមេរៀនជាមូលដ្ឋានអំពីរបៀបនៃការប្រើប្រាស់ ការគ្រប់គ្រងម៉ាស៊ីនថតរូប, ការប្រើប្រាស់ពន្លឺ និងការជ្រើសរើសប្លង់។ បន្ទាប់ពីការធ្វើបទបង្ហាញជាទ្រឹស្តី សិស្សដែលចូលរួមទាំងអស់ គឺត្រូវបានតម្រូវឲ្យថតរូបក្នុងម្នាក់ចំនួន៥សន្លឹក និងត្រូវជ្រើសតែរូបថត១សន្លឹកដែលខ្លួនពេញចិត្តបំផុតដើម្បីយកមកជួបជាមួយលោក លី ដេវីត ដើម្បីផ្តល់ជាមតិណែនាំបន្ថែម។

លោក ខូវ ណារិន នាយករងវិទ្យាល័យ ហ៊ុនសែន ស្គន់ ថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលបានចំណាយពេលចុះមកបង្រៀន និងផ្តល់ការអនុវត្តផ្ទាល់ទៅកាន់សិស្សានុសិស្ស ពីព្រោះគណៈគ្រប់គ្រងវិទ្យាល័យមានបំណងចងក្រងទាំងរូបភាព និងវីដេអូ អំពីសកម្មភាព និងព្រឹត្តិការណ៍សំខាន់របស់វិទ្យាល័យទុកជាឯកសារសម្រាប់សិស្សជំនាន់ក្រោយ។

# អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ បានធ្វើទស្សនកិច្ចសិក្សា និងជួប

## ជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

ឈុំ រ៉ា



អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ធ្វើទស្សនកិច្ចសិក្សានៅព្រះរាជបណ្ណាល័យ ហ្វូងម៉ៃនៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងជួបជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង៨:៣០ព្រឹក ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៤ អ្នកស្ម័គ្រចិត្តមកពីខេត្តត្បូងឃ្មុំ និងខេត្តក្រចេះចំនួន៤០នាក់ ដែលបានចូលរួមដំណើរទស្សនកិច្ចសិក្សា «ផ្លូវរថភ្លើងខ្មែរក្រហម» ផ្តោតលើប្រធានបទ «អំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិប្បតេយ្យ៖ ការជម្លៀសដោយបង្ខំនៅដំណាក់កាលទី៣» ចាប់ពីនៅថ្ងៃទី១ ដល់ ទី៥ ខែមិថុនា ឆ្នាំ២០២៤ បានមកធ្វើទស្សនកិច្ចសិក្សា និងជួបជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ បន្ទាប់ពីលោក ឆាំង យុ ទទួលស្វាគមន៍អ្នកស្ម័គ្រចិត្តទាំង៤០នាក់រួចមក លោក ឆាំង យុ បានលើកឡើងពីប្រសាសន៍របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ដែលបានថ្លែងនៅក្នុងពិធីបើកសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃ ទី២០ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ នៅសាលយុត្តិធម៌... តេជោ បញ្ញការដ្ឋានកងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ ដែលមានខ្លឹមសារដូចខាងក្រោម៖





អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ធ្វើទស្សនកិច្ចសិក្សានៅព្រះរាជបណ្ណាល័យ ហ្វូងម៉ៃនៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងជួបជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្ថាប័នរដ្ឋាភិបាល ទាំងអស់ ទាំងយោធា និងស៊ីវិល ត្រូវតែគាំទ្រការផ្សារអប់រំពីអំពើប្រល័យពូជសាសន៍សម្រាប់មនុស្សជំនាន់ក្រោយ។ យើងត្រូវតែធានាថា ការបង្រៀនប្រវត្តិសាស្ត្រ ត្រូវបានដាក់បញ្ចូលយ៉ាងត្រឹមត្រូវ នៅក្នុងកម្មវិធីសិក្សារបស់សាលារដ្ឋ និង ឯកជន ចាប់ពី អនុវិទ្យាល័យ រហូតដល់សាកលវិទ្យាល័យ ហើយគ្រូបង្រៀនទាំងអស់របស់យើង អាចចូលរួមជាកម្លាំង ដើម្បីផ្សព្វផ្សាយការអប់រំពីអំពើប្រល័យពូជសាសន៍ នៅក្នុងសាលារៀនទូទាំងប្រទេស។ ការអប់រំពីអំពើប្រល័យពូជសាសន៍មិនចាំបាច់កំណត់ត្រឹមតែមេរៀនប្រវត្តិ-សាស្ត្រនោះទេ។ យើងក៏អាចបញ្ចូលទៅក្នុងមុខវិជ្ជាគ្រប់ប្រភេទ ចាប់ពីសីលធម៌ និង អក្សរសាស្ត្រខ្មែរ រហូតដល់ការសិក្សាពីភាពជាអ្នកដឹកនាំ និង ការអភិវឌ្ឍន៍ជំនាញទន់ផ្សេងទៀតផងដែរ។ យើងក៏អាចស្វែងរកវិធីច្នៃប្រឌិតផ្សេងៗ ដើម្បីរៀបរាប់រឿងរ៉ាវពិបាក ទាំងនេះ ទៅកាន់មនុស្សដែលមានវ័យ និងជំនាន់ផ្សេងគ្នារួមមាន តាមរយៈសិល្បៈ មាតិកាឌីជីថល ឬ គំនូរជីវចល ជាដើម។

យើងចាំបាច់ត្រូវសង្កត់ធ្ងន់ថា កាតព្វកិច្ចលើកកម្ពស់ការអប់រំពីអំពើប្រល័យពូជសាសន៍គឺជារបស់កាតព្វកិច្ចរបស់យើងទាំងអស់គ្នា មិនមែនតែរាជរដ្ឋាភិបាលម្នាក់ឯងនោះទេ។ សន្និសីទថ្ងៃនេះ គឺជាគំរូដ៏ប្រសើរ នៃកិច្ចសហប្រតិបត្តិការល្អ និង សាមគ្គីភាពរវាងតួអង្គពាក់ព័ន្ធផ្សេងៗ។ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានជួយរាជរដ្ឋា-ភិបាល ក្នុងការដាក់បញ្ចូលការបង្រៀនអំពីប្រវត្តិ-សាស្ត្រនៃអំពើប្រល័យពូជសាសន៍ ទៅក្នុងការអភិវឌ្ឍវិជ្ជាជីវៈ និង ស្ថាប័ន និង សម្រាប់សកម្មភាព

ផ្សព្វផ្សាយក្នុងមជ្ឈដ្ឋានជាតិ និង អន្តរជាតិ ដោយប្រើប្រាស់ប្រវត្តិសាស្ត្រ ដើម្បីត្រិះរិះពិចារណា និងបំផុសគំនិត សម្រាប់អនាគតកម្ពុជា។

បន្ទាប់មក អ្នកស្ម័គចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំចំនួន២ក្រុម បានឡើងធ្វើបទបង្ហាញយ៉ាងក្បោះក្បាយអំពីអ្វីដែលខ្លួន និងក្រុមរបស់ខ្លួនបានរៀនសូត្រ ចេញដំណើរទស្សនកិច្ចសិក្សា «ផ្លូវរថភ្លើងខ្មែរក្រហម» ពីភ្នំពេញទៅកាន់ខេត្តកំពត និងបានជួបសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិបឹងតាព្រាម សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត និងទំនប់ម្រេចក្នុងឃុំប្រេស ស្រុកជុំគិរី ខេត្តកំពត។

នៅក្នុងឱកាសនោះដែរ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានអនុញ្ញាតឲ្យអ្នកស្ម័គ្រចិត្តកម្ពុជាសួរសំណួរទាក់ទងនឹងការរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ -១៩៧៩) ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងការសាងសង់ការិយាល័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅតាមបណ្ដាខេត្តនានា ជាពិសេសនៅភូមិបាក់នឹម ឃុំប្រេស ស្រុកជុំគិរី ខេត្តកំពត។

អ្នកស្ម័គ្រចិត្តភាគច្រើនបានដឹងរឿងរ៉ាវអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកាន់តែច្បាស់ និងបានយល់ដឹងពីបញ្ហាសុខភាពផ្លូវកាយ ផ្លូវចិត្ត ដូចជាជំងឺផ្លូវចិត្ត (ជំងឺបាក់ស្បាត) ដែលបន្សល់ពីរបបខ្មែរក្រហម។ ការយល់ដឹងបញ្ហាខាងលើនេះបានធ្វើឲ្យអ្នកស្ម័គ្រចិត្តកម្ពុជាមានការជឿជាក់ និងកាន់តែអាណិតអាសូរដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ អ្នកស្ម័គ្រចិត្តកម្ពុជាបានសំណូមពរលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបន្តរៀបចំដំណើរទស្សនកិច្ចសិក្សាបែបនេះទៀត ដើម្បីឲ្យយុវជនជំនាន់ក្រោយបានរៀនសូត្រអំពីប្រវត្តិសាស្ត្រឈឺចាប់របស់ប្រទេសជាតិខ្លួន។

ចុងក្រោយ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្ដាំផ្ញើអ្នកស្ម័គ្រចិត្តទាំងអស់ឲ្យរក្សាទំនាក់ទំនងជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងមិត្តភក្តិដែលបានចូលរួមដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើងនេះ។





អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ធ្វើទស្សនកិច្ចសិក្សានៅព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងជួបជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ និង ខេត្តក្រចេះ ទស្សនកិច្ចសហគមន៍ភូមិបាក់នឹម

ឈុំ រ៉ា



អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ធ្វើទស្សនកិច្ចសិក្សានៅសហគមន៍ភូមិបាក់នឹម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



នៅវេលាម៉ោង៧:៤០នាទីព្រឹក ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤ ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៤០នាក់មកពីខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ដឹកនាំក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានធ្វើដំណើរតាមរថយន្តក្រុងចេញពីរមណីយដ្ឋានទំនប់ម្រេចឆ្ពោះទៅសហគមន៍ភូមិបាក់នឹម ស្ថិតនៅក្នុងភូមិបាក់នឹម ឃុំប្រេស ស្រុកជុំគិរី ខេត្តកំពត។ នៅវេលាម៉ោង៨ព្រឹក ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាបានទៅឈប់នៅជើងភ្នំដំរីរមៀល រួចបន្តដំណើរដោយថ្មើរជើងប្រមាណ១គីឡូម៉ែត្រ ទើបដល់សហគមន៍ភូមិបាក់នឹម។ គោលបំណងនៃដំណើរទស្សកិច្ចសិក្សាទៅកាន់សហគមន៍ភូមិបាក់នឹមដើម្បីឲ្យអ្នកស្ម័គ្រចិត្តកម្ពុជា

ឈ្វេងយល់អំពីរឿងរ៉ាវជីវិតរបស់ប្រជាជននៅសហគមន៍ដែលបានឆ្លងកាត់របបខ្មែរក្រហម។

នៅរដូវវស្សាដែលមានភ្លៀងធ្លាក់ជោគជាំ យើងសង្កេតឃើញរុក្ខជាតិនៅតាមជួរភ្នំដំរីរមៀលមានពណ៌បៃតងស្រស់បំព្រង។ ទេសភាពដ៏ស្រស់ត្រកាលទាំងនេះ បានធ្វើឲ្យអ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ព្រមទាំងក្រុមការងារមជ្ឈ-មណ្ឌលឯកសារកោះថ្ម មានអារម្មណ៍ស្រស់ស្រាយ និងភាពសប្បាយរីករាយ។ សហគមន៍ភូមិបាក់នឹម គឺស្ថិតនៅឆ្ងាយពីទីប្រជុំជន និងមានភ្នំនៅព័ទ្ធជុំវិញប្រៀបបានទៅនឹងជញ្ជាំងបាំង។ នៅជុំវិញបរិវេណសហគមន៍ភូមិបាក់នឹមមានវាលស្មៅពណ៌បៃតង និងមានស្រះឈូកចំពីមុខអគារការិយាល័យដែលកំពុងចេញផ្ការហង់។ សហគមន៍ភូមិបាក់នឹម គឺជាកន្លែងសម្រាប់ប្រជាជនក្នុងនៅក្នុងភូមិមកជួបជុំគ្នា និងជាកន្លែងសម្រាប់អ្នកស្ម័គ្រចិត្តកម្ពុជាធ្វើការងារបម្រើដល់សហគមន៍។







អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ធ្វើទស្សនកិច្ចសិក្សានៅសហគមន៍ភូមិបាក់នឹម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទាវ ឆុន រំឭកអំពីសាវតាររបស់ខ្លួនជានិគមជនរបបសង្គមរាស្ត្រនិយម និងព្រឹត្តិការណ៍ខ្មែរក្រហមស្វែងរកចាប់ខ្លួនអ្នកដែលមានប្រវត្តិជានិគមជន

សាំង ចិន្តា



*ទាវ ឆុន អាយុ៧៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ទាវ ឆុន អាយុ៧៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ខ្ញុំគឺជានិគមជនរបបសង្គមរាស្ត្រនិយម មកពីខេត្តស្វាយរៀង គឺជាប្រជាជនដែលត្រូវបានសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ បញ្ជូនមករស់នៅក្រុងបុរីអូរស្វាយ ចាប់តាំងពីឆ្នាំ១៩៦៧ មកម៉្លេះ។ ខ្ញុំរៀបការជាមួយប្រពន្ធឈ្មោះ ចេង សាមី ដែលជានិគមជនរបបសង្គមរាស្ត្រនិយម មកពីខេត្តព្រៃវែង និងមានកូនប្រុសស្រីចំនួន១០នាក់ ចៅជិត២០នាក់ និងចៅទួត១នាក់។ ខ្ញុំមានឪពុកឈ្មោះ ទាវ សុខ និងម្តាយឈ្មោះ ម៉ែនធួង (ស្លាប់អស់ហើយ)។ ខ្ញុំគឺជាកូនទី២ ក្នុងចំណោមបងប្អូនប្រុសស្រីសរុបចំនួន៥នាក់។ នៅពីក្មេង ខ្ញុំចូលរៀននៅសាលាបឋមសិក្សាពោធិ៍រាជ។ ក្រោយមក ខ្ញុំប្រឡងចូលរៀននៅវិទ្យាល័យព្រះសូរិយាវង្ស រហូតដល់ថ្នាក់ទី៥សង្គមចាស់។ ខ្ញុំអាចអាន ស្តាប់ និងនិយាយភាសាបារាំងបានខ្លះៗ។ នៅឆ្នាំ១៩៦២ ខ្ញុំឈប់រៀនដោយសារតែជីវភាពក្រលំបាកមិនអាចបន្តការសិក្សាបាន។

បន្ទាប់ពីឈប់រៀន ខ្ញុំចូលធ្វើការជាកម្មករនៅមន្ទីរសាធារណៈការ។ ការងាររបស់ខ្ញុំគឺត្រូវដើរចាក់ដីរកៅស៊ូនៅតាមផ្លូវថ្នល់។ ពីព្រោះតែធ្វើជាកម្មករហត់នឿយពេក ខ្ញុំក៏មានគំនិតលក់ការ៉េមវិញ។ នៅពេលនោះ ខ្ញុំទទួលបានកម្រៃច្រើនគួរសម។ នៅពេលដែលខ្ញុំកំពុងតែលក់ការ៉េម ខ្ញុំបានឮសេចក្តីប្រកាស និងអំពាវនាវរកអ្នកស្ម័គ្រចិត្តមករស់នៅក្រុងបុរីអូរស្វាយ ដើម្បីការពារទឹកដី ក្នុងគម្រោងអភិវឌ្ឍន៍នៅតំបន់ជាប់ស្រយាលក្នុងប្រទេសកម្ពុជា ដែលផ្តួចផ្តើមដោយសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ នៅពេលនោះ ខ្ញុំដឹងថា មានការរៀបចំទីតាំងរស់នៅសម្រាប់ទទួលនិគមជនដែលមកពីតាមបណ្តាខេត្តនានា ហើយការជ្រើសរើស គឺសម្រាប់តែប្រជាជនដែលចេះនិយាយ សរសេរ អានភាសាខ្មែរច្បាស់។ ខ្ញុំដឹងថា ការជ្រើសរើសប្រជាជនដែលចេះភាសាខ្មែរច្បាស់ គឺដើម្បីការពារបូរណភាពទឹកដី ខណៈដែលលាវក្រហម ដែលមាននិន្នាការប្រឆាំងរដ្ឋាភិបាលលាវនៅពេលនោះ បានប្រកាសគ្រប់ទឹកន្លែងណាដែលប្រជាជននិយាយភាសាលាវ គឺជាទឹកដីលាវ និងមានបំណងយកទឹកដីខ្មែរ ក្នុងនោះគឺមានទឹកដីនៅខាងខេត្តស្ទឹងត្រែងនេះផងដែរ។

នៅឆ្នាំ១៩៦៧ ក្នុងស្មារតីនិងបំណងមករស់នៅដើម្បីការពារទឹកដី ខ្ញុំចុះឈ្មោះក្នុងបញ្ជីប្រជាជនដែលត្រូវបញ្ជូនមករស់នៅបុរីអូរស្វាយនេះតែម្តង។ ខ្ញុំធ្វើដំណើរមកជាមួយឪពុកមា ដែលមានតួនាទីជានាយទាហានម្នាក់។ មានប្រជាជនចំនួនតែ២គ្រួសារតែប៉ុណ្ណោះមកពីខេត្តស្វាយរៀង។ ពេលនោះគឺជាដំណាក់កាលទី៣នៃការបញ្ជូននិគមជនមករស់នៅក្រុងបុរីអូរស្វាយនេះ។ នៅចន្លោះឆ្នាំ១៩៦៤ ដល់ឆ្នាំ១៩៦៧ ប្រជាជនមន្ត្រីយោធាចូលនិវត្តន៍ ទាហាន និងគ្រួសារដែលមានចំណូលទាបមកពីខេត្តតាកែវ ព្រៃវែង ស្វាយរៀង និងខេត្តកណ្តាល ត្រូវបានបញ្ជូនមករស់នៅក្រុងបុរីអូរស្វាយនេះជា៣ដំណាក់កាល ដោយទទួលបានផ្ទះមួយខ្នង ដីស្រែចម្ការ គ្រាប់ពូជ គោក្របី និងប្រាក់ឧបត្ថម្ភសម្រាប់ចាប់ផ្តើមជីវភាពរស់នៅក្នុងទឹកដីថ្មី។ ក្រោយមក ខ្ញុំបានរៀបការប្រពន្ធដែលជាប្រជាជនមកពីខេត្តព្រៃវែង និងមានកូនម្នាក់។ ខ្ញុំទទួលបានរបបរួមមាន ផ្ទះនិងដីរស់នៅទំហំ៤០ម៉ែត្រ គុណ ៥០ម៉ែត្រ, ដីស្រែចម្ការ៥ ហិកតា, គោមួយនឹម, និងប្រាក់ឧបត្ថម្ភ៧៥០រៀលក្នុងមួយខែ រយៈពេល៣០ខែ (២ឆ្នាំកន្លះ)។

នៅថ្ងៃមួយ នៅពេលដែលខ្ញុំទៅបើកប្រាក់ឧបត្ថម្ភប្រចាំខែ ខ្ញុំឃើញមានតួលេខសរុបប្រជាជនដែលត្រូវបានបញ្ជូនមករស់នៅបុរីអូរស្វាយនេះ គឺមានសរុបទាំងអស់ចំនួន៣០០គ្រួសារជាង ដែលផែនការគ្រោងទទួលប្រជាជនចំនួន៥០០គ្រួសារ។ ចំពោះហេដ្ឋារចនាសម្ព័ន្ធវិញ ខ្ញុំឃើញមានមន្ទីរចាត់ការ, សាលាស្រុក, មន្ទីរពេទ្យ, ផ្សារសហគមន៍, ទីកន្លែងចុះចតឧទ្ធម្ភាគចក្រ, ផ្ទះ, សួនច្បារ និងស្តូបអនុស្សាវរីយ៍បុរីអូរស្វាយ។ ខ្ញុំស្គាល់ស្ថាបត្យករចំនួន២រូប ដែលជាអ្នកសាងសង់រាល់សំណង់នៅបុរីអូរស្វាយនាពេលនោះ។ ស្ថាបត្យករឈ្មោះ ឯក ម៉េង គឺជានាយទាហានរបបសង្គមរាស្ត្រនិយម និងជាអ្នកសាងសង់ «ស្តូបអនុស្សាវរីយ៍បុរីអូរស្វាយ» និងសួនច្បារ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរំលំ ស្ថាបត្យករ ឯក ម៉េង បានផ្លាស់ទីលំនៅមករស់នៅទីក្រុងភ្នំពេញ និងបានស្លាប់ជាច្រើនឆ្នាំមុន។ ចំណែកឯស្ថាបត្យករម្នាក់ទៀតឈ្មោះ ទូក ឆេង ដែលជាអ្នកសាងសង់ផ្ទះសម្រាប់និគមជន និងបានស្លាប់ដោយជរាភាពកាលពីប៉ុន្មានឆ្នាំមុន។

នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៦៨ សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ យាងចុះមកសម្ពោធសមិទ្ធផលនៅបុរីអូរស្វាយ។ ខ្ញុំ និងប្រពន្ធរួមទាំងប្រជាជនរាប់ពាន់នាក់បានចូលរួមព្រះរាជដំណើរយាងមកសម្ពោធសមិទ្ធផលរបស់ព្រះអង្គ។ សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ យាងមកដល់នៅវេលាម៉ោងប្រហែល៩ព្រឹក តាមឧទ្ធម្ភាគចក្រចំនួន៣គ្រឿង និងចុះចតនៅទីកន្លែងចុះចតឧទ្ធម្ភាគចក្រ។ បន្ទាប់មក សម្តេចព្រះនរោត្តម




ទាវ ឆុន ថតជាមួយប្រពន្ធ កូន និងចៅរបស់គាត់ នៅផ្ទះរបស់គាត់ស្ថិតនៅក្នុងភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សីហនុ បរមរតនកោដ្ឋ យាងតាមក្បួនព្រះទីនាំងរថយន្តចំនួន៣គ្រឿងមកកាន់ទីតាំងអង្គពិធី។ មុនព្រះអង្គមានព្រះរាជសុន្ទរកថា សម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ បានចែកក្រណាត់ស១ដុំ ប្រវែង២ម៉ែត្រ ដែលមានប៉ាក់ថា «សង្គមរាស្ត្រនិយម» សម្រាប់កាត់ជាអាវ ជូនដល់ប្រជារាស្ត្រដែលជាកូនចៅរបស់ព្រះអង្គ។ ខ្ញុំ និងប្រពន្ធទទួលបានក្រណាត់សម្នាក់១ដុំ និងបានចាប់ព្រះហត្ថរបស់សម្តេចព្រះ នរោត្តម សីហនុ បរមរតនកោដ្ឋ។ យើងខ្ញុំពិតជាមានចិត្តសប្បាយរីករាយណាស់។ បន្ទាប់មក សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ព្រះអង្គមានព្រះរាជសុន្ទរកថាជិត១ម៉ោង និងបន្តយាងចុះទតតាមផ្ទះរបស់និគមជននៅបុរីអូរស្វាយ។ ខ្ញុំនិងគ្រួសារបន្តប្រកបរបរធ្វើស្រែចម្ការ និងរស់នៅជាធម្មតារហូតដល់ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ បរមរតនកោដ្ឋ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ទើបខ្ញុំនិងគ្រួសាររួមទាំងប្រជាពលរដ្ឋផ្សេងទៀតនៅបុរីអូរស្វាយទទួលរងគ្រោះដោយសារតែការទម្លាក់គ្រាប់បែក និងក្រោយមកទៀតការចាប់យកទៅសម្លាប់នៅក្នុងរបបខ្មែរក្រហម។

ប៉ុន្មានខែបន្ទាប់ពីរដ្ឋប្រហារ លន់ នល់, កងទ័ពខ្មែរក្រហមបានចូលមកគ្រប់គ្រងបុរីអូរស្វាយ។ ដោយសារតែវត្តមានកងទ័ពរំដោះខ្មែរក្រហម ទើបមានការចាប់ផ្តើមទម្លាក់គ្រាប់បែកពីកងទ័ពសហរដ្ឋអាមេរិក និងទាហានលន់ នល់។ ការទម្លាក់គ្រាប់បែកយ៉ាងសន្ធឹកសន្ធាប់នៅបុរីអូរស្វាយ បានបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ និងសំណង់អាគារ ជាច្រើន។ ខ្ញុំឮដំណឹងថា ទាហាន លន់ នល់ មានគម្រោងទម្លាក់គ្រាប់បែក៣០០យប់ ៣០០ថ្ងៃ។ បុរីអូរស្វាយក្រោយមកត្រូវបានប្រែក្លាយទៅជាតំបន់ប្រយុទ្ធរវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម។ ការប្រយុទ្ធ និងការទម្លាក់គ្រាប់បែកបន្តរហូតដល់ឆ្នាំ១៩៧៤។ ខ្ញុំ និងគ្រួសារមិនបានរត់គេចខ្លួនទៅណានោះទេ។ នៅឆ្នាំ១៩៧៤ ខ្ញុំនិងគ្រួសារត្រូវបានខ្មែរក្រហមដាក់ឲ្យធ្វើការងារនៅកងប្រវាស់ដៃរហូតដល់ឆ្នាំ១៩៧៥។

នៅពេលដែលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំឃើញមានការមកដល់នៃប្រជាជន ១៧ មេសា ប្រហែល៥-៦ គ្រួសារ នៅបុរីអូរស្វាយ នៅខែមិថុនា។ ប្រជាជន ១៧ មេសា ភាគច្រើនបានស្លាប់បាត់បង់ជីវិតដោយសារតែជំងឺគ្រុនចាញ់ កង្វះអាហារូបត្ថម្ភ ឬជំងឺគ្មានថ្នាំព្យាបាល។ ចំណែកឯខ្លះទៀត ត្រូវបានសម្លាប់ដោយការចោទប្រកាន់ថា ជាភ្នាក់ងារសេអ៊ីអា។ នៅឆ្នាំ១៩៧៦ សហករណ៍ត្រូវបានបង្កើត ហើយប្រជាជននៅអូរស្វាយ ត្រូវបានចល័តទៅធ្វើការងារឆ្ងាយពីភូមិ និងបង្ខំឲ្យធ្វើការហួសកម្លាំងនៅតាមការដ្ឋាន។ បុរីអូរស្វាយត្រូវបានបំបែកជា២ សហករណ៍។ សហករណ៍ទី១មានប្រជាជនប្រហែល១៨គ្រួសារ និងមានប្រធានក្តាប់រួមឈ្មោះ មិត្ត គិ ចំណែកឯសហករណ៍ទី២ មានប្រជាជនប្រហែល២០គ្រួសារ និងមានមិត្ត សឿន ជាប្រធាន។

នៅឆ្នាំ១៩៧៧ ប្រពន្ធខ្ញុំបានបង្កើតកូនប្រុសម្នាក់។ ខ្មែរក្រហមមិនយោគយល់ទេ គឺប្រើឲ្យប្រពន្ធខ្ញុំធ្វើការស្រាល។ ដូចជាបុកអង្ករ ដែលនៅពេលនោះគាត់ទើបតែសម្រាលកូនបានរយៈពេល៧ថ្ងៃ។ ខ្ញុំត្រូវបានបញ្ជូនទៅលើកទំនប់នៅអូរពួក ស្ថិតនៅក្នុងស្រុកសេសាន ដែលជាទំនប់តំបន់។ ខ្ញុំទទួលបានរបបអាហារមិនគ្រប់គ្រាន់ និងធ្វើការលើកទំនប់គ្មានពេលសម្រាក។ នៅឆ្នាំ១៩៧៨ ខ្ញុំបានត្រឡប់មកនៅភូមិវិញ។ មិនយូរប៉ុន្មាន គឺនៅពាក់កណ្តាលឆ្នាំ ១៩៧៨ ប្រជាជនទាំងអស់នៅបុរីអូរស្វាយ ត្រូវបានខ្មែរក្រហមជម្លៀសចេញទៅនៅខាងកើតទន្លេសេកុង។ បន្ទាប់មក ខ្មែរក្រហមចាប់ផ្តើមសើរើប្រវត្តិរូបនិគមជនរបស់សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ។ ខ្ញុំ និងគ្រួសារ រួមទាំងប្រជាជនផ្សេងទៀត ដែលត្រូវបានរកឃើញថាជានិគមជនរបបសង្គមរាស្ត្រនិយម ត្រូវបានខ្មែរក្រហមប្រាប់ឲ្យជីករណ្តៅ និងប្រាប់ថាដើម្បីសម្រាប់ជាលេណដ្ឋានការពារខ្លួនពីការបាញ់គ្រាប់ផ្លោងនៅក្នុងរណ្តៅនោះ។ ប៉ុន្តែតាមពិតទៅ រណ្តៅដែលយើងកំពុងតែជីកនេះ គឺសម្រាប់ខ្មែរក្រហមសម្លាប់ និងកប់និគមជនរបបសង្គមរាស្ត្រនិយមទៅវិញនោះទេ។ ជាសំណាងល្អ នៅពេលដែលខ្ញុំ និងគ្រួសារនិគមជនផ្សេងទៀតកំពុងតែជីករណ្តៅ កងទ័ពខ្មែរក្រហមដែលវាយចាញ់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានរត់ និងប្រាប់ឲ្យយើងរត់គេចចេញពីកន្លែងនោះ។ ខ្ញុំនិងគ្រួសារ មិនបានរត់តាមកងទ័ពខ្មែរក្រហមដែលរត់គេចនោះទេ គឺយើងបានវិលត្រឡប់មករស់នៅភូមិវិញ។

នៅឆ្នាំ១៩៨០ ខ្ញុំត្រូវបានជ្រើសរើសឲ្យធ្វើជាមេភូមិ និងបន្តជាមេឃុំ អស់រយៈពេល៧ឆ្នាំ ទើបខ្ញុំចូលនិវត្តន៍។ បន្ទាប់ពីចូលនិវត្តន៍ ខ្ញុំមិនអាចធ្វើអ្វីបានច្រើននោះទេ ពីព្រោះតែជរាភាព។ នៅថ្ងៃនេះ ខ្ញុំសប្បាយរីករាយដែលទទួលបានការពិនិត្យសុខភាពបឋម និងចូលរួមវេទិកាណែនាំអំពីការថែទាំសុខភាព និងអាចនិយាយចែករំលែកបទពិសោធន៍ជីវិតរបស់ខ្លួនជាមួយក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។



តាវ៉ នុន ចូលរួមវេទិកាអប់រំអំពីសុខភាពដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជាយ ហ៊ុយ អតីតខ្មែរសដែលជាចលនាតស៊ូប្រឆាំងខ្មែរក្រហម

ស្រេង លីជា



ជាយ ហ៊ុយ ចូលរួមវេទិកាអប់រំអំពីសុខភាពដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ជាយ ហ៊ុយ អាយុ៦៨ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មានស្រុកកំណើតនៅស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ខ្ញុំមានឪពុកឈ្មោះ សៅ សរី និងម្តាយឈ្មោះ គក មែក។ ខ្ញុំមានបងប្អូនចំនួន៩ នាក់ គឺស្រី៥នាក់ និងប្រុស៤នាក់ ហើយខ្ញុំគឺជាកូនទី៤។ ខ្ញុំមានកូនចំនួន៥ នាក់ គឺស្រី២នាក់ និងប្រុស៣នាក់។

ខ្ញុំបានរៀនត្រឹមថ្នាក់ទី១០ពីសង្គមចាស់។ បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ខ្ញុំនៅក្មេងនៅឡើយ។ ពេលនោះខ្ញុំរៀនផងគេចគ្រាប់ផង។ ខ្ញុំរៀននៅក្រោមផ្ទះប្រជាជន ប៉ុន្តែមិនបានរៀនជាប់លាប់ទេ ព្រោះមានការទម្លាក់គ្រាប់បែក ហើយម្យ៉ាងទៀត មិនមានសម្ភារសិក្សាគ្រប់គ្រាន់។ ឪពុកម្តាយរបស់ខ្ញុំបានជីកលេណដ្ឋានដើម្បីលាក់ខ្លួន។ ខ្ញុំនៅក្មេងមិនសូវភ័យខ្លាចទេ ព្រោះនៅពេលមានការទម្លាក់គ្រាប់បែកមកម្តងៗ ខ្ញុំតែងចេញទៅមើល។ ខ្ញុំបានឃើញរណ្តៅគ្រាប់ធំៗ នៅក្នុង

ភូមិដែលខ្ញុំរស់នៅ។ ពេលទម្លាក់គ្រាប់បែកនោះ ក៏បណ្តាលឲ្យប្រជាជននៅក្នុងភូមិស្លាប់ និងរងរបួសជាច្រើននាក់ដែរ។

កងទ័ពខ្មែរក្រហមបានចូលមកក្នុងភូមិ នៅឆ្នាំ១៩៧៥ ដោយមានប្រជាជននាំគ្នាអបអរនឹងជ័យជម្នះនៃរបបដឹកនាំខ្មែរក្រហម ប៉ុន្តែផ្ទុយស្រឡះពីការរំពឹងទុករបស់ប្រជាជន ព្រោះត្រូវបានខ្មែរក្រហមគាបសង្កត់ជាងរបបមុនទៅទៀត។ ខ្មែរក្រហមបានបែងចែកប្រជាជនថ្មី និងប្រជាជនចាស់ ដោយប្រជាជនចាស់ គឺជាប្រជាជនដែលរស់នៅក្នុងមូលដ្ឋានរំដោះ និងគ្រប់គ្រងដោយខ្មែរក្រហមស្រាប់ ចំណែកប្រជាជនថ្មី គឺជាប្រជាជនដែលខ្មែរក្រហមជម្លៀសពីភ្នំពេញ ឬទីប្រជុំជនឲ្យមករស់នៅជនបទក្នុងឆ្នាំ១៩៧៥។ ប្រជាជនថ្មី ឬប្រជាជន១៧ មេសា ពិបាកជាងគេ ព្រោះគាត់ធ្លាប់រស់នៅស្រណុកសុខស្រួល ប៉ុន្តែដល់ពេលខ្មែរក្រហមបញ្ជូនទៅរស់នៅក្នុងព្រៃ គឺជួបប្រទះការអត់ឃ្លាន និងជំងឺផ្សេងៗ បណ្តាលឲ្យបាត់បង់ជីវិតជាច្រើននាក់។ ដោយឡែកប្រជាជនចាស់ក៏ពិបាកដូចគ្នាដែរ ប៉ុន្តែអាចស៊ូទ្រាំបាន។ កាលនោះខ្មែរក្រហមបើកអង្ករ៣គីឡូសម្រាប់បបរមួយខ្ទះត្នោត ក្រោយមកសល់ត្រឹមតែ១គីឡូសម្រាប់បបរក្នុងមួយខ្ទះ។ រហូតអស់អង្ករ ខ្មែរក្រហមក៏បើកសណ្តែក និងពោត សម្រាប់បបរលាយជាមួយគ្នា។ នៅពេលខ្លះខាតខ្លាំង ប្រធានកងឲ្យប្រជាជនដើររកអាហារហូបរៀងៗខ្លួន ប៉ុន្តែមិនអនុញ្ញាតឲ្យហូបមាន់ទា ដំឡូងដែលយើងដាំទេ ព្រោះរបស់ទាំងអស់នោះគឺជារបស់រួម។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំធ្វើការនៅកងចល័តរយៈពេល២ឆ្នាំ ដោយប្រធានកងប្រើខ្ញុំឲ្យរែកដីចាប់ពី១ម៉ែត្រគុប រហូតដល់២ម៉ែត្រគុបក្នុងមួយថ្ងៃ។ ខ្ញុំខិតខំតស៊ូរែកដីរហូតគ្រប់ផែនការកំណត់។ ការដ្ឋានដែលខ្ញុំរែកដីមានឈ្មោះថា ទំនប់បឹងក្រចាប់ ដែលមានកម្ពស់ប្រហែល៥០ម៉ែត្រ និងខ្នងទំនប់ប្រហែល២០ម៉ែត្រ ទៅ២៥ម៉ែត្រ។ បន្ទាប់មក ខ្មែរក្រហមបញ្ជូនខ្ញុំឲ្យទៅរែកដីទប់ទំនប់ និងជីកប្រឡាយនៅស្រុកក្រូចឆ្មារ ស្រុកដំបែរ ស្រុកទឹកជ្រៅ និងស្រុកឆ្លូង។

ក្រោយមក ខ្ញុំបានចូលរួមចលនាតស៊ូ ដែលមានឈ្មោះថា ខ្មែរស គឺជាចលនាតស៊ូដែលងើបឡើងប្រឆាំង និងរើបម្រះពីការគាបសង្កត់របស់ខ្មែរក្រហម ដោយចាប់ផ្តើមដំបូងមានសមាជិកតែ៦០នាក់ប៉ុណ្ណោះ។ ផែនការរបស់ក្រុមតស៊ូដំបូង គឺត្រូវហាមឃាត់មិនឲ្យខ្មែរក្រហមជម្លៀសប្រជាជនចេញពីខេត្តកំពង់ចាម ទៅខេត្តកំពង់ធំ ប៉ុន្តែសំណាងមិនល្អ ខ្ញុំត្រូវបានខ្មែរក្រហមចាប់ខ្លួនដោយសារខ្មែរក្រហមដឹងពីល្បិច និងការប្រើប្រាស់និមិត្តសញ្ញារបស់ក្រុមខ្ញុំនៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៨។ យោធាខ្មែរក្រហមបញ្ជូនខ្ញុំទៅឃុំឃាំងនៅស្ពួងរយៈពេលមួយខែ។ ខ្ញុំត្រូវបានឆ្មាំគុកវាយធ្វើបាប និងសួរចម្លើយមួយថ្ងៃ៣ដង។ កងសន្តិសុខគុកសួរខ្ញុំថា តើអ្នកដឹកនាំឈ្មោះអ្វី? តើឈរជើងនៅចំណុចណា? តើកម្លាំងមានប៉ុន្មាននាក់? តើមានអាវុធប៉ុន្មានដើម? កងសន្តិសុខបានធ្វើទារុណកម្មមកលើខ្ញុំដោយចងដៃខ្ញុំទាំងពីរទៅក្រោយជាប់នឹងកៅអី ហើយយកថង់ប្លាស្ទិកធំពណ៌សមកច្រកនឹងករបស់ខ្ញុំ ហើយយកទឹកមកចាក់ចូលក្នុងថង់ធ្វើឲ្យខ្ញុំថប់ដង្ហើម ឈ្លក់ និងផឹកទឹកនោះចូលក្នុងពោះ។ កងសួរចម្លើយធ្វើទារុណកម្មខ្ញុំបែបនេះរយៈពេលមួយខែ ហើយពេលខ្លះខ្ញុំចេញឈាមតាមរោមតាមភ្នែក។ ពេលខ្លះនៅពេលកងសួរចម្លើយដកថង់នោះចេញពីក្បាលខ្ញុំ ទឹកបានបាញ់ចេញពីពោះតាមមាត់របស់ខ្ញុំមានកម្ពស់ជាងមួយម៉ែត្រក៏មានដែរ។ ចំណែកក្បាលរបស់ខ្ញុំ កន្លែងណាក៏កងសួរចម្លើយវាយឡើងហើមពោរដែរ។ មិនត្រឹមតែប៉ុណ្ណោះ កងសួរចម្លើយបានយកដង្កាប់មកចាប់ភ្លៅរបស់ខ្ញុំ ហើយបើខ្ញុំនៅតែមិនឆ្លើយ កងសួរចម្លើយបានយកដង្កាប់នោះទៅកៀបប្រមុះខ្ញុំថែមទៀត។ នៅពេលគាបប្រមុះខ្ញុំភ្លាម ទឹកភ្នែកខ្ញុំហូរស្រក់មកតែម្តង ព្រោះខ្ញុំឈឺចាប់ខ្លាំងណាស់ ចំណែកដៃរបស់ខ្ញុំទាំងឆ្វេងទាំងស្តាំបានរលួយនៅសល់តែឆ្អឹង និងសរសៃខ្លះៗប៉ុណ្ណោះ ដោយសារឆ្មាំគុកចងរឹតណែនពេក។

ទោះបីយ៉ាងណា ខ្ញុំនៅតែមិនឆ្លើយប្រាប់កងសួរចម្លើយ ដើម្បីកុំឲ្យអ្នកផ្សេងទទួលទារុណកម្មដូចខ្ញុំៗ បើនិយាយពីរបបអាហារវិញក្នុងរយៈពេលមួយខែនោះ ខ្ញុំហូបតែទឹកបបរប៉ុណ្ណោះ ព្រោះដៃខ្ញុំកាន់ស្លាបព្រាមិនកើត ចំណែកជើងខ្ញុំក៏ជាប់ខ្នោះៗ ខ្ញុំរំកិលខ្លួនដើម្បីកៀរចានបបរមកកៀកនឹងខ្លួនម្តងបន្តិចៗរហូតដល់មាត់ទើបអាចបរិភោគបានៗ អស់រយៈពេលមួយខែទើបខ្ញុំឆ្លើយដាក់ឈ្មោះអ្នកនេះឈ្មោះអ្នកនោះថាជាមេកើយ ឬក៏ជាខ្សែរយៈរបស់ខ្ញុំ ប៉ុន្តែតាមអ្នកដែលខ្ញុំឆ្លើយដាក់ទាំងនោះសុទ្ធសឹងតែស្លាប់អស់ហើយៗ រយៈពេលមួយថ្ងៃបន្ទាប់ពីខ្ញុំសារភាព ស្រាប់តែកងទ័ពវៀតណាមចូលតាមព្រំដែន ចំណែកយោធាខ្មែរក្រហមបានរត់គេចខ្លួនអស់ៗ អ្នកទោសទាំង៥៦នាក់ រួមទាំងខ្ញុំ ក៏បានរកវិធីសាស្ត្រដោះខ្នោះដែលបានជាប់នៅនឹងជើងៗ ខ្ញុំបានរួចពីគុក ក៏ទៅនៅភូមិ ស្រាប់តែអ្នកភូមិបានដេញខ្ញុំចេញដោយចោទខ្ញុំថាគឺជាជនបង្កប់របស់ខ្មែរក្រហមៗ ទោះជាយ៉ាងណា ខ្ញុំបន្តរស់នៅក្នុងភូមិបានមួយរយៈ ទើបខាងភូមិបញ្ជូនខ្ញុំទៅព្យាបាលដៃនៅវៀតណាមរយៈពេលមួយឆ្នាំ រហូតបានជាសះស្បើយទើបវិញត្រឡប់មកជួបជុំបងប្អូនក្រុមគ្រួសារវិញៗ



ជាយ ហ៊ុយ ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហមដល់ ស្រេង លីដា អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា អំឡុងពេលចូលរួមវេទិកាអប់រំអំពីសុខភាពដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែងៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកបុរីអូរស្វាយ សែនជ័យ ទទួលបានការពិនិត្យសុខភាពបឋមជាលើកទី៣

**ស៊ាង ចិន្តា**



ក្រុមគ្រូពេទ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះពិនិត្យសុខភាពបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





ចាប់ពីថ្ងៃទី៦ ដល់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង និងមន្ទីរពេទ្យ ខេរី ត្បូងឃ្មុំ ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) រៀបចំវេទិកាពិនិត្យសុខភាពបឋមជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម សរុបចំនួន ២០០នាក់បន្ថែមទៀត នៅមណ្ឌលសុខភាព ព្រះនរោត្តម សីហនុរាជា និងសម្តេចព្រះវររាជមាតា នរោត្តម មុនីនាថ សីហនុ អូរស្វាយ នៅឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង។

វេទិកាពិនិត្យសុខភាពបឋមនេះធ្វើឡើងក្នុងគោលបំណងមិនត្រឹមតែផ្តល់ការពិនិត្យសុខភាពបឋមជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលរស់នៅទីដាច់ស្រយាល និងកំពុងប្រឈមបញ្ហាសុខភាព និងផ្តល់ការណែនាំអំពីការថែទាំសុខភាព ប៉ុន្តែថែមទាំងផ្តល់ពេលវេលាដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីជួបជុំ និងនិយាយចែក

រំលែកអំពីបទពិសោធន៍របស់ខ្លួនក្នុងរបបខ្មែរក្រហម។

ខាងក្រោមនេះ គឺជាការនិយាយចែករំលែកអំពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលទទួលបានការពិនិត្យសុខភាពបឋម៖

ខ្ញុំឈ្មោះ **ខែក គឹមឈុន** អាយុ៧១ឆ្នាំ កើតនៅភូមិក្រាំងម៉ាយ ឃុំស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។ ខ្ញុំរៀបការប្រពន្ធឈ្មោះ កៅ ប៊ុននី និងមានកូនប្រុសស្រីចំនួន៧នាក់ គឺប្រុស៤ និងស្រី៣នាក់។ បច្ចុប្បន្ននេះ ខ្ញុំរស់នៅភូមិបុរីអូរស្វាយ ឃុំបុរីអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ឪពុកខ្ញុំឈ្មោះ ឡុង និងម្តាយឈ្មោះ សុន។ ខ្ញុំមានបងប្អូនចំនួន៨នាក់។ នៅវ័យកុមារ ខ្ញុំរៀនសូត្រនៅសាលាបឋមសិក្សាក្រាំងម៉ាយរហូតដល់ថ្នាក់ទី១០ចាស់ ទើបខ្ញុំឈប់រៀន ព្រោះពេលនោះរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ បានកើតឡើង។ ខ្ញុំមកជួយធ្វើការងារឪពុកម្តាយនៅផ្ទះ និងចម្ការ។ នៅចុងនៅឆ្នាំ១៩៧០ ខ្ញុំធ្វើជាកងស្ម័គ្រចិត្ត ប្អូកងឈ្លបជាមួយខាងកងទ័ពរំដោះខ្មែរក្រហមនៅមូលដ្ឋាន។ បន្ទាប់មក ខ្ញុំឃើញមានយន្តហោះមកទម្លាក់គ្រាប់បែកនៅតាមបណ្តាភូមិបណ្តាលឲ្យខូចខាត និងឆេះផ្ទះអ្នកស្រុក។ ការទម្លាក់គ្រាប់បែកកើតឡើងទាំងព្រឹកទាំងថ្ងៃទាំងយប់។ នៅពេលដែលខ្ញុំបើកទូក ខ្ញុំរត់គេចស្ទើរតែមិនចង់ទាន់។

បន្ទាប់ពីពេលនោះមក ខ្ញុំត្រូវបានចាប់ខ្លួន និងចោទថាជា «ខ្មែរស»។ ខ្ញុំត្រូវបានចាប់មកដាក់ឃុំឃាំងនៅឃ្លាំងប្រាក់ នៅខាងលិចមន្ទីរពេទ្យអស់រយៈពេល១ខែកន្លះ។ ខ្ញុំមិនត្រូវបានធ្វើទារុណកម្មនោះទេ គឺគ្រាន់តែសួរចម្លើយចំនួន២ដង។ ក្រោយពេលខ្ញុំត្រូវបានដោះលែងពីកន្លែងសួរចម្លើយ ខ្ញុំកាន់តែពិបាកខ្លាំង។ ខ្ញុំធ្វើការធម្មតានៅក្នុងសហករណ៍ គឺត្រូវច្រូតស្រូវ។ តមកទៀត ខ្ញុំចូលមកធ្វើការងារនៅកងគមនាគមន៍ ជួសជុលស្ពានចាប់ពីស្រែពកទៅខេត្តរតនគិរី រយៈពេល១ឆ្នាំជាង ដែលមានគ្នាចំនួន៤០នាក់ គឺប្រធានកងឈ្មោះ តាវង្ស។ នៅពេលដែលប្រទេសត្រូវបានរំដោះនៅដើមឆ្នាំ១៩៧៩ ខ្ញុំត្រូវបានចាប់សួរនាំអំពីការងារ។ ខ្ញុំប្រាប់គេថា ជាកងចល័តច្រូតស្រូវតែប៉ុណ្ណោះ។ អ្វីដែលខ្ញុំចងចាំមិនភ្លេចពីមុននោះគឺសង្គ្រាម និងស្ទើរតែត្រូវបានសម្លាប់ដោយខ្មែរក្រហម ដែលខ្ញុំត្រូវធ្វើកិច្ចសន្យាកុំឲ្យមានកំហុសម្តងទៀត។ ខ្ញុំចង់ឲ្យក្មេងជំនាន់ក្រោយដឹងពីផលវិបាកនៃសង្គ្រាម, ការអត់ឃ្លាន និងការកាប់សម្លាប់ដោយរបបខ្មែរក្រហម។ ខ្ញុំធ្លាប់បានប្រាប់រឿងរ៉ាវលំបាកវេទនានៅក្នុងរបបខ្មែរក្រហមទៅកាន់កូនៗចៅៗរបស់ខ្ញុំ តែកូនចៅខ្ញុំមិនជឿទេ។ សព្វថ្ងៃសុខភាពរបស់អ្នករស់រានមានជីវិតពីខ្មែរក្រហម គឺមានសារសំខាន់ណាស់ ព្រោះមានវ័យកាន់តែចាស់។ ខ្ញុំសប្បាយចិត្តនៅពេលដែលទទួលបានការពិនិត្យសុខភាពបឋមនេះ។ ខ្ញុំសូមផ្តាំផ្ញើឲ្យកូនចៅជំនាន់ក្រោយខិតខំរៀនសូត្រ និងចូលរួមការអភិវឌ្ឍន៍ប្រទេសជាតិ។

ខ្ញុំឈ្មោះ **ភួយ ខាំផែន** អាយុ៧៨ឆ្នាំ រស់នៅភូមិព្រែកក្មៅ ឃុំបុរីអូរស្វាយ ស្រុកបុរីអូរស្វាយ ខេត្តស្ទឹងត្រែង។ ខ្ញុំរៀបការប្រពន្ធឈ្មោះ បូរ ទន់ និងមានកូនប្រុសស្រី២នាក់។ ខ្ញុំមានបងប្អូនសរុបចំនួន ៤នាក់ (ស្លាប់៣នាក់)។ នៅពីក្មេង ខ្ញុំចូលរៀននៅវត្តអង្គរ ហើយខ្ញុំរៀនបានត្រឹមថ្នាក់ទី១២ចាស់។ ខ្ញុំរៀនពីរវេន ពេលយប់មករៀននៅវត្ត និងពេលថ្ងៃរៀននៅសាលា។ នៅអាយុ១៦ឆ្នាំ ខ្ញុំចូលធ្វើជាទាហានលន់ នល់។ ខ្ញុំបានឆ្លងកាត់សមរភូមិជាច្រើនរួមមានខេត្តតាកែវ ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។

ក្រោយមកទៀតខ្ញុំរត់ភៀសខ្លួនទៅរស់នៅឡាវ។ ខ្មែរមិនអាចរស់នៅឡាវបានស្រួលទេគឺត្រូវធ្វើទាហានឲ្យឡាវសិន។ ខ្ញុំប្រាប់ឡាវថា ខ្ញុំភៀសខ្លួន ដើម្បីស្នាក់អាស្រ័យ ប៉ុន្តែឡាវមិនយល់ព្រម។ ប្រហែលនៅឆ្នាំ១៩៧១ ខ្ញុំធ្វើទាហាននៅឡាវដើម្បីបានបាយហូប ចំណែកឯខ្លះទៀតបានធ្វើជាគ្រូបង្រៀន។ នៅចុងឆ្នាំ១៩៧៨ ខ្ញុំវិលត្រឡប់មកខ្មែរវិញ គឺបន្ទាប់ពីកងទ័ពខ្មែរក្រហមត្រូវបានវាយបណ្តេញដោយ

កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដឹកនាំដោយសម្តេច ហ៊ុន សែន សម្តេច ជា ស៊ីម និងសម្តេច ហេង សំរិន។ ខ្ញុំក៏បានចូលរួមជាមួយកងទ័ពរណសិរ្ស ដែលខ្ញុំបានវាយចូលមកតាមព្រះរំកិល និងមុំបី រួចត្រឡប់ទៅនៅអង្គភាពនៅស្ទឹងត្រែង។ នៅសម័យនោះ គឺមិនទាន់មានការចាយលុយនៅឡើយទេ។ ខ្ញុំមានប្រពន្ធកូននៅឡាវ។ ខ្ញុំឡើងចុះទៅលេងប្រពន្ធកូន ប៉ុន្តែក្រោយមកក៏រស់នៅបែកគ្នា។ នៅពេលដែលខ្ញុំទទួលបានការពិនិត្យសុខភាពរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំពិតជាសប្បាយចិត្តណាស់ ដែលនេះគឺជាលើកទី១របស់ខ្ញុំ។ សូមជូនពរឲ្យក្រុមការងារ មន្ត្រីរាជការ និងប្រជាជនទាំងអស់ មានសុខភាពល្អ និងរស់នៅសុខសាន្ត។

ខ្ញុំឈ្មោះ **កើត ទ៉ាន់ថុន** អាយុ៧០ឆ្នាំ កើតនៅភូមិថ្លាត ឃុំថ្លាត ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង។ ខ្ញុំរៀបការប្រពន្ធឈ្មោះ សាន នាង និងមានកូន៨នាក់។ ឪពុកខ្ញុំឈ្មោះ កើត និងម្តាយឈ្មោះ ជា វណ្ណា។ នៅពីក្មេង ខ្ញុំចូលរៀនបានត្រឹមថ្នាក់ទី៧ សង្គមចាស់។ នៅពេលដែលសង្គ្រាមផ្ទុះឡើងនៅទសវត្សរ៍ឆ្នាំ១៩៧០ ខ្ញុំរស់នៅភូមិកំណើតរបស់ខ្ញុំ ដែលការទម្លាក់គ្រាប់បែកបានចាប់ផ្តើម និងបន្តរហូតដល់ឆ្នាំ១៩៧៣។ នៅពេលដែលមានយន្តហោះមកទម្លាក់គ្រាប់បែកម្តងៗ ខ្ញុំរត់ចូលក្នុងរណ្តៅ។ នៅសម័យខ្មែរក្រហម ខ្ញុំធ្វើការនៅក្នុងកងដឹកជញ្ជូនរហូតដល់ចុងឆ្នាំ១៩៧៨។ ខ្ញុំបន្តមករស់នៅភូមិកំណើតរបស់ខ្ញុំវិញនៅឆ្នាំ១៩៨២ រហូតមកដល់សព្វថ្ងៃ។ សូមអរគុណដល់អាជ្ញាធរមូលដ្ឋាន និងក្រុមការងារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលរៀបចំអ្នកគ្រូពេទ្យចុះពិនិត្យសុខភាពដល់ខ្ញុំនៅផ្ទះរបស់ខ្ញុំផ្ទាល់តែម្តង។

រដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង បានថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការរៀបចំវេទិកាពិនិត្យសុខភាពបឋមជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំង៣លើក គឺចាប់ពីខែមីនា ដល់ខែមិថុនា ដែលមានចំនួនសរុបទាំងអស់គឺ៦០០នាក់។





លោក លី មីនា អភិបាលស្រុកបុរីអូរស្វាយសែនជ័យ សំណេះសំណាលនិងសួរសុខទុក្ខអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានអញ្ជើញមកចូលរួមវេទិកាអប់រំអំពីសុខភាព និងពិនិត្យសុខភាពដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ស្ថិតនៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកា

## ថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)៖ ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម និងប្រភេទឯកសារ ដល់អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តកំពង់ចាម

**សាំង ចាន់ធូ**



មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមរៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)៖ ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម និងប្រភេទឯកសារដល់អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤ អ្នកស្រាវជ្រាវវ័យក្មេង ដែលជាអ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាម ចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ«ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម»។ វេទិកាថ្នាក់រៀននេះធ្វើឡើងក្នុងគោលបំណងដើម្បីបង្កើនចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់យុវជន-យុវនារីជំនាន់ក្រោយ និងអំពីបទពិសោធន៍របស់ប្រជាជនដែលត្រូវបានជម្លៀសដោយបង្ខំ បន្ទាប់ពីកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

មុនការចាប់ផ្តើមបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម លើកឡើងថា «ការនិយាយ ការស្តាប់ និងការសរសេររឿងរ៉ាវរបស់អ្នករស់រានមានជីវិតពី



មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមរៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)៖ ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម និងប្រភេទឯកសារដល់អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

របបខ្មែរក្រហម មានសារសំខាន់ខ្លាំងណាស់ ព្រោះបានចូលរួមចំណែកក្នុងការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម និងការពារកុំឲ្យរបបប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀត»។ បន្ទាប់មក លោក ស៊ាង ចិន្តា ធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងរំលេចព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ រួមមានរដ្ឋប្រហាររបស់ លន់ នល់ នៅឆ្នាំ១៩៧០, សង្គ្រាមជិត៥ឆ្នាំរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម, ការឡើងកាន់អំណាចរបស់ខ្មែរក្រហម ការជម្លៀសប្រជាជនដោយបង្ខំ និងជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបខ្មែរក្រហម។ ដើម្បីយល់ច្បាស់អំពីការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងរបបខ្មែរក្រហម លោក ស៊ាង ចិន្តា ពន្យល់បន្ថែមអំពីវណ្ណៈសង្គមថ្មីពីរក្នុងរបបខ្មែរកហម ដោយបានសង្កត់ទៅលើការបែងចែកប្រជាជនទៅជា៣ក្រុម នៅក្នុងរបបខ្មែរក្រហម រួមមាន៖

១) **ប្រជាជនចាស់** (ឬហៅថា ប្រជាជន៧០) គឺជាប្រជាជនរស់នៅតំបន់ដែលកងទ័ពរំដោះខ្មែរក្រហមបានរំដោះចាប់តាំងពីឆ្នាំ១៩៧០។

២) **ប្រជាជនកណ្តាល** (ហៅថា ប្រជាជន៧៣) គឺជាប្រជាជនរស់នៅតំបន់ដែលកងទ័ពរំដោះខ្មែរក្រហមបានវាយយកមកគ្រប់គ្រងនៅឆ្នាំ១៩៧៣។ ជាក់ស្តែងនៅឆ្នាំ១៩៧៣ កងទ័ពខ្មែរក្រហមវាយចូលទីរួមខេត្តកំពង់ចាម និងបានរំដោះផ្នែកខ្លះនៃទីរួមខេត្ត។ ប្រជាជនដែលត្រូវបានកងទ័ពខ្មែរក្រហមគ្រប់គ្រងនៅទីរួមខេត្តកំពង់ចាម ត្រូវបានជម្លៀសចេញពីផ្ទះសម្បែងរបស់ខ្លួនទៅទីកន្លែងផ្សេង ឬភូមិកំណើតរបស់ខ្លួន។ ប្រជាជនជម្លៀសចេញពីទីរួមខេត្តកំពង់ចាមនាពេលនោះ ត្រូវបានចាត់ទុកថា ជាប្រជាជនកណ្តាល ឬប្រជាជន៧៣។

៣) **ប្រជាជន ៧៥ ឬប្រជាជន ១៧ មេសា** គឺជាប្រជាជនដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងៗមកកាន់ភូមិនានា បន្ទាប់ពីខ្មែរក្រហមបានឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ប្រជាជន៧៥ ឬប្រជាជន១៧មេសា ទទួលរងការធ្វើទុក្ខបុកម្នេញ និងការកាប់សម្លាប់ច្រើនជាងគេ។

នៅចុងបញ្ចប់នៃបទបង្ហាញ លោក ស៊ាង ចិន្តា ពន្យល់អំពីនិយមន័យ និងវិធីសាស្ត្រទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងអំពើប្រល័យពូជសាសន៍។ នៅក្នុងឱកាសនោះ អ្នកស្រាវជ្រាវវ័យក្មេងបន្តកិច្ចពិភាក្សាទៅលើប្រធានបទ «ការជម្លៀសប្រជាជនដោយបង្ខំ»

ដើម្បីបន្ថែមការយល់ដឹង ការគិតពិចារណា និងអាណិតអាសូរដល់ទុក្ខលំបាករបស់ប្រជាជនជម្លៀសក្រោមកម្ដៅថ្ងៃក្ដៅហួតហែង។ កម្មវិធីបន្ទាប់ គឺបទបង្ហាញអំពីប្រភេទឯកសារ (ឯកសារដើម និងឯកសារបន្ទាប់បន្សំ)។ ការយល់ដឹងអំពីប្រភេទឯកសារ គឺមានសារសំខាន់សម្រាប់អ្នកស្រាវជ្រាវវ័យក្មេងក្នុងការប្រើប្រាស់ដោយមានប្រសិទ្ធភាព និងយ៉ាងត្រឹមត្រូវ។ បន្ទាប់មក អ្នកស្រាវជ្រាវវ័យក្មេងទាំងអស់ត្រូវបានបែងចែកក្រុមស្រាវជ្រាវចំនួន៨ក្រុម និងទទួលបានប្រធានបទស្រាវជ្រាវសម្រាប់ក្រុមនីមួយៗ រួមទាំងឯកសារ និងសៀវភៅមួយចំនួន។ «ការយកមេរៀនជាទ្រឹស្ដីដើម្បីចុះអនុវត្តផ្ទាល់» គឺជាវិធីសាស្ត្រដ៏ល្អមួយសម្រាប់អ្នកស្រាវជ្រាវវ័យក្មេងអាចទទួលបានចំណេះដឹងបន្ថែម និងបទពិសោធន៍ផ្ទាល់ខ្លួន។

បន្ទាប់ពីចប់វេទិកាថ្នាក់រៀន អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាម បានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖

**វ៉ែម ប៊ុនរ៉ុង** អ្នកស្រាវជ្រាវវ័យក្មេង និងជាអ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាម រៀបរាប់ថា «វេទិកាថ្នាក់រៀននេះ គឺមានសារសំខាន់ណាស់សម្រាប់ខ្ញុំដើម្បីយល់ដឹងបន្ថែមអំពីរបបខ្មែរក្រហម ក៏ដូចជាការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងដំណាក់កាលទី៣។ ខ្មែរក្រហមបានបង្ខំប្រជាជនចាកចេញពីផ្ទះដោយគ្មានមនោសញ្ចេតនាក្នុងខ្លួន និងមិនលើកលែងសូម្បីតែស្ត្រី កុមារ និងជនពិការ គឺជម្លៀសទាំងអស់។ ខ្ញុំក៏បានដឹងថា ការជម្លៀសរបស់ខ្មែរក្រហម មានទាំងថ្មើរជើង តាមរថយន្ត និងតាមរថភ្លើង។ ការជម្លៀសទាំងអស់នេះ គឺមិនងាយស្រួលនោះទេ គឺលំបាកវេទនាយ៉ាងខ្លាំង។ ប្រជាជនដែលត្រូវបានជម្លៀសនៅដំណាក់កាលទី៣ គឺជាប្រជាជនមកពីភូមិភាគបូព៌ា ដែលត្រូវធ្វើវិសុទ្ធកម្ម និងភាគច្រើនទទួលរងគ្រោះនៃការសម្លាប់រង្គាល។ ខ្ញុំធ្លាប់បានឮអំពីរបបខ្មែរក្រហមតាមរយៈការនិយាយប្រាប់ពីលោកតា លោកយាយ របស់ខ្ញុំ និងការរៀនសូត្រនៅសាលា។ ខ្ញុំនឹងយកអ្វីដែលខ្ញុំទទួលបាននៅពេលនេះទៅចែករំលែកនៅក្នុងបណ្ដាញសង្គម និងមិត្តភក្តិនៅសាលា ព្រមទាំងសិស្សប្អូន ដើម្បីឲ្យដឹងអំពីផលលំបាកអំពីរបបដ៏ខ្មៅងងឹតមួយនេះ និងចូលរួមការពារកុំឲ្យរបបនេះកើតឡើងជាថ្មីម្ដងទៀត»។

**រស់ លីដា** អ្នកស្រាវជ្រាវវ័យក្មេង និងជាអ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាម យល់ថា «ខ្ញុំសប្បាយរីករាយយ៉ាងខ្លាំងដែលបានចូលរួមវេទិកាថ្នាក់រៀនដែលជាផ្នែកមួយនៃកម្មវិធីដំណើរទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យសម្រាប់យុវជន ស្ដីពីការជម្លៀសប្រជាជនដោយបង្ខំ ដំណាក់កាលទី៣ ក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)» ដល់ខ្ញុំដែលកំពុងតែរៀនថ្នាក់ទី១២។ ខ្ញុំទទួលចំណេះដឹងប្រវត្តិសាស្ត្រខ្មែរក្រហមបន្ថែមពីវេទិកាថ្នាក់រៀននេះ ជាពិសេសគឺការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម។ ប្រជាជនរស់នៅក្នុងរបបខ្មែរក្រហមពិតជាវេទនា និងស្លាប់ជាច្រើនក្នុងស្ថានភាពលំបាក ដូចជា ការបង្ខំធ្វើការគ្មានពេលសម្រាក, ការហូបចុកមិនគ្រប់គ្រាន់, ការឈឺគ្មានថ្នាំព្យាបាល និងការចាប់យកទៅសម្លាប់»។





អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាម ឡើងសួរសំណួរ អំឡុងពេលចូលរួមវេទិកាថ្នាក់រៀនស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ៖ ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម និងប្រភេទឯកសារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាថ្នាក់រៀន ស្ដីពី «ការជម្លៀសដោយបង្ខំ» ក្នុងរបបខ្មែរក្រហម សម្រាប់អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ នៅសាលប្រជុំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ឈុំ រ៉ា



មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាថ្នាក់រៀន ស្ដីពី «ការជម្លៀសដោយបង្ខំ» ក្នុងរបបខ្មែរក្រហម សម្រាប់អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ នៅសាលប្រជុំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅរសៀលថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានរៀបចំវេទិកា ថ្នាក់រៀន ស្ដីពីការជម្លៀសប្រជាជនដោយបង្ខំនៅដំណាក់កាលទី៣ (ការជម្លៀសប្រជាជននៅភូមិភាគបូព៌ាទៅភាគភូមិពាយ័ព្យ រួមមាន ខេត្តពោធិ៍សាត់ និង បាត់ដំបង ចាប់ពីចុងឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨) និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍សម្រាប់អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំចំនួន៤៤នាក់ ក្នុងនោះមានស្រី១៩នាក់ នៅអាគារ CJCC នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ចាប់ផ្តើមបើកវេទិកាថ្នាក់រៀនលោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម បានស្នើសុំឲ្យអ្នកស្ម័គ្រចិត្តកម្ពុជា ទាំងអស់ ចែករំលែកនូវចំណេះដឹងដែលខ្លួនបានសិក្សារៀនសូត្រអំពីប្រវត្តិសាស្ត្រខ្មែរក្រហមជាមុនៗ បន្ទាប់ពីការចែករំលែកចំណេះដឹងរួចមក លោក ឡុង ដានី ក៏ផ្តល់ឱកាសឲ្យអ្នកស្ម័គ្រចិត្តសួរសំណួរទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម ដូចតទៅ ៖ ១) តើហេតុអ្វីបានខ្មែរក្រហមឡើងកាន់អំណាចបានងាយស្រួល? ២) តើហេតុអ្វីបានជាប្រទេសជិតខាងមិនជួយពេលដែលប្រទេសកម្ពុជាធ្លាក់ក្នុងសង្គ្រាម និងរបបខ្មែរក្រហម?

៣) តើហេតុអ្វីបានជារបបខ្មែរក្រហម ផ្តួលរំលំរបបសាធារណរដ្ឋខ្មែរបាន? ៤) តើក្នុងរបបខ្មែរក្រហមអង្គការបង្ខំឲ្យប្រជាជនធ្វើការអ្វីខ្លះ? ៥) តើនៅក្នុងរបបខ្មែរក្រហមមានការប្រើប្រាស់គ្រឿងយន្តសម្រាប់ធ្វើកសិកម្មដែរឬទេ? ៦) តើការកើតមានរបបខ្មែរក្រហមទាក់ទងនឹងប្រទេសជិតខាងដែរឬទេ? ៧) តើមេដឹកនាំខ្មែរក្រហមចង់បានអ្វី ទើបអនុវត្តគោលការណ៍៨ចំណុច? ៨) តើហេតុអ្វីបានជាខ្មែរក្រហមបញ្ជូនកងទ័ពទៅតាមព្រំដែនជាពិសេសប្រទេសវៀតណាម? ៩) តើនៅក្នុងរបបខ្មែរក្រហមប្រជាជនជួបការលំបាកអ្វីខ្លះ? ១០) តើខ្មែរក្រហមបណ្តុះបណ្តាលយុវជនយ៉ាងដូចម្តេច ទើបយុវជនហ៊ានសម្លាប់ឪពុកម្តាយដើម្បីអង្គការ? ១១) តើហេតុអ្វីបានជាកម្មាភិបាលជាន់ខ្ពស់នៅរបបខ្មែរក្រហមសង្ស័យលើប្រជាជននិងកម្មាភិបាលភូមិភាគបូព៌ា? ១២) តើហេតុអ្វីបានជាខ្មែរក្រហមស្អប់វៀតណាម? ១៣) តើនៅក្នុងរបបខ្មែរក្រហម ផលិតផលដែលផលិតបានយកទៅណា? ១៤) តើហេតុអ្វីខ្មែរក្រហមបោះពុម្ពលុយហើយមិនចាយ? ១៥) តើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទទួលបានប្រាក់បៀវត្សរ៍ដែរឬទេ?

រាល់សំណួរដែលទទួលបានពីអ្នកស្ម័គ្រចិត្តកម្ពុជាគឺលោក ឡុង ដានី ឆ្លើយបកស្រាយ និងធ្វើបទបង្ហាញជូនក្នុងវេទិកាថ្នាក់រៀនៗ ប៉ុន្តែចំណុចសំខាន់ក្នុងថ្នាក់រៀននាថ្ងៃនេះគឺ ផ្តោតលើប្រធានបទការជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាលទី៣ ក្នុងរបបខ្មែរក្រហមៗ លោក ឡុង ដានីបន្តថា កងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដោយដំបូងប្រជាជនមានភាពសប្បាយរីករាយពេលដឹងថា កងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ ឬហៅថារបប លន់ នល់ៗ ប៉ុន្តែមិនបានប៉ុន្មានម៉ោងផង ប្រជាជនប្តូរមកជាការភ័យខ្លាចៗ កងទ័ពខ្មែរក្រហមបាញ់គំរាម និងបង្ខំឲ្យប្រជាជនចាកចេញពីផ្ទះសម្បែងរយៈពេល៣ថ្ងៃៗ កងទ័ពខ្មែរក្រហមធ្វើគ្រប់បែបយ៉ាងដើម្បីឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញ មិនថាចាស់ជរា ក្មេងៗ ឬស្ត្រីមានផ្ទៃពោះជិតគ្រប់ខែនោះទេ ហើយនេះគឺជាការជម្លៀសដំណាក់កាលទី១ៗ ការជម្លៀសដំណាក់កាលទី២ គឺចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសប្រជាជនពីភូមិភាគនិរតី បស្ចិម ទៅភូមិភាគពាយ័ព្យ ដោយខ្មែរក្រហមដឹកប្រជាជនតាមរទេះគោ រថយន្ត ទូក និងកាណូតមកដាក់នៅតាមស្ថានីយរថភ្លើងនានា ដើម្បីជម្លៀសទៅកាន់គោលដៅភូមិភាគពាយ័ព្យៗ ការជម្លៀសដំណាក់កាលទី៣ គឺចាប់ពីចុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ដោយជម្លៀសប្រជាជនចេញពីភូមិភាគបូព៌ា នៅពេលដែលខ្មែរក្រហមបានប្រកាសសង្គ្រាមជាមួយវៀតណាម និងបានចោទកម្មាភិបាលភូមិភាគបូព៌ាថាជាជនក្បត់ៗ ខ្មែរក្រហមមានគោលដៅជម្លៀសប្រជាជនពីភូមិភាគបូព៌ាឲ្យអស់ៗ

ជម្រាបភ្ជាប់នឹងប្រធានបទខាងលើ គឺខ្មែរក្រហមយកផ្លូវរថភ្លើងជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហមៗ បន្ទាប់មកលោក ឡុង ដានីក៏បង្ហាញអ្នកស្ម័គ្រចិត្តកម្ពុជាពីដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើងពីស្ថានីយក្រុងភ្នំពេញឆ្ពោះទៅកាន់ស្ថានីយរថភ្លើងខេត្តកំពតៗ អ្នកស្ម័គ្រចិត្តកម្ពុជា ដែលបានចូលរួមក្នុងវេទិកាថ្នាក់រៀននៅថ្ងៃនេះ ត្រូវបែងចែកជាក្រុម ដើម្បីចុះទៅសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលជានារីកម្មករស្រែអំបិល នៅសង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត និងការដ្ឋានលើកទំនប់ម្លូប ស្ថិតនៅក្នុងឃុំនារាយណ៍ ស្រុកឈូក ខេត្តកំពតៗ អ្នកស្ម័គ្រចិត្តកម្ពុជានឹងត្រូវធ្វើដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើងនៅ ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៤ៗ

ខាងក្រោមនេះគឺជាចំណាប់អារម្មណ៍របស់អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ ក្នុងវេទិកាថ្នាក់រៀន៖

នាងខ្ញុំឈ្មោះ **យូ គីមលីញ** គឺជាសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែនក្តុលជម្រាវៗ ខ្ញុំមានអារម្មណ៍សប្បាយរីករាយជាខ្លាំង ដែលទទួលបានចំណេះដឹងថ្មីៗជាច្រើនទាក់ទងនឹងប្រវត្តិសាស្ត្រដឹ

ឈឺចាប់ ព្រៃផ្សៃ របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ លើសពីនេះទៅទៀត ថ្នាក់សិក្សានេះក៏បានបណ្ដុះស្មារតីនាងខ្ញុំផ្ទាល់ ក៏ដូចជាយុវជនដទៃទៀតឲ្យដឹងថា អំពើហិង្សាក៏ដូចជាការដឹកនាំតាមរបបផ្ដាច់ការ ធ្វើឲ្យប្រទេសជាតិធ្លាក់ចូលទៅក្នុងស្ថានភាពអួអាប់។

ខ្ញុំបាទឈ្មោះ **សិលា បញ្ញាវុធ** គឺជាសិស្សនៃវិទ្យាល័យ ជា ស៊ីម កណ្ដាលជ្រុំ ខេត្តត្បូងឃ្មុំ។ ថ្ងៃនេះ ខ្ញុំពិតជាមានការសប្បាយរីករាយជាខ្លាំង ដែលបានធ្វើដំណើរពីខេត្តត្បូងឃ្មុំមកកាន់ទីក្រុងភ្នំពេញ។ នៅតាមផ្លូវ ខ្ញុំបានជួបបងប្អូនសិស្សានុសិស្សជាច្រើន និងបានស្គាល់គ្នា។ ខ្ញុំក៏មានបញ្ហាបន្តិចបន្តួចដែរ ព្រោះមិត្តភក្តិដែលមកពីសាលាជាមួយគ្នាពុល ឡាន ហើយក្អួតជាច្រើនដង។ លុះមកដល់ភ្នំពេញ ខ្ញុំនិងអ្នកស្ម័គ្រចិត្តកម្ពុជា ទាំងអស់បានធ្វើដំណើរទៅកាន់សាលាភូមិន្ទភ្នំពេញដើម្បីចូលរួមវេទិកាថ្នាក់រៀន និងធ្វើការសំណេះសំណាល ជាមួយលោកគ្រូ ឡុង ដានី ដែលធ្វើបទបង្ហាញពីរបបខ្មែរក្រហម។

នាងខ្ញុំឈ្មោះ **អ៊ីម ចរិយា** គឺជាសិស្សមកពីវិទ្យាល័យក្រែក។ នាងខ្ញុំសប្បាយរីករាយ និងប្លែកអារម្មណ៍ដែលបានធ្វើដំណើរមកភ្នំពេញ និងបានជួបជុំអ្នកស្ម័គ្រចិត្តកម្ពុជាផ្សេងទៀត។ សម្រាប់វេទិកាថ្នាក់រៀននៅថ្ងៃនេះ លោកគ្រូ ឡុង ដានីបានធ្វើបទបង្ហាញ និងបង្រៀនអំពីរបបប្រល័យពូជសាសន៍ ធ្វើឲ្យនាងខ្ញុំយល់ដឹងកាន់តែច្បាស់។ ខ្ញុំសំណូមពរឲ្យមានថ្នាក់រៀនបែបនេះនៅពេលក្រោយៗទៀត។

ខ្ញុំបាទឈ្មោះ **ម៉ន ភារុណ** គឺជាសិស្សមកពីខេត្តត្បូងឃ្មុំ។ ខ្ញុំមានអារម្មណ៍រំភើបដែលបានចូលរួមវេទិកាថ្នាក់រៀនស្ដីអំពី ប្រវត្តិសាស្ត្រខ្មែរក្រហម ព្រោះដឹងពីរបបនេះកាន់តែច្បាស់ជាងមុន និងដឹងពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា។ ជាចុងក្រោយ ខ្ញុំសូមអរគុណលោក ឡុង ដានី និងក្រុមការងារដែលរៀបចំវេទិកាថ្នាក់រៀនបានយ៉ាងល្អ។



មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាថ្នាក់រៀន ស្ដីពី «ការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម» ដល់អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ នៅសាលប្រជុំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)






# ការិយាល័យព័ត៌មានសាធារណៈ




«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។







មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។







តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។




ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ




អ៊ីម៉ែល ៖ truthsampeou.r@dccam.org




សូមអរគុណ!

# ជីវិតកូនប្រុសពុកក្នុងគុកខ្មែរក្រហម (ត)

ហង្ស ឆាំឆាន

### ៤.១. ការសួរចម្លើយលើកទីពីរ

សួររហូតដល់ម៉ោង៦ល្ងាចទើបចប់។ ក្នុងចំណោមអ្នកទោសទាំងអស់មានម្នាក់ឈ្មោះ កែវ ពីគា ពេលគេសួរថានៅភ្នំពេញធ្វើអ្វី? គាត់ឆ្លើយកំបុតថា BGI អ្នកសួរថា BGI CIA និង KGB ដូចគ្នានឹងហើយក៏ចប់ទៅ។

### ៤.២. មូលហេតុត្រូវសម្លាប់អ្នករដ្ឋការ លន់ នល់

ព្រឹត្តិការណ៍សម្លាប់សន្តិសុខពីរនាក់គឺមិត្ត ណោត និង មិត្ត វ៉ន នៅគុកពោធិ៍បូរីបានក្លាយទៅជាមូលហេតុត្រូវសម្លាប់អ្នកទោសក្រោយ១៧ មេសា៧៥ ទាំងអស់។ ការសួរចម្លើយលើកទីពីរបានមួយថ្ងៃខ្ញុំ និងបងសុននិយាយគ្នាដោយសប្បាយចិត្តក្នុងពេលធ្វើការពេលព្រឹក រួមទាំងអ្នកដែលខ្ញុំស្គាល់ម្នាក់ឈ្មោះ កែវ ពីគា ជាអ្នកស្រុកជាមួយគ្នាចេញពីភ្នំពេញដូចខ្ញុំដែរ។ ខ្ញុំនិយាយទៅលោក គា ថា គា ឯងនិយាយថាធ្វើការ BGI (បេហ្សេអ៊ី) គ្រោះថ្នាក់ណាស់គួរកុំនិយាយល្អជាង គា ឆ្លើយថា អាពួកហ្នឹងទាល់តែនិយាយអញ្ចឹងទើបវាខ្លាចយើងបង វាល្ងង់មិនដឹងអីទេ ខ្ញុំនិងបងសុន ក៏លែងនិយាយតទៅទៀត ហើយក៏មិនហ៊ាននៅជិតមិត្តគាត់ទៅទៀតដែរ ព្រោះថាចរិករបស់គាត់និងគ្នាគាត់ជាច្រើនទៀត ដែលជាទាហាននៅរក្សាចរិកដដែល និងចូលចិត្តមើលងាយពួកសន្តិសុខពួកគេហាក់ដូចជាមិនដឹងថាគ្រោះថ្នាក់កំពុងនៅចំពោះមុខ។ ខ្ញុំនិយាយប្រាប់រឿងនេះទៅបងសុនៗ តបមកខ្ញុំវិញថា ឆាន ឯងនិយាយនេះត្រឹមត្រូវណាស់ ដូច្នេះយើងទាំងពីរនាក់គួរនៅឲ្យឆ្ងាយពីក្រុមនេះទើបបានសេចក្តីសុខ។

### ៤.៣. ការហៅប្រជុំសម្ងាត់

ពេលល្ងាចក៏មានការកោះហៅអ្នកថ្មីប្រជុំម្តងទៀតដើម្បីលែងឲ្យទៅផ្ទះ។ ខ្ញុំ និងបងសុន ក៏ចូលទៅនឹងគេដែរ តែអង្គុយចុងក្រោយចាំស្តាប់គេហៅឈ្មោះម្តងមួយៗចូលទៅក្នុងបន្ទប់ប្រជុំសម្ងាត់។ ហៅដល់ឈ្មោះទី២០ គេក៏ឈប់ហៅតទៅទៀត ហើយមានអ្នកស្រែកពីក្នុងមកថា ប៉ុណ្ណឹងបានហើយ បិទទ្វារប្រជុំ។ បងសុន ឡើងឈរតវ៉ាទៅមិត្ត សារិន ជាអនុប្រធានស្នាក់ការភ្លាមថា បងខ្ញុំ២នាក់នេះក៏ជាប្រជាជនថ្មីដែរបង ម៉េចមិនឲ្យរួចផងបង? មិត្ត សារិន ដែលរៀបការ៤២គូ ជាមួយខ្ញុំ ភ្ញាក់រួចក្រឡេកឃើញខ្ញុំក៏សួរបងសុនថា តើអ្នកឯងជាប់ប៉ុន្មានឆ្នាំហើយ? បងសុនឆ្លើយថា ៦ខែ ហើយបង មិត្តសារិនប្រាប់ថាគេជាប់ដល់រលួយដូចគោមិនទាន់រួចផង ឯងទើបតែជាប់៦ខែចង់រួចទៅផ្ទះ ដូចឆាន អីហ្នឹងក៏មិនទាន់រួចដែរ។ ថាហើយមិត្ត សារិន ក៏សើចហើយដេញពួកយើងឲ្យទៅធ្វើការ។ បងសុន មិនអស់ចិត្តនៅតែអង្គុយមិនព្រមចេញទៅធ្វើការមិត្ត សារិន ក៏ទាញទំពក់រនាស់មកជន្លូដេញឲ្យទៅធ្វើការកុំឲ្យនៅក្បែរនេះអង្គការប្រជុំ។



ហង្ស ឆាំឆាន ពេលបួសជាព្រះសង្ឃ។ (ហង្ស ឆាំឆាន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

### ៤.៤. សូមអង្វរគេទៅស្លាប់

តាមពិតបើសិនជាមានតែបងសុន ម្នាក់ឯង មិត្តសារិន ឲ្យបញ្ចូលឈ្មោះជាមួយគេយកបងសុន ទៅសម្លាប់ចោលបាត់ទៅហើយ (ក្រោយមកទើបដឹង) ព្រោះមិត្តសារិន ជាអនុប្រធានក្រុមការងារនេះគាត់មានសិទ្ធិសម្រេចនៅពេលនោះ។ តែមិត្ត សារិន គាត់ឃើញខ្ញុំគាត់អាណិតខ្ញុំ គាត់ដឹងថា ខ្ញុំការហើយមិនបានមួយអាទិត្យផង គេយកមកដាក់គុក ដោយសារផ្ទះប្រពន្ធគាត់និងផ្ទះប្រពន្ធខ្ញុំនៅក្បែរគ្នា។ ខ្ញុំមិននិយាយអ្វីទាំងអស់ ក្រៅតែអង្គុយចោងហោងលើកដៃប្រណម្យសុំការអាណិតពីគេ មានតែបងសុន ទេដែលនិយាយផងលើកដៃប្រណម្យផង សុំគេរួចទៅផ្ទះ។ ដោយគេមិន

មើលមុខ និងទទួលការអង្វរពីគេៗ យើងទាំងពីរនាក់ក៏ត្រឡប់ទៅធ្វើការ តែមិនហ៊ានទៅណាឆ្ងាយទេ នៅធ្វើការចម្ងាយប្រហែល៥០ម៉ែត្រ និងបង្ហាញខ្លួនឲ្យគេឃើញក្រែងគេហៅៗ ការប្រជុំមិនបាន១ម៉ោងផង ក៏រំសាយទៅ អ្នកទោសទាំង២០នាក់ចេញពីប្រជុំមិនមាននិយាយអ្វីទាំងអស់គ្រាន់តែសើចញឹមៗជាធម្មតា ជាពិសេសមិត្តគា ខ្ញុំសួរគាត់ថាម៉េចដែរគា? មិត្តគា ឆ្លើយថា ប្រហែលជាស្អែកឬខានស្អែកបានរួច ហើយអង្គការមិនទុកនៅយូរទេឲ្យពួកខ្ញុំទៅផ្ទះ យកក្រុមបងឯងមកជំនួសពួកខ្ញុំ ខំប្រឹងធ្វើការទៅបង ឆាប់បានទៅផ្ទះៗ ពាក្យនេះបងសុន និងខ្ញុំតូចចិត្តណាស់ មិនមាត់ក៏ដើរចេញពីក្រុមគេទៅនិយាយគ្នាតែ២នាក់ៗ ល្ងាចនោះមិត្តគា បានសុំច្បាប់ទៅផ្ទះ១យប់នៅសង្កាត់ដែកំពកចម្ងាយប្រហែលជា៥គីឡូពីគុកៗ

### ៤.៥. ថ្ងៃចាប់ខ្លួនអ្នក១៧ មេសាទៅសម្លាប់

លុះព្រឹកឡើងម៉ោង៨ស្រាប់តែឃើញក្រុមសន្តិសុខ២០នាក់ កាន់កាំភ្លើងគ្រប់ដៃមកដល់គុក រួចហៅឈ្មោះអ្នកប្រជុំពីម្សិលមកចងស្លាបសេកភ្លាមៗ រួចបណ្តើរទៅឆ្លងបឹងបង្កោលទៅបាត់ និងសន្តិសុខ២នាក់ទៀតរង់ចាំមិត្តគា មកដល់ទាំងមុខក្រញូវ និងឲ្យមិត្តផុន ជិះកង់ទៅហៅមិត្ត គា ថាអង្គការមកដោះលែងៗ ឯពួកយើងខ្ញុំ២៥នាក់ គេឲ្យចូលក្នុងគុកចាក់សោ ពេលដឹងថាមិត្តគា មកជិតដល់ហើយក៏លែងឲ្យពួកខ្ញុំចេញធ្វើការធម្មតា កុំឲ្យមិត្ត គាសង្ស័យៗ មិត្តគា មកដល់ខំសើចសប្បាយចិត្តពីចម្ងាយដាក់ពួកខ្ញុំ មិនទាន់ទាំងចូលកន្លែងផង សន្តិសុខ២នាក់ ភ្ជង់កាំភ្លើងចងស្លាបសេកនាំទៅបាត់តាមក្រោយគេៗ ឃើញដូច្នេះ បងសុនរត់មករកខ្ញុំនិយាយទាំងទឹកមុខស្លេកស្លាំង និងមាត់ប៉ប៉ាច់ប៉ប្រាចថា ឆាន អើយ ឆាន យើងសុំគេទៅផាប់គេមិនឲ្យ សំណាងណាស់យើង ! និយាយហើយក៏បែកផ្លូវគ្នាធ្វើការរៀងៗខ្លួនទៅៗ

### ៤.៦. សម្រុកធ្វើស្រូវព្រោះ២៥០ហិកតា

នៅជុំវិញគុកទួលសំរិតដីប្រមាណជាង២៥០ហិកតា ជាដីសន្តិសុខស្រុកកោះជ័យ (ក្នុងនេះដីជាង៥០ហិកតា ជាអតីតដីលោកឪពុកខ្ញុំដែលខ្មែរក្រហមរឹបអូសយកកាលពីឆ្នាំ១៩៧៣)ៗ ឆ្នាំនេះភ្លៀងធ្លាក់ដើមឆ្នាំតិចតួចណាស់ ធ្វើឲ្យការធ្វើស្រូវពង្រោះមិនបានទាន់ពេលដូចឆ្នាំមុនៗទេ ក្រុមយើងខ្ញុំមានគ្នា២៥នាក់ត្រូវភ្ជួរដីនេះ និងព្រោះស្រូវឲ្យហើយនៅមុនដាច់ខែកក្កដាៗ ដូច្នេះអង្គការកំណត់ក្នុងមួយក្រុមមាននង្គ័ល៤ និងរនាស់១ អ្នករាស់ដីមានភារកិច្ចព្រោះផង រាស់ដីលុបគ្រាប់ស្រូវព្រោះផងត្រូវធ្វើឲ្យហើយដី១ហិកតា ១ព្រឹកៗ ខ្ញុំត្រូវគេចាត់តាំងឲ្យរាស់ដី និងព្រោះស្រូវ ខ្ញុំមានក្របី១នឹម រនាស់១និងស្រូវពូជ២បាវប្រហែលជិត២០០គីឡូក្រាម ដឹកទៅជាមួយរៀងរាល់ព្រឹកៗ ថ្ងៃដំបូងក្រុមយើងខ្ញុំត្រូវទៅភ្ជួរព្រោះស្រែរបស់ខ្ញុំនៅចម្ងាយ៥០០ម៉ែត្រពីផ្ទះខ្ញុំៗ ខ្ញុំស្រណោះខ្លួនណាស់មិនដឹងថា អ្នកម្តាយខ្ញុំដឹងថាកូនគាត់ជាអ្នកទោសមកភ្ជួរស្រែខ្លួនឯងឬអត់ទេ? ប្រហែលជាមិនដឹងទេមើលទៅ? ខ្ញុំចាប់ផ្តើមព្រោះស្រូវមួយផារម្តងរួចរាស់ដីបណ្តើរទឹកភ្នែកហូរមកឯងៗ ដោយមិនដឹងខ្លួនពេលក្រឡេកឃើញផ្ទះនៅជិតបង្កើយហើយមិនអាចទៅជួបអ្នកម្តាយ លោកឪពុក និងប្អូនៗបានៗ ម៉ោង១០ ថ្ងៃទី១ ក្រុមយើងធ្វើបាន៥ហិកតាដោយជោគជ័យ ពួកយើងសប្បាយចិត្តណាស់ៗ ការដ្ឋានធ្វើស្រូវពង្រោះរបស់ពួកយើងបានប្រព្រឹត្តទៅជាធម្មតា ពុំសូវមានប្រជាជនណាហ៊ានដើរកាត់ក្បែរផ្លូវដែលពួកយើងភ្ជួរទេ ព្រោះគេមិនហ៊ានទៅជិតការដ្ឋានសន្តិសុខ និងឃើញអ្នកទោសដែលគេធ្វើបាបទេៗ

### ៤.៧. ជួបបងស្រីបានព័ត៌មានដល់គ្រួសារខ្ញុំ

ថ្ងៃមួយ ខ្ញុំឃើញបងស្រីភូមិឫស្សីស្រុក១ក្រុមមានគ្នា៥នាក់ដើរចុះទៅបឹងដោល កាត់តាមផ្លូវជាប់ភ្លឺស្រែដែលពួកយើងកំពុងភ្ជួរ បងស្រីខ្ញុំឈ្មោះ ហាក់ជូ ជាប្រពន្ធបងជាម យៀប ក្រឡេកឃើញខ្ញុំភ្លាម គាត់ភ្ញាក់ហាក់បីដូចជាចង់ហក់មករកខ្ញុំ តែខ្ញុំលើកដៃជាសញ្ញាចង្អុលទៅពួកសន្តិសុខឲ្យគាត់ឃើញពួកនោះកំពុងអង្គុយយាមខ្ញុំនៅក្បែរនោះ គាត់ក៏ឈ្ងោកមុខជូតទឹកភ្នែកដើរចេញទៅៗ ក្រោយមកទៀតពួកយើងទៅភ្ជួរកន្លែងផ្សេង លែងឃើញអ្នកណាដើរកាត់ទៀត ហើយព័ត៌មាននេះបានដឹងដល់អ្នកម្តាយ លោកឪពុក និងបងប្អូនខ្ញុំ តែមិនទាន់មានអ្នកណាហ៊ានមករកខ្ញុំភ្លាមៗទេ ជាពិសេស លោកឪពុកកំពុងរិះរកវិធីត្រូវជួយសង្គ្រោះខ្ញុំរបៀបណា?ៗ មួយអាទិត្យក្រោយមកលទ្ធផលនៃការផាររបានល្អប្រសើរ អង្គការបានបន្ធូរបន្ថយមិនសូវជាយាមកាមតឹងរ៉ឹងដូចមុនទេ អ្នកខ្លះក៏ដាច់ចិត្តសុំទៅលេងផ្ទះនៅជិតៗពេលព្រឹកក្រោយភ្ជួររួច ល្ងាចមកគុកវិញ ក្នុងនោះមានមិត្ត វ៉ាត និងមិត្ត មីន ផ្ទះគាត់នៅភូមិម្លូរថ្មីចម្ងាយ២គីឡូដី ខាងកើតគុកៗ ឃើញដូច្នេះ ខ្ញុំក៏ដាច់ចិត្តសុំមិត្ត សារិន គាត់ក៏យល់ព្រមតែផ្តាំថា កុំទៅយូរពេល ហើយកុំឲ្យប្រធានបុកម្មាភិបាលសហករណ៍ឃើញប្រយ័ត្នគេប្តឹងបើគេប្តឹងទទួលខុសត្រូវខ្លួនឯងៗ ខ្ញុំឆ្លើយបាទអរគុណណាស់បងៗ

### ៤.៨. ជួបអ្នកមានគុណថ្ងៃដំបូង

ម៉ោង១២ថ្ងៃត្រង់ខ្ញុំទៅដល់ផ្ទះជាមួយនឹងសម្លៀកបំពាក់អាវរហែកយ៉ុយ ដែលខ្ញុំដេរដោយដៃឯងនៅពេលធ្វើការរហែកៗ អ្នកម្ដាយកំពុងសម្រាកស្រែកយំភ្លាត់មាត់ទាំងទឹកភ្នែករត់មកឱបខ្ញុំៗ កូនម៉ែ! បានតែប៉ុណ្ណោះលោកឪពុកយកដៃខ្ទប់មាត់ថាកុំឮពេក ឮដល់ពួកអស់នេះ នាំបញ្ហាទៀតៗ លោកឪពុកបានប្រាប់ប្អូនស្រីឲ្យទៅហៅប្អូនៗមកជួបខ្ញុំហើយសួរនាំពីការវង្វេងកាត់ការលំបាកនិងទារុណកម្មទាំងឡាយ និងដាំបាយឲ្យខ្ញុំហូប តែខ្ញុំប្រាប់ថា ខ្ញុំមិនអាចនៅយូរបានទេ ខ្លាចអាពួកសហករណ៍វាដឹងគេប្ដឹងខ្ញុំអាចនឹងគ្រោះថ្នាក់ដល់ជីវិតៗ ដោយគ្រួសារខ្ញុំ មាននៅសល់ស្រូវច្រើនគេមិនទាន់ប្រមូលចូលសហករណ៍ តែងតែដាំបាយឲ្យសល់ជានិច្ច និងដើម្បីឲ្យទាន់សភាពការណ៍ប្អូនស្រីខ្ញុំក៏វេចបាយកកដែលទើបនឹងហូបរួចអស់ពីក្នុងឆ្នាំងមកឲ្យខ្ញុំ រួមទាំងចំណីដែលមានផ្សេងៗទៀតបានមួយបង្វិចធំមកឲ្យខ្ញុំៗ អ្នកម្ដាយបានទៅយកអាវនិងខោថ្មីៗ មកដាក់ក្នុងបង្វិចរួចសួរថា តើខោអាវកូនឯងរហែកអស់ឬ? បានជាស្លៀកពាក់អាចរហែករយ៉ែអញ្ចឹង ខ្ញុំឆ្លើយថា បាទមែនហើយម៉ែ ខ្ញុំរែកដី រែកទឹករហូតខោអាវម៉ែដាក់ឲ្យពីមុនរហែកអស់ហើយ នៅសល់តែ១ហ្នឹងៗ អ្នកម្ដាយឮដូច្នេះក៏យំម្ដងទៀតជាមួយបងជីដូនមួយ និងប្អូនៗ ហើយគាត់ប្រាប់ថាកុំស្លៀកអញ្ចឹងទៀត កូនម៉ែឃើញកូនស្លៀកអញ្ចឹងម៉ែក្ដុកក្ដួលណាស់ៗ អស់ពេលមួយម៉ោងជាងខ្ញុំក៏ថ្វាយបង្គំអ្នកមានគុណទាំងពីរ និងលាបងប្អូនត្រឡប់ទៅគុកវិញៗ ស្រូវពង្រោះបានដុតស្ទើរគ្រប់ស្រែ ទាំងស្រែសន្តិសុខ ទាំងស្រែសហករណ៍សង្កាត់បឹងដោលដីទំនេរសម្រាប់លែងគោ ក្របីឲ្យស៊ីស្មៅកាន់តែចង្អៀតៗ ម្យ៉ាងទៀត ស្នាក់ការសន្តិសុខស្រុកកោះដ័យមួយចំនួនត្រូវបានរំសាយ ដូចជា គុកពោធិ៍បូរីជាដើមៗ ដូច្នេះគោ ក្របី នៅតាមស្នាក់ការទាំងនោះត្រូវយកមកទុកនៅគុកទួលសំរិតៗ

### ៤.៩. ការបែងចែកកម្លាំងឃ្វាលគោ

ល្ងាចមួយមិត្ត សួន ប្រធានស្នាក់ការបានបែងចែកកម្លាំងបន្ថែមការងារទៀតគឺ ហ៊ុន សុន , ហង្សឆាន និង ភោគ វ៉ាត ក្រោយពីភ្ជួររាស់ពេលព្រឹករួចមិនបាច់ទៅលើកភ្លឺស្រែទេគឺទៅឃ្វាលគោ និងក្របីកុំឲ្យស៊ីស្រូវពង្រោះៗ ពេលនេះយើងខ្ញុំហាក់ដូចជាមានសេរីភាពគ្រាន់បើជាងមុន ការងារធ្វើស្រែជារឿងធម្មតាសម្រាប់រូបខ្ញុំជាកូនកសិករឆ្លៀតពេលនេះខ្ញុំរៀនសូត្របានជាច្រើននូវអ្វីដែលខ្ញុំមិនបានធ្វើពីមុនដូចជារៀនវិញខ្សែគោ ធ្វើនង្គ័លភ្ជួរដីៗលៗ យ៉ាងពូកែជាងអ្នកខ្លះដែលនៅក្នុងគុកជាមួយខ្ញុំទៀតផងៗ ព្រឹកនេះក្រោយពីព្រោះស្រូវពេលព្រឹករួចហូបបាយហើយ យើងទាំងបីត្រូវធ្វើដំបងឫស្សីពីងពង់ប្រវែងជាង១ម៉ែត្រមួយម្នាក់ កាន់ដៃដើម្បីគម្រាមគោ ក្របី និងដេញវាទៅវាលស្មៅមាត់បឹងដ៏ធំល្វឹងល្វើយ ខាងលិចស្នាក់ការសន្តិសុខៗ គោ និងក្របី សរុបមានចំនួនជាង៤០០ងាយស្រួលត្រង់យើងនៅចាំតែខាងណាមានស្រូវ បង្អើលពួកវាមិនឲ្យចូលស៊ីស្រូវ បើអាណាមួយហ៊ានចចេសនឹងប៉ះបញ្ហាត្រូវព្រមានវាដោយចោលនឹងដំបងពីងពង់ ចោលតែ២ទៅ៣ដង វាលែងហ៊ានមក ពួកយើងបានអង្គុយជុំគ្នាជជែកគ្នាពីអតីតកាលរៀងៗខ្លួនប្រាប់គ្នាៗ ដោយមានពេលទំនេរច្រើន មិត្តវ៉ាត ក៏ទៅសុំខ្ទីឈ្នាងសន្តិសុខពីមិត្ត សួន ដើម្បីជញ្ជូតត្រី កំពឹស មកហូបឲ្យមានកម្លាំងរត់ដេញគោ ក្របីៗ បានឈ្នាងមកថ្ងៃដំបូងគ្រាន់តែ មិត្តវ៉ាត ចុះជញ្ជូតមួយម៉ោងបានត្រីតូចៗនិងកំពឹសមួយល្អីពេញយកមកលីងនិងស្ងោរហូបគ្នា៣នាក់អស់គ្មានសល់ ព្រោះក្រពះយើងទាំងអស់គ្នាពុំបានហូបឆ្អែតយូរដែរហើយពេលនេះអង្ករតិចចាក់ចូលជាមួយកូនត្រីបបរហូបមិនឆ្អែត ក៏លីងកំពឹងដែលមានទាំងប៉ុន្មានហូបមិនឆ្អែតទៀតៗ

### ៤.១០. ឃ្វាលគោបានត្រីហូប និងរបបអង្ករ១០កំប៉ុងហូប៣នាក់អស់រលីង

ឃ្វាលគោបាន៥ថ្ងៃ ពួកយើងតែងតែជញ្ជូតត្រី កំពឹសហូបដូចរាល់ដង ដល់យូរទៅហូបកំពឹសលែងអស់ក៏ហាលទុកយកផ្ញើទៅផ្ទះៗ មិត្តសួនក៏លបទៅមើលពួកយើងពីការឃ្វាលគោ ក្របី និងឆែកមើលថាពួកហ្នឹងវាបានស៊ីស៊ី ហាក់ដូចជាមានកម្លាំងរត់លឿនៗម្ល៉េះៗ គាត់ទៅមើលឆ្នាំងបាយយើងមានឆ្នាំងមួយតែធំ គាត់សួរ ចុះបានអីស្ល យើងឆ្លើយថាទៅជញ្ជូតកំពឹសមកស្ងោរហូប បងចុះថ្ងៃនេះបានកំពឹសប៉ុន្មាន? ពួកយើងចង់លាក់កុំឲ្យមិត្តសួន ដឹងពីរឿងបានកំពឹសច្រើនខ្លាចមានរឿង ក៏មិនឆ្លើយហើយមើលមុខគ្នាវិញ ទៅមក គាត់មានការងឿងឆ្ងល់ក៏ដើរទៅកំប៉ុតព្រៃនៅជិតនោះឃើញកំពឹសកន្ទះទៃ និងមួយល្អីទៀតដាក់ហាលលើក្រមាៗ គាត់ក៏សួរដោយឆ្ងល់ថាកំពឹសអ្នកណាហ្នឹង? មុនដំបូងគាត់ស្មានថាក្រែងពួកខ្ញុំលបទៅផ្ទះយកកំពឹសនេះមកទុកហូបៗ ដល់ឮពួកខ្ញុំឆ្លើយព្រមគ្នាថា កំពឹសពួកខ្ញុំជញ្ជូតបានយកមកហូបអស់ក៏ហាលទុកផ្ញើទៅផ្ទះបង គាត់ក៏មាត់ថាល្អណាស់ឆានវ៉ាត សុនប្រពន្ធកូនខ្ញុំនៅសហករណ៍គ្មានស៊ីស៊ីទេ ឥឡូវទាំងអស់គ្នាជួយចិញ្ចត់ឲ្យបានច្រើនមកឲ្យខ្ញុំផ្ញើទៅប្រពន្ធ កូន ខ្ញុំ ថែមរបបអង្ករហូបរាល់ថ្ងៃ ឆាន ចាំគេចេញអស់ទៅយកអង្ករពីខ្ញុំមួយអាទិត្យខ្ញុំទៅផ្ទះ

ម្តង វ៉ាត យកទៅលាក់តាមផ្លូវឲ្យខ្ញុំ។ ស្អែកឡើងខ្ញុំនៅវ៉េរ វេងចាំគេចេញអស់ ដើម្បីយកអង្ករបេបពីមិត្តសួន និងបានឲ្យមិត្តវ៉ាត និង មិត្តសុនដេញគោ ក្របីទៅវាលមុន។ ពេលគេចេញទៅធ្វើការអស់ មិត្ត សួនបក់ដៃហៅខ្ញុំចូលយកអង្ករ៦កំប៉ុងឲ្យ ហើយសួរថាប៉ុណ្ណឹងគ្រាន់ ឬអត់ ឆាន? ខ្ញុំក៏ប្រាប់ថាបងពួកនេះហូបច្រើនណាស់ ថ្ងៃមុនអង្ករបេប១កំប៉ុងកន្លះបូកនឹងកំពឹសមួយល្អីស៊ីអស់។ អញ្ចឹងចង់បានប៉ុន្មានទើបគ្រាន់ ឆាន? បានហើយ អរគុណបង។ ពេលទៅដល់វាលមិត្តសុន ចាក់អង្ករទាំង១០កំប៉ុងដាំបាយតែ១ពេលហើយ ហូបជាមួយកំពឹស១ល្អី ៣នាក់អស់គ្មានសល់។

### ៤.១១.ភាពទុកចិត្តគ្នារវាងសន្តិសុខនិងអ្នកទោស

ជារៀងរាល់ថ្ងៃមិត្ត សួនតែងតែឲ្យអង្ករពួកយើងដោយលួចលាក់ជួយគ្នាទៅវិញទៅមក ដោយបានឆ្អែតរាល់ថ្ងៃជាប់គ្នា ពួកយើងហូបលែងអស់ ខ្ញុំប្រាប់អស់មិត្ត សួនថាបងសុំបន្ថយមកនៅ១កំប៉ុងវិញព្រោះហូបលែងអស់ហើយ។ មិត្ត សួនទៅផ្ទះរាល់អាទិត្យ ពួកយើងផ្ញើផ្គត់ផ្គង់កំពឹសលីងរហូតដល់គាត់ប្រាប់ថាឈប់ទៅបានហើយ ប្រយ័ត្នគេដឹងមានរឿង។ ក្រោយមកមិត្តសួន ក៏ដូចជាសន្តិសុខផ្សេងទៀតក្នុងគុកឃើញសកម្មភាពពួកយើង ទាំងបីនាក់បេះជួយយកអាសារគ្នា ក៏រាប់អានពួកយើង និងបន្ធូរបន្ថយការផ្សារបើកឲ្យដើររកត្រីហូបនៅក្រៅម៉ោង បានត្រីហូបឆ្អែតម្នាក់ៗមានសាច់ឈាមស្រស់បស់ ហាក់ដូចជាមិនមែនអ្នកទោស អ្នកខ្លះទៀតដូចជាមិត្ត ទន់ សំ ក្លាយទៅជាអ្នកដុះក្បាលពោះ ស្អាតជាងប្រធានសហករណ៍ទៅទៀត។ ពេលខ្លះទុកចិត្តរហូតឲ្យខ្ញុំដេកជាមួយកាន់កាំភ្លើងជួយយាមគុកឲ្យទៀតផង។

### ៤.១២. ព័ត៌មានពីឪពុកក្មេកនិងការស្លាប់អនិកជនវៀតណាម

ពាក្យថាអ្នកទោសមួយម៉ាត់មិនដែលល្អរហូតទេពេលឃុំាលគោ ខ្ញុំបានទៅផ្ទះជួបអ្នកម្តាយលោកឪពុកស្ទើររៀងរាល់សប្តាហ៍ និងទទួលព័ត៌មានខ្លះពីប្រពន្ធសម្ងាញ់ លោកឪពុកអ្នកម្តាយក្មេក អាណិតលោកឪពុកក្មេកកើតទុក្ខពីរឿងខ្ញុំបានធ្លាក់ខ្លួនឈឺរហូតដល់អស់ជីវិត តែមុននឹងស្លាប់លោកហៅប្រពន្ធខ្ញុំ ម្តាយក្មេក និងអ្នកជិតស្និទ្ធផ្តាំថា អត់ពីគាត់ទៅបើកូនរួចពីគុកវិញជួយធ្វើយ៉ាងម៉េចឲ្យតែកូនបានជុំគ្នា ព្ញព័ត៌មាននេះខ្ញុំសែនរន្ធត់និងខ្លោចផ្សាណាស់។ ជីវិតខ្ញុំលិចអណ្តែតជាបន្តបន្ទាប់។ ខែតុលា ឆ្នាំ១៩៧៧ ព្រឹត្តិការណ៍មួយកើតឡើងគឺប្រមូលអាណិកជនវៀតណាម ដែលនៅសល់តាមភូមិមកសម្លាប់នៅសន្តិសុខទួលសំរិតជាច្រើននាក់ ក្នុងរយៈពេលជាង១អាទិត្យខ្ញុំឃើញពួកសន្តិសុខបណ្តើរអនិកជនវៀតណាម៤គ្រួសារដែលខ្ញុំស្គាល់នៅភូមិបឹងដោលនឹងភូមិម្លូរថ្មីងក្បែរផ្ទះខ្ញុំ និងឃើញគេសម្លាប់មនុស្សទាំងនេះវាយនឹងដំបងដូចវាយសម្លាប់សត្វ ខ្ញុំអាណិតណាស់ព្រោះមនុស្សទាំងអស់នោះជាមនុស្សដែលខ្ញុំស្គាល់នៅភូមិច្បាស់ធ្លាប់គោរពរៀនសូត្រ និងលេងជាមួយគ្នា។ ពេលនេះខ្ញុំត្រូវគេចាត់ឲ្យបរទេះដឹកកណ្តាប់ ជាមួយអ្នកផ្សេងទៀតសរុប១០នាក់។ អ្នកប្រូតអង្គការបានស្នើសុំកម្លាំងយុទ្ធនារីប្រមាណជា៥០០នាក់មកជួយប្រូតស្រូវ។ ក្រោយពីដឹកកណ្តាប់ ខ្ញុំមានភារកិច្ចបញ្ជូនស្រូវនិងជួយជញ្ជូនស្រូវឲ្យយុទ្ធនារីរោយ។

### ៤.១៣. ប្រមូលកម្លាំងគ្រប់កន្លែងមកប្រមូលផលស្រូវ

ដោយមានវត្តមានយុទ្ធនារី ក្រុមអ្នកទោសត្រូវរឹតបន្តឹងវិន័យយ៉ាងតឹងបំផុត ពេលនោះក៏មានកម្មាភិបាល និងអ្នកទោសពីស្នាក់ការគុកជាច្រើនកន្លែងត្រូវរំសាយមកទីនេះដែរ។ ពេលនេះគុកស្រុកកោះជ័យមានតែ២កន្លែងប៉ុណ្ណោះ គឺទួលានមន្ទីររួម និងគុក ទួលសំរិត។ ចាប់ពីពេលនោះមកអ្នកទោសមិនអាចចេញដើរទៅរកត្រីហូបបានដូចមុនទៀតឡើយ។ ពេលយប់ត្រូវដេកដាក់ខ្នោះ របបអាហារត្រូវបន្ថយមកកន្លះកំប៉ុងអង្ករ ការផ្សារត្រូវបង្កើនទ្វេរដង។ ក្រោយប្រមូលផលស្រូវរួចកម្លាំងអ្នកទោសប្រុសៗត្រូវប្រក់ និងលីស្រូវដាក់ ឡាន៧គ្រឿងបញ្ជូនទៅឲ្យអង្គការរាល់ថ្ងៃរយៈពេលប្រហែល១ខែទើបដឹកអស់ស្រូវ២ជង្រុកជាង២០០តោន។ បន្ទាប់មកអង្គការបានចាត់យើងខ្ញុំ៣នាក់គឺមិត្តសុន មិត្តវ៉ាតនិងខ្ញុំ ទៅកាប់ខសនៅតែព្រែកតាពុតចម្ងាយ៥គីឡូដីខាងជើងស្នាក់ការ។ ពួកយើងមានគ្នា៦នាក់ គឺសន្តិសុខ៣នាក់ទៅតាមយាមពួកយើង ព្រោះនៅព្រំដែនកាំភ្លើងធំស្នូលហាក់ដូចជានៅជិតៗនេះ និងការដេញតាមចាប់ឈ្មោះ ស៊ិន សុង សណ្ឌូត និង ទាហានដែលរត់ចេញពីគុកពោធិ៍បូរី គេកំពុងដេញតាមយ៉ាងក្តៅគគុកដោយមានទាំងប្រមូលប្រជាជនតាមភូមិរុករកក្នុងព្រៃ យោធាតំបន់ និងស្រុកតាមចាប់។ យើងទាំង៦នាក់មានរទេះគោ៣ កាំភ្លើង៣ដើម កាំបិតកាប់ខសគ្រប់ដៃ និងកន្ទ្រាវខ្វាត្រី២។

### ៤.១៤.យុទ្ធនារីចាប់ពួកខ្ញុំក្នុងព្រៃចងស្លាបសេកដោយប្រទ្បំ

ម៉ោង៧ កាប់ខសពេញរទេះហើយនាំគ្នាដើររកឃ្មុំរហូតដល់ពេលបាយបានឃ្មុំជាច្រើនសម្បុករួច មិត្តសុនចាំមើលគោ ពួកខ្ញុំពីរនាក់ចុះខ្វាត្រី

(តនៅលេខក្រោយ)

រូបក្របមុខ ៖

ព្រះឆាយាលក្ខណ៍ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ, សម្តេចព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរ និងព្រះរាជបុត្រាទាំងពីរ គឺ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី និង នរោត្តម នរិន្ទ្រពង្ស ។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ ៖

ព្រះឆាយាលក្ខណ៍សម្តេចព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣*

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 294, June 2024 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.